**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Universitè Royale de Droits et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# តួនាទី និងភារកិច្ចអយ្យការ

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២២


សិក្សាស្រាវជ្រាវដោយៈ

និស្សិតៈ លោក **មុនី ឥថៈយុសុទត្តិគមន៍**

កញ្ញា **ស៊ិន ស្រីពេជ្រ**

សាស្ត្រាចារ្យណែនាំ

លោក **ខាត់ ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# លិខិតថ្លែងអំណរគុណ

ក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំមានដូចជា លោក មុនី តថៈយុសុវត្ថិគមន៍ និងកញ្ញា ស៊ិន ស្រីពេជ្រ ជានិស្សិតថ្នាក់បរិញ្ញាប័ត្រនីតិសាស្រ្តជំនាន់ទី២២ ក្រុមL៤C៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២១-២០២២ ។

ជាដំបូងក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកឪពុកអ្នកម្ដាយ ដែលលោកទាំងពីរបានផ្ដល់កំណើតដល់រូបយើងខ្ញុំ ហើយលោកបានចំណាយពេលវេលា និងខិតខំចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្ដីដោយមិនគិតពីភាពនឿយហត់ឡើយ ។ លោកបានអប់រំ ទូន្មាន ប្រៀនប្រដៅឲ្យយើងខ្ញុំស្គាល់នូវអ្វីខុសអ្វីត្រូវ យោគយល់អធ្យាស្រ័យនូវរាល់កំហុស ដែលកូនៗបានប្រព្រឹត្តឆ្គាំឆ្គង និងព្រមទាំងបានលះបង់អស់នូវកម្លាំងកាយ កម្លាំងចិត្ត ដើម្បីឲ្យកូនៗបានសិក្សារៀនសូត្ររហូតមកដល់ថ្ងៃនេះ ។

ជាមួយគ្នានេះផងដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី សាស្រ្តចារ្យទាំងអស់នៃមហាវិទ្យាល័យនីតិសាស្រ្ត ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការអប់រំបណ្ដុះបណ្ដាល ដល់រូបយើងខ្ញុំទាំងពីរនាក់ យ៉ាងយកចិត្តទុកដាក់ ព្រមទាំងបានស្វះស្វែងរកឯកសារដែលថ្មីៗល្អៗក្នុងចែករំលែកចំណេះដឹង និងតែងតែអប់រំយើងខ្ញុំឲ្យប្រព្រឹត្តនូវអំពើល្អ ថែមទាំងលើកទឹកចិត្តក្នុងការសិក្សាផងដែរ ។

ជាពិសេសទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់លោកសាស្រ្តាចារ្យ **ខាត់ ធី** ជាសាស្រ្តាចារ្យដឹកនាំសារណារហូតធ្វើឲ្យកិច្ចការនេះសម្រេចបាន ដោយភាពជោគជ័យ ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធិពរជ័យចំពោះលោកអ្នកមានគុណទាំងពីរ ថ្នាក់ដឹកនាំនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងលោក លោកស្រី ដែលជាសាស្រ្តាចារ្យទាំងអស់ ក៏ដូចជាមិត្តភក្តិបងប្អូន សូមឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ឆ្លងកាត់ការសិក្សាផ្នែកនីតិសាស្ត្រ អស់រយៈពេល៤ឆ្នាំ ក្រុមយើងខ្ញុំពិតជាមានភាពរីករាយជាខ្លាំងដែលមានកិត្តិយសបានចូលរួមចងក្រង សរសេរសារណាបញ្ចប់ការសិក្សាធ្វើជាស្នាដៃសម្រាប់ជាឯកសារស្រាវជ្រាវនាពេលអនាគត ។ ដោយហេតុថា ការសិក្សារបស់យើងខ្ញុំមានការទាក់ទងជាមួយនឹងវិស័យច្បាប់ ដូចនេះយើងខ្ញុំបានជ្រើសរើសយកប្រធានបទស្តីពី ស្ថាប័នអយ្យការ ក្នុងគោលបំណងស្រាវជ្រាវឲ្យបានស៊ីជម្រៅពីការបំពេញមុខងាររបស់តំណាងស្ថាប័នមួយនេះ តាំងពីប្រវត្តិនៃការកកើត ដំណើរការប្រព្រឹត្តទៅរបស់តំណាងអយ្យការ និងការស្វែងរកយុត្តិធម៌ជូនសង្គមជាតិលើរឿងក្តីព្រហ្មទណ្ឌ ។

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋ ដែលបង្កើតឡើងសម្រាប់ដំណើរការបណ្តឹងសាធារណៈ ឬបណ្តឹងព្រហ្មទណ្ឌ ដើម្បីនាំមកនូវសណ្តាប់ធ្នាប់ល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងជាតិរបស់ខ្លួនឲ្យមានការរីកចម្រើន ។ ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដ៏សំខាន់ដែលស្ថិតនៅអមសាលាក្តីគ្រប់ជាន់ថ្នាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ស្ថាប័នអយ្យការ គឺជាអ្នកធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ និងជាអ្នកសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់ មិនតែប៉ុណ្ណោះ ស្ថាប័នអយ្យការជាអ្នកធានារ៉ាប់រងលើការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងជាអ្នកផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួនផងដែរ ។ម្យ៉ាងវិញទៀត ចៅក្រមអយ្យការមានសិទ្ធិក្នុងការកេណ្ឌកងកម្លាំងសមត្ថកិច្ចសាធារណៈដោយផ្ទាល់ ដើម្បីជាជំនួយក្នុងការបំពេញភារកិច្ចរបស់ខ្លួន ហើយចៅក្រមអយ្យការចាំបាច់ត្រូវតែមានវត្តមានក្នុងសវនាការរឿងក្តីព្រហ្មទណ្ឌ ។

យើងខ្ញុំសង្ឃឹមថា សារណាដែលយើងខ្ញុំបានសរសេរឡើងនេះ នឹងក្លាយជាឯកសារផ្នែកច្បាប់មួយដែលមានសារៈប្រយោជន៍ ដល់និស្សិតជំនាន់ក្រោយៗទៀត ក្នុងការពង្រឹង និងលើកស្ទួយវិស័យយុត្តិធម៌នៅកម្ពុជាឲ្យកាន់តែរឹងមាំ ។ ជាមួយគ្នានេះដែរ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចការស្រាវជ្រាវមួយនេះនឹងក្លាយជាឯកសារមួយដែលអាចជួយពង្រឹងសមត្ថភាពយល់ដឹងលើស្ថាប័នអយ្យការជាក់ជាមិនខាន ។

យ៉ាងណាមិញ បើទោះបីជាលទ្ធផលនៃការសិក្សាបានស្តែងចេញតាមរយៈសារណានេះក៏ដោយ ក៏ក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំយល់ថានៅមានខ្វះចន្លោះមួយចំនួនដែលមិនអាចជៀសវាងបានជាក់ជាមិនខាន ។ យើងខ្ញុំរីករាយនិងស្វាគមន៍រាល់ការរិះគន់កែតម្រូវរាល់ចំណុចខ្វះខាតដែលមានក្នុងសារណារបស់យើងខ្ញុំ ។ យើងខ្ញុំក៏សូមអរគុណទុកជាមុន រាល់ការរិះគន់ កែតម្រូវក្នុងគោលបំណងស្ថាបនា ។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រងព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ឲ្យជួបនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

**សេចក្តីផ្តើម** ............................................................ ០១

## ជំពូកទី១

## ស្ថាប័នអយ្យការ និង តំណាងអយ្យការ

**ផ្នែកទី១៖ ស្ថាប័នអយ្យការ** ............................................................ ០៤

**១. និយមន័យស្ថាប័នអយ្យការ** ............................................................ ០៤

**២. ប្រវត្តិនៃការកកើតស្ថាប័នអយ្យការ** ............................................................ ០៥

២.១. ការកកើតស្ថាប័នអយ្យការដំបូង ............................................................ ០៥

២.២. ការកកើតស្ថាប័នអយ្យការនៅកម្ពុជា ............................................................ ០៥

២.១.១. ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៣៧-១៩៧០ ............................................................ ០៥

២.១.២. ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៧០-១៩៧៥ ............................................................ ០៦

២.១.៣. ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ............................................................ ០៦

២.១.៤. ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៧៩-១៩៩១ ............................................................ ០៧

២.១.៥. ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៩១-បច្ចុប្បន្ន ............................................................ ០៧

**៣. គោលការណ៍នៃស្ថាប័នអយ្យការ** ............................................................ ០៩

៣១.. គោលការណ៍គ្រឹះរបស់អង្គការអយ្យការ ............................................................ ០៩

៣.១.១. គោលការណ៍ឯកភាព ឬ ឋានានុក្រម ............................................................ ០៩

៣.១.២. គោលការណ៍អវិភាគ ............................................................ ០៩

៣.១.៣. គោលការណ៍ឯករាជ្យ ............................................................ ១០

៣.១.៤. គោលការណ៍នៃការមិនទទួលខុសត្រូវ ............................................................ ១០

៣.១.៥. គោលការណ៍មិនអាចប្តឹងជំទាស់ ............................................................ ១០

៣.២. គោលការណ៍នៃការចោទប្រកាន់ ............................................................ ១១

៣.២.១. គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ............................................................ ១១

៣.២.២. គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ............................................................ ១២

**ផ្នែកទី២៖ តំណាងអយ្យការ** ............................................................ ១២

**១. តំណាងអយ្យការ** ............................................................ ១២

១.១. ការជ្រើសរើស ..................................................................................................... ១២
១.២. ការចុះកម្មសិក្សា និងតែងតាំងស៊ុបចំពោះព្រះរាជអាជ្ញា..................................................... ១៤
១.៣. ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ........................................................................................ ១៤
១.៤. ការតែងតាំង ផ្លាស់ប្តូរ ការផ្តាច់មុខងារ ........................................................................... ១៦
១.៥. កាតព្វកិច្ចទូទៅរបស់ព្រះរាជអាជ្ញា ................................................................................... ១៧
១.៦. ទណ្ឌកម្មវិន័យ .................................................................................................................. ១៨
១.៧. ការចូលនិវត្តន៍ ................................................................................................................. ១៩
**២.ព្រះរាជអាជ្ញា** ............................................................................................................ ២០
២.១. អ្វីទៅជាព្រះរាជអាជ្ញា?...................................................................................................... ២០
២.២. សញ្ញាណនៃព្រះរាជអាជ្ញា ................................................................................................. ២១

## ជំពូកទី២

## រចនាសម្ព័ន្ធស្ថាប័នអយ្យការ

**ផ្នែកទី១៖ ស្ថាប័នអយ្យការនៅអមសាលាជម្រះក្តី**................................................................ ២២
**១. អយ្យការអមតុលាការយោធា** ........................................................................................ ២២
១.១. រចនាសម្ព័ន្ធ..................................................................................................................... ២២
១.២. មុខងារព្រះរាជអាជ្ញាអមតុលាការយោធា............................................................................. ២២
១.៣. អំណាចរបស់ព្រះរាជអាជ្ញាអមតុលាការយោធា ..................................................................... ២៣
**២. អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**........................................................................... ២៤
២.១. រចនាសម្ព័ន្ធ..................................................................................................................... ២៤
២.២. មុខងារព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត ............................................................. ២៥
២.៣. អំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត....................................................... ៣០
**៣. មហាអយ្យការអមសាលាឧទ្ធរណ៍** .................................................................................... ៣១
៣.១. រចនាសម្ព័ន្ធ ..................................................................................................................... ៣១
៣.២. មុខងារអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ........................................................................ ៣២
៣.៣. អំណាចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍.................................................................. ៣២
**៤. មហាអយ្យការអមតុលាការកំពូល**..................................................................................... ៣៣
៤.១. រចនាសម្ព័ន្ធ..................................................................................................................... ៣៣

៤.២. មុខងារអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ............ ៣៣

៤.៣. អំណាចរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ............ ៣៤

**ផ្នែកទី២៖ ប្រវត្តិអយ្យការអមតុលាការជាន់ទាប** ............ ៣៥

**១. អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ............ ៣៥

១.១. ប្រវត្តិអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ............ ៣៥

១.២. រចនាសម្ព័ន្ធរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ............ ៣៦

**២. អយ្យការអមតុលាការយោធា** ............ ៣៧

២.១. ប្រវត្តិអយ្យការអមតុលាការយោធា ............ ៣៧

២.២. រចនាសម្ព័ន្ធរបស់អយ្យការអមតុលាការយោធា............ ៣៨


## ជំពូកទី៣

## នីតិវិធី និងចំណាត់ការរបស់អយ្យការក្នុងរឿងក្ដីព្រហ្មទណ្ឌ


**ផ្នែកទី១៖ នីតិវិធីស៊ើបអង្កេត** ............ ៣៩

**១. ការស៊ើបអង្កេតករណីជាក់ស្ដែង** ............ ៣៩

១.១. ការឆែកឆេរ ............ ៣៩

១.២. ការឃាត់ខ្លួន ............ ៤០

១.៣. ការបញ្ជូនខ្លួន ............ ៤០

**២. ការស៊ើបអង្កេតបឋម** ............ ៤០

២.១. ការឆែកឆេរ ............ ៤១

២.២. ការបញ្ជាឲ្យចូលខ្លួន ............ ៤១

**ផ្នែកទី២៖ នីតិវិធីស៊ើបសួរ** ............ ៤១

**១. ការអនុវត្តដីការបស់តុលាការ** ............ ៤១

១.១. ដីការសន្និដ្ឋានរឿងឲ្យស៊ើបសួរ ............ ៤២

១.២. ដីកាបង្គាប់ឲ្យចាប់ខ្លួន ............ ៤២

១.៣. ដីកាបង្គាប់ឲ្យឃុំខ្លួន ............ ៤២

**២. ស្នើសុំឲ្យបំពេញកិច្ច** ............ ៤៣

**៣. ស្នើសុំឲ្យដោះលែង** ............ ៤៣

**៤. ស្នើសុំឲ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ............ ៤៤

**៥. ការប្រគល់វត្ថុចាប់យក** ........ ៤៤
**៦. ការឆែកឆេរ និងការធ្វើកោសលវិច័យ** ........ ៤៥
**៧. ម៉្លឹងមោឃភាព និងម៉្លឹងមោឃកម្ម** ........ ៤៥
**៨. ការធ្វើសេចក្តីសន្និដ្ឋានស្ថាពរ** ........ ៤៦
**ផ្នែកទី៣៖ នីតិវិធីជំនុំជម្រះ** ........ ៤៦
**១. កោះហៅ** ........ ៤៦
១.១. កោះហៅជនជាប់ចោទ ........ ៤៦
១.២. កោះហៅដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ........ ៤៧
១.៣. កោះហៅអ្នកពាក់ព័ន្ធ ........ ៤៧
**២. អញ្ជើញមេធាវី** ........ ៤៨
**៣. ការដេញដោល** ........ ៤៨
**៤. ធ្វើសេចក្តីសន្និដ្ឋាន** ........ ៤៨
**ផ្នែកទី៤៖ នីតិវិធីដោយឡែក** ........ ៤៨
**១. អធិការកិច្ចពន្ធធនាគារ** ........ ៤៨
**២. ការដោះលែងដោយមានលក្ខខណ្ឌ** ........ ៤៩
**៣. ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ** ........ ៤៩
**សេចក្តីសន្និដ្ឋាន** ........ ៥១
**អនុសាសន៍** ........ ៥៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលបែងចែកអំណាចជាបីដាច់ដោយឡែកពីគ្នា គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ សាលាជម្រះក្តីនៅកម្ពុជាមាន២លំដាប់ថ្នាក់ គឺ តុលាការជាន់ទាប និងតុលាការជាន់ខ្ពស់ ក្នុងនោះផងដែរ ក៏មានស្ថាប័នអយ្យការអមតុលាការគ្រប់ជាន់ថ្នាក់ ។

ស្ថាប័នអយ្យការអមតុលាការជាន់ខ្ពស់ មានដូចជា មហាអយ្យការអមសាលាឧទ្ធរណ៍ និងមហាអយ្យការអមតុលាការកំពូល ។ រីឯស្ថាប័នអយ្យការអមតុលាការជាន់ទាប មានដូចជា អយ្យការអមសាលាដំបូងរាជធានី-ខេត្ត និងអយ្យការអមតុលាការយោធា ។ ក្នុងនោះផងដែរ ព្រះរាជអាជ្ញា គឺជាតួអង្គយ៉ាងសំខាន់ នៅក្នុងសង្គមកម្ពុជា ក្នុងការពិនិត្យ និងស្វែងរកនូវរាល់អត្ថិភាពនៃបទល្មើសទាំងឡាយ ក្នុងទស្សនៈវិស័យ និងគោលបំណងបម្រើផលប្រយោជន៍សាធារណៈ ។ លើសពីនេះទៅទៀត អយ្យការក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ តាមរយៈការធ្វើឲ្យរឿងក្តីព្រហ្មទណ្ឌមានចលនា ស្វែករកភស្តុតាងដាក់បន្ទុក សម្រាលបន្ទុក រហូតដល់ដំណើរការសវនាការ ឈានដល់ការចេញសេចក្តីសម្រេចពីតុលាការ និងការអនុវត្តសេចក្តីសម្រេចរបស់តុលាការ ។ ការអនុវត្តមុខងារជាព្រះរាជអាជ្ញា មិនត្រឹមតែបញ្ឈប់ការកើតមាននូវបទល្មើសក្នុងសង្គម និងជាគូក្តីដើមរបស់តុលាការក្នុងរឿងព្រហ្មទណ្ឌប៉ុណ្ណោះទេ ព្រះរាជអាជ្ញាក៏មានអំណាចសន្តោសយ៉ាងពិសេស ដោយអាចសម្រេចតម្កល់រឿងក្តីទុលឥតចាត់ការ ឬសម្រេចឲ្យជនជាប់ចោទណាម្នាក់អាចស្ថិតនៅក្រៅឃុំជាបណ្តោះអាសន្នផងដែរ ។

ដោយមើលឃើញអំពីសារៈសំខាន់នៃសិទ្ធិ អំណាច តួនាទី មុខងាររបស់ស្ថាប័នអយ្យការក្នុងវិស័យយុត្តិធម៌ ទើបយើងសម្រេចចិត្តលើកយកប្រធានមួយគឺ តួនាទី និងភារកិច្ចអយ្យការ ដើម្បីធ្វើការសិក្សាស្វែងយល់ និងបកស្រាយចងក្រងជាឯកសារដែលមានខ្លឹមសារដូចតទៅ ៖

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែអង្គអយ្យការ គឺជាតួអង្គដែលសំខាន់ ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលធានាដល់សន្តិសុខស្ថេរភាពសង្គម ជាពិសេសសិទ្ធិមនុស្ស ដូចនេះហើយ វាពិតជាមានសារៈសំខាន់ណាស់ នៅក្នុងការអនុវត្តកាតព្វកិច្ចមុខងារ ជាពិសេសតួនាទី និងភារកិច្ចដែលបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដោយហេតុនេះហើយទើបយើងមានបំណងស្វែករកឲ្យឃើញនូវចំណោទបញ្ហាដូចជា ៖

- តើអង្គការអយ្យការ និងព្រះរាជអាជ្ញាគឺជាអ្វី?
- តើព្រះរាជអាជ្ញាមានតួនាទី និងភារកិច្ចអ្វីខ្លះ?
- តើការអនុវត្ត តួនាទី និងសិទ្ធិអំណាចអយ្យការ មានលក្ខណៈដូចម្តេចខ្លះ?

- តើអង្គការអយ្យការ មានទំនាក់ទំនងយ៉ាងណាទៅលើបញ្ហាសំណុំរឿងព្រហ្មទណ្ឌ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងកិច្ចការស្រាវជ្រាវនេះ ក្រុមរបស់យើងខ្ញុំមានគោលបំណងសំខាន់ៗដូចជា ៖

- សិក្សាស្វែងយល់ពីការវិវត្តអង្គការមួយនេះនៅប្រទេសកម្ពុជា
    - សិក្សាស្វែងយល់អំពីអំណាច តួនាទី ភារកិច្ច និងសារៈសំខាន់របស់ព្រះរាជអាជ្ញា
    - សិក្សាស្វែងយល់ពីការអនុវត្តមុខងារផ្ទាល់របស់ព្រះរាជអាជ្ញា ។

## ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រធានបទមួយនេះ ក្រុមយើងខ្ញុំធ្វើការស្រាវជ្រាវ បែបពិពណ៌នា ដោយធ្វើការសិក្សាស្រាវជ្រាវ និងអង្កេតពី ៖

- ស្រាវជ្រាវទៅលើរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ
- ស្រាវជ្រាវទៅលើច្បាប់ជាតិនានា
- អង្កេតទៅលើសំណុំរឿងគំរូ
- អនុសាសន៍ និងការចង្អុលបង្ហាញផ្ទាល់ពីលោកសាស្ត្រាចារ្យ ខាត់ ធី
- អនុសាសន៍ និងការចង្អុលបង្ហាញផ្ទាល់ពី ឧត្តមសេនីយ៍ទោ ប៊ិន រត្ន័មុនី
- សិក្សាស្វែងយល់ ការអង្កេត និងពិភាក្សាជាមួយមិត្តរួមក្រុម
- ការវិភាគ និងសំយោគទៅលើប្រធានបទ

## ៥. កម្រិតនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺផ្តោតសំខាន់ទៅលើអង្គការអយ្យការ និងព្រះរាជអាជ្ញានៅក្នុងវិស័យយុត្តិធម៌កម្ពុជា ការកកើតស្ថាប័នអយ្យការ និងនីតិវិធីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ .........។

## ៦. សារៈប្រយោជន៍នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឲ្យក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងឲ្យកាន់តែស៊ីជម្រៅខ្លាំងទៅលើប្រធានបទ ស្តីពី តួនាទី និងភារកិច្ចអយ្យការ នៅក្នុងប្រទេសកម្ពុជា ដូចនេះ ការសិក្សាស្រាវជ្រាវទាំងអស់នេះ បានផ្តល់នូវសារៈប្រយោជន៍សំខាន់ៗដូចជា ៖

- ផ្តល់ចំណេះដឹងបន្ថែមដល់និស្សិតក្នុងការសិក្សាស្វែងយល់ទៅលើស្ថាប័នអយ្យការ
- ផ្តល់ជាឯកសារសម្រាប់សិក្សាស្រាវជ្រាវបន្ត និងរៀនសូត្របន្ថែមទៅលើសំណុំរឿងព្រហ្មទណ្ឌ
- ផ្តល់ជាគតិសម្រាប់កែលម្អនូវចំណុចខ្វះខាតក្នុងការអនុវត្តមុខងារ
- ផ្តល់ជាទ្រឹស្តី និងមតិយោបល់ ក្នុងគោលបំណងអភិវឌ្ឍវិស័យយុត្តិធម៌ និង ប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា

- ផ្តល់នូវការកែលម្អសម្រាប់និស្សិតជំនាន់ក្រោយ ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះចែកចេញជា ៣ ជំពូក ៖

- ជំពូកទី១ ស្ថាប័នអយ្យការ និងតំណាងអយ្យការ
- ជំពូកទី២ រចនាសម្ព័ន្ធស្ថាប័នអយ្យការ
- ជំពូកទី៣ នីតិវិធី និងចំណាត់ការរបស់អយ្យការក្នុងរឿងក្តីព្រហ្មទណ្ឌ ។

# ជំពូកទី១
# ស្ថាប័នអយ្យការ និង តំណាងអយ្យការ

## ផ្នែកទី១៖ ស្ថាប័នអយ្យការ

### ១.និយមន័យស្ថាប័នអយ្យការ

ស្ថាប័នអយ្យការ បង្កើតឡើងដោយពាក្យ ស្ថាប័ន + អយ្យការ ។

ពាក្យថា ស្ថាប័ន គឺសំដៅទៅលើសមាគមមួយដែលមានបុគ្គលមួយក្រុមធ្វើការរួមគ្នា និងរៀបចំឡើងក្នុងគោលដៅណាមួយដើម្បីនាំមកនូវសណ្ដាប់ធ្នាប់ល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ក្នុងការដឹកនាំ និងគ្រប់គ្រងជាតិរបស់ខ្លួនឲ្យមានការរីកចម្រើន ។

ពាក្យថា អយ្យការ បានមកពីពាក្យ អយ្យ ជាពាក្យបាលី ដែលមានន័យដូចគ្នាទៅនឹងពាក្យ អរិយ ដែលប្រែមកថា អ្នកមានត្រកូលខ្ពង់ខ្ពស់ អ្នកដែលត្រូវបានគេគោរពកោតខ្លាច រីឯអយ្យការវិញមានន័យថា ឈ្មោះច្បាប់មួយក្រុមមានគតិសម្រាប់ចោទប្រកាន់ព្រមទាំងវិនិច្ឆ័យការផែនដី[1]៖ ច្បាប់អយ្យការ ឬក្រុមអយ្យការ ។

និយមន័យតាមឬសគល់ដើមនៃពាក្យនេះ មានលក្ខណៈត្រូវគ្នាខ្លះដែរនឹងនិយមន័យគតិយុត្តិត្រង់សញ្ញាណដែលថា សម្រាប់ចោទប្រកាន់ និងអ្នកដែលត្រូវគេគោរពកោតខ្លាច ព្រោះវាអាចទាក់ទងនឹងអំណាចរបស់អយ្យការក្នុងការចោទប្រកាន់ប្រឆាំងបទល្មើស ប៉ុន្តែអយ្យការគ្មានអំណាចវិនិច្ឆ័យសេចក្ដីចេញជាសាលក្រមឡើយ ។

និយមន័យអយ្យការ មិនត្រូវបានកំណត់ច្បាស់លាស់ដោយវិធានគតិយុត្តណាមួយឡើយ ប៉ុន្តែគេអាចឲ្យនិយមន័យអយ្យការថា ជាអង្គការ ឬស្ថាប័នដែលតំណាងឲ្យផលប្រយោជន៍ទូទៅ ដើម្បីធ្វើបណ្ដឹងអាជ្ញា គឺធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងទាមទារឲ្យតុលាការអនុវត្តច្បាប់ ។

ជារួមមកវិញ ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋដែលបង្កើតឡើងសម្រាប់ដំណើរការបណ្ដឹងសាធារណៈ ឬបណ្ដឹងព្រហ្មទណ្ឌ ដើម្បីនាំមកនូវសណ្ដាប់ធ្នាប់ល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងជាតិរបស់ខ្លួនឲ្យមានការរីកចម្រើន ។ ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដ៏សំខាន់ដែលស្ថិតនៅអមសាលាក្ដីគ្រប់ជាន់ថ្នាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ នៅក្នុងនោះផងដែរ ព្រះរាជអាជ្ញា គឺជាបុគ្គលដ៏សំខាន់ក្នុងការបម្រើការងារឲ្យបានសម្រេចនូវបេសកកម្មរបស់ស្ថាប័ននេះ ។ ស្ថាប័នអយ្យការ គឺជាអ្នកធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ និងជាអ្នកសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់មិនតែប៉ុណ្ណោះ ស្ថាប័នអយ្យការជាអ្នកធានារ៉ាប់រងលើការអនុវត្តសេចក្ដីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងជាអ្នកផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួនផងដែរ ។ ម្យ៉ាងវិញទៀត ចៅក្រមអយ្យការមានសិទ្ធិក្នុងការកេណ្ឌកងកម្លាំងសមត្ថកិច្ចសាធារណៈដោយផ្ទាល់ ដើម្បីជាជំនួយ

[1] វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ហើយចៅក្រមអយ្យការចាំបាច់ត្រូវតែមានវត្តមានក្នុងសវនាការរឿងក្តីព្រហ្មទណ្ឌ ។ យោងតាមមាត្រា១៣១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## ២.ប្រវត្តិនៃការកកើតស្ថាប័នអយ្យការ

ស្ថាប័នអយ្យការនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៣៧ (ជំនាន់អាណានិគមនិយមបារាំង) ដើម្បីធានានូវសុវត្ថិភាពសារធារណៈ និងដំណើរការប្រព្រឹត្តទៅនៃក្រមព្រហ្មទណ្ឌ ក្នុងការចោទប្រកាន់ចំពោះបុគ្គលដែលបានប្រព្រឹត្តផ្ទុយពីក្រមព្រហ្មទណ្ឌ ។ ដោយសារតែព្រះរាជាណាចក្រកម្ពុជា ទទួលរងនូវសង្គ្រាមជិត ៤ទសវត្ស ដែលធ្វើឲ្យប្រទេសកម្ពុជាយើងឆ្លងកាត់នូវរបបនៃការដឹកនាំជាច្រើន ដូចនេះ ស្ថាប័នអយ្យការនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងក៏ត្រូវបានផ្លាស់ប្តូរឲ្យសមស្របទៅតាមរបបទាំងអស់នោះផងដែរ ។

### ២.១ ការកកើតស្ថាប័នអយ្យការក្រោមអំណាចបារាំង

ប្រទេសកម្ពុជាបានចុះសន្ធិសញ្ញា ដាក់ឲ្យស្ថិតក្រោមអាណាព្យាបាលរបស់សាធារណរដ្ឋបារាំងនៅក្នុងឆ្នាំ១៨៨៤ ដែលធ្វើឲ្យការគ្រប់គ្រងរដ្ឋមួយនេះបានផ្លាស់ប្តូរទៅតាមប្រព័ន្ធយុត្តាធិការបារាំង ។ ស្ថាប័នអយ្យការដំបូងបង្កើតឡើងក្នុងជំនាន់អាណានិយមបារាំង ដែលជាគំនិតផ្តួចផ្តើមរបស់បារាំង ដើម្បីធានាឲ្យបាននូវស្ថេរភាពសង្គម និងនយោបាយ ។

### ២.២ ការកកើតស្ថាប័នអយ្យការដំបូងនៅកម្ពុជា

#### ២.១.១ ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៣៧-១៩៧០

ស្ថាប័នអយ្យការ ត្រូវបានបង្កើតឡើងដំបូងបង្អស់នៅឆ្នាំ១៩៣៧ ដោយការបញ្ចូលដំណែងនេះនៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ (ដែលគេហៅថា ក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងសម័យបច្ចុប្បន្ន ) ។ យោងទៅតាមក្រមនេះនៅអមសាលាដំបូងនីមួយៗមាន ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ហើយនៅអយ្យការជាន់ខ្ពស់មាន ព្រះរាជបម្រើ និងភូឈួយព្រះរាជបម្រើ ។ នៅពេលនោះតំណែងរបស់ព្រះរាជអាជ្ញាមិនទាន់មាននៅគ្រប់សាលាដំបូងគ្រប់ខេត្តនោះទេ គឺមានតែនៅភ្នំពេញប៉ុណ្ណោះ ។ ដោយសារតែមានការខ្វះខាតថវិការគេបានជ្រើសរើសប្រធានសាលាដំបូងឲ្យដើរតួនាទីពីរ គឺព្រះរាជអាជ្ញាអមសាលាដំបូងផង និងជាចៅក្រមជំនុំជម្រះផង ។ តួនាទីព្រះរាជអាជ្ញានេះមកជំនួស តួនាទីរបស់ចៅក្រមស៊ើបសួរ ឬសភាចារបុរស ដែលដើមឡើយជាអ្នកបង្ករសំណុំរឿងចោទប្រកាន់ទៅសាលាក្រុមចោទ (ដែលជាសាខាមួយរបស់សាលាឧទ្ធរណ៍ដែលពិនិត្យរឿងដដែលប្តឹងជំទាស់ នឹងដីការបស់សុភាចារបុរស) ។

ចំណែកនៅសាលាវិនិច្ឆ័យធិបតី (សមមូលនឹងតុលាការកំពូលសព្វថ្ងៃ) វិញ ពុំមានព្រះរាជអាជ្ញាអមនោះទេ ។ ប៉ុន្តែនៅសម័យកាលក្រោយមកទៀត តំណែងអគ្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យធិបតីត្រូវបានឃើញ

មាននៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈយុត្តាធិការ ចៅក្រម និងក្រឡាបញ្ជីខាងផ្នែកតុលាការចុះថ្ងៃទី០៩ មីនា ឆ្នាំ១៩៥៤[2] ។ តាមច្បាប់លក្ខន្តិកៈនេះ អគ្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យធិបតី គ្មានអំណាចលើសមាជិកនៃក្រសួងអយ្យការទេ (មាត្រា៩)[3] ។

ដំណើរការនៃការគ្រប់គ្រងរបស់ស្ថាប័នអយ្យការនៅក្នុងសម័យនោះបានបន្តនិរន្តភាពរបស់ខ្លួនរហូតដល់ចុងឆ្នាំ១៩៦៩ មុនពេលដែលការធ្វើរដ្ឋប្រហារនៅឆ្នាំ១៩៧០ បានកើតឡើង ។

### ២.១.២ ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៧០-១៩៧៥

ប្រទេសកម្ពុជាបានប្តូរពីរបបសង្គមរាស្ត្រនិយម ទៅជាសម័យសាធារណរដ្ឋខ្មែរ នៅក្នុងឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥ ប្រព័ន្ធច្បាប់នៅក្នុងសម័យកាលនេះ គឺមិនបានផ្លាស់ប្តូរអ្វីធំដុំនោះឡើយ ។

នៅក្នុងសម័យកាលនេះ ព្រះរាជអាជ្ញា មានឈ្មោះថា រដ្ឋអាជ្ញា ។ រដ្ឋអាជ្ញា គឺត្រូវបានដាក់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទាំងការងារ និងការអនុវត្តចំពោះទណ្ឌកម្មវិន័យ[4]។ ចំនួនរដ្ឋអាជ្ញានៅក្នុងសម័យកាលនេះដែលសល់បន្តពីសម័យមុនមកមានចំនួន ៣៨នាក់ ក្នុងនោះមានស្ត្រីម្នាក់ជាភរិយារបស់លោក អ៊ឹង ប៊ឹង ។ រដ្ឋអាជ្ញាពីរនាក់ក្នុងចំណោមនោះ មានតំណែងនៅក្នុងក្រសួងយុត្តិធម៌ ។ ចំណែកឯចៅក្រមវិញមានចំនួន ៩២នាក់ ដោយមិនមានស្ត្រីទេ (យោងតាមក្រឹត្យលេខ ១៤២/៧៣/បសខ ចុះថ្ងៃទី០១ មីនា ១៩៧៣) ។

### ២.១.៣ ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩

សម័យកាលនេះជាសម័យកម្ពុជាប្រជាធិបតេយ្យ ដែលប្រទេសកម្ពុជាមានគុកសម្រាប់ដាក់មនុស្សប៉ុន្តែគ្មានប្រព័ន្ធតុលាការអ្វីទាំងអស់ ។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានបង្កើតរដ្ឋធម្មនុញ្ញមួយ ។ របបប្រជាធិបតេយ្យបានបង្កើតតុលាការតែមួយមានរចនាសម្ព័ន្ធមិនច្បាស់លាស់ដែលត្រូវបានគេហៅថា តុលាការប្រជាជន[5] ។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានចរឹកសកម្មភាពល្មើសមានពីរប្រភេទ គឺបទល្មើសប្រឆាំង និងបំផ្លិចបំផ្លាញរដ្ឋ ដែលត្រូវមានទោសធ្ងន់ និងបទល្មើសផ្សេងទៀតគ្រាន់តែទទួលការអប់រំប៉ុណ្ណោះ[6] ។

---

[2] សៀវភៅស្តីពីអយ្យការ៖ ប្រវត្តិ និងការសិក្សាប្រៀបធៀបឆ្នាំ ២០០៦ របស់លោក កុយ នាម និងលោក ឡុង បញ្ញាវុធ

[3] មាត្រា ៩ ជំពូក៧ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ១៩៦៧

[4] រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ ១៩៧២

[5] មាត្រា ៩ ជំពូក៧ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ១៩៦៧

[6] មាត្រា ១ ជំពូក១ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ១៩៨១

### ២.១.៤ ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៧៩-១៩៩១

បន្ទាប់ពីការដួលរលំនៅរបបខ្មែរក្រហម ឬរបបកម្ពុជាប្រជាធិបតេយ្យ ដែលជារបបវាលពិឃាត ប្រទេសកម្ពុជាបានប្តូរឈ្មោះទៅជារបបសាធារណរដ្ឋប្រជាមានិតកម្ពុជ[7] ។ ចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ជារយៈពេលដែលប្រទេសកម្ពុជាបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជំនាញការវៀតណាមក្នុងការផ្តល់គំនិតយោបល់ផ្នែកច្បាប់ ។ នៅពេលនោះ រដ្ឋអាជ្ញាអមតុលាការខេត្ត-ក្រុង ត្រូវបានជ្រើសរើសដោយគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង រួចធ្វើការស្នើសុំយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ក្រោយពីទទួលបានការយល់ព្រមពីរដ្ឋមន្ត្រីហើយ រដ្ឋអាជ្ញានោះនឹងត្រូវបានតែងតាំងដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ។ ចំណែកឯរដ្ឋអាជ្ញារងវិញ ការតែងតាំងមានលក្ខណៈងាយស្រួលជាងរដ្ឋអាជ្ញា ដោយត្រូវបានជ្រើសរើសពីគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ហើយស្នើសុំយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីទទួលបានការយល់ព្រម ហើយរដ្ឋអាជ្ញារងនោះ ត្រូវបានតែងតាំងដោយគណៈកម្មាធិការតែម្តង ។

នៅក្នុងតុលាការថ្នាក់ខេត្ត-ក្រុងនីមួយៗ ត្រូវមានរដ្ឋអាជ្ញាម្នាក់ និងរដ្ឋអាជ្ញារងម្នាក់ ឬពីរនាក់ ។ អំឡុងពេលនោះ ពុំទាន់មានសាលាឧទ្ធរណ៍ទេ ប៉ុន្តែក្រសួងយុត្តិធម៌មានភារកិច្ចទទួល និងពិនិត្យមើលបណ្តឹងឧទ្ធរណ៍នេះ ។ លើសពីនេះទៅទៀត តុលាការខេត្ត-ក្រុង ជាតុលាការតែមួយគត់ដែលសម្រេចសេចក្តីចុងក្រោយ ។

### ២.១.៥ ស្ថាប័នអយ្យការនៅចន្លោះឆ្នាំ ១៩៩១-បច្ចុប្បន្ន

ក្រោយពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសដើម្បីបញ្ចប់សង្គ្រាម ឆ្នាំ១៩៩១ មក ប្រទេសកម្ពុជាបានស្ថិតនៅក្នុងសម័យអន្តរកាលមួយរយៈ ដែលកំឡុងពេលនោះត្រូវបានគ្រប់គ្រងដោយអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ ហៅកាត់ថា អ៊ុន តាក់ (UNTAC)[8] ។ ក្នុងរយៈកាលនោះអាជ្ញាធរបណ្តោះអាសន្នរបស់អ.ស.ប បានបង្កើតនូវបញ្ញតិមួយស្តីពី បទបញ្ញាត្តិស្តីពី ប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅក្នុងរយៈកាលនោះ ។ តាមរយៈបញ្ញត្តិនេះ គេឃើញមានការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៃសាលាជម្រះក្តីមានពីរថ្នាក់ គឺតុលាការជាន់ទាប និងតុលាការជាន់ខ្ពស់ ។ ហើយជានិច្ចកាលនៅគ្រប់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ បទបញ្ញាត្តិនេះក៏ចែងពីស្ថាប័នអយ្យការ គឺត្រូវនៅអមសាលាជម្រះនោះផងដែរ [9] ។ ចំពោះមន្ត្រីតុលាការនៃរបបចាស់ (របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរបបរដ្ឋកម្ពុជា) មិនត្រូវបានដកហូត និងបញ្ចប់មុខងារនោះឡើយ ពោលគឺគ្រប់មន្ត្រីនៅក្នុងរដ្ឋការចាស់ត្រូវបានអនុញ្ញាតឲ្យបំពេញការងាររបស់ខ្លួនតាមធម្មតា ។

---

[7] សៀវភៅស្តីពីអយ្យការ៖ ប្រវត្តិ និងការសិក្សាប្រៀបធៀបឆ្នាំ ២០០៦ របស់លោក កុយ នាម និងលោក ឡុង បញ្ញាវុធ
[8] UNTAC=UNITED NATIOS TRANSITIONAL AUTHORITHY IN CAMBODIA
[9] មាត្រា ជំពូក នៃរដ្ឋធម្មនុញ្ញរដ្ឋកម្ពុជា ឆ្នាំ១៩៨៩

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីដែលទំព័រប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាបានកំណត់ជ្រើសយកប្រព័ន្ធគ្រប់គ្រងរដ្ឋ តាមរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។ ដែលតាមរយៈប្រព័ន្ធគ្រប់គ្រងនេះត្រូវបានកែប្រែឡើងវិញនូវ រដ្ឋអាជ្ញា មកជាព្រះរាជអាជ្ញាវិញ ។ តាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នេះបានប្រគល់នូវអំណាចផ្តាច់មុខទៅលើស្ថាប័នអយ្យការតែមួយគត់ក្នុងការធ្វើបណ្តឹងព្រហ្មទណ្ឌផងដែរ[10]។ តែបើទោះជាយ៉ាងនេះក្តីបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌនៅតែរក្សាសុពលភាពក្នុងការអនុវត្តនៅដដែល ។

នៅក្នុងឆ្នាំ១៩៩៤ ដោយមានការកើនឡើងនូវសំណុំរឿងចាស់លំដាប់ ក្រសួងយុត្តិធម៌បានសម្រេចរៀបចំជ្រើសរើសនូវចៅក្រម និងព្រះរាជអាជ្ញាដើម្បីដោះស្រាយនូវបញ្ហាដែលកំពុងតែកើតមាននេះ ។ ជាលទ្ធផលក្រសួងបានជ្រើសរើសបេក្ខជន (សិស្សចៅក្រម និងព្រះរាជអាជ្ញា) បានចំនួន ៤២រូប ។ ទន្ទឹមនឹងនេះផងដែរនៅក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានបង្កើតឲ្យមាននូវសាលាភូមិន្ទចៅក្រម[11] និងសាលាភូមិន្ទក្រឡាបញ្ជី[12] និងក្រោយមកទៀតនៅឆ្នាំ២០០៨ បង្កើតឲ្យមានសាលាភូមិន្ទអាជ្ញាសាលា[13] និងសាលាភូមិន្ទអាជ្ញាសាការី[14] ក្នុងគោលដៅបណ្តុះបណ្តាលនូវសិស្ស និស្សិត ដែលបានប្រឡងជាប់ឲ្យក្លាយទៅជា អ្នកវិជ្ជាជីវៈប្រកបដោយគុណភាពដែលស្ថិតក្រោមការគ្រប់គ្រងរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលក្រោយមកត្រូវបានផ្លាស់ប្តូរចំណុះឲ្យក្រសួងយុត្តិធម៌វិញ ។

នៅអំឡុងឆ្នាំ២០០៧ កម្ពុជាបានសម្រេចនូវលទ្ធផលក្នុងការតាក់តែងក្រមនីតិវិធីព្រហ្មទណ្ឌដែលជាបទបញ្ញត្តិថ្មី ដែលចែងពីតួនាទី ភារកិច្ចរបស់ចៅក្រម និងព្រះរាជអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌ ។ ក្នុងក្រមនេះបានចែងពីតួនាទី គោលការណ៍ និងកាតព្វកិច្ចចម្បងសំខាន់ៗរបស់ស្ថាប័នអយ្យការនៅគ្រប់ជាន់ថ្នាក់របស់សាលជម្រះក្តី ។

បន្ថែមពីនេះច្បាប់ថ្មីមួយទៀតក៏បានចែងបន្ថែមនូវការគ្រប់គ្រង ទៅលើចៅក្រម និងព្រះរាជអាជ្ញាដើម្បីធានានូវគោលឯករាជ្យភាព និងដើម្បីធានាបាននូវគុណភាពខាងផ្នែកវិជ្ជាជីវៈ និងក្រមសីលធម៌ ជាអាទិ៍ដែលត្រូវបានគេស្គាល់ថាច្បាប់គោលទាំងបី ដែលរួមមាន ៖ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈ

[10] មាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

[11] អនុក្រឹត្យលេខ៩ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០២ និងព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥

[12] ព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥

[13] អនុក្រឹត្យលេខ ១១៧ អនក្របក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨

[14] អនុក្រឹត្យលេខ ១១៨ អនក្របក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨

របស់ចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[15]។ តាមរយៈច្បាប់ទាំងអស់នេះ គេសង្កេតឃើញមានការរៀបចំ និងបែងចែកនៃសាលាជម្រះក្តី រៀបចំរចនា សម្ព័ន្ធសាលាជម្រះក្តី កំណត់ការជ្រើសរើស គោលការណ៍សំខាន់ៗ ឋានន្តរស័ក្តិ ការគ្រប់គ្រងលើទណ្ឌកម្មវិន័យ របស់ចៅក្រម ព្រះរាជអាជ្ញា និងស្ថាប័នដែលគ្រប់គ្រងលើការតែងតាំង ការដាក់ទណ្ឌកម្ម និងការដកហូតទៅលើចៅក្រម និងព្រះរាជអាជ្ញា ជាអាទិ៍ផងដែរ ។

## ៣. គោលការណ៍នៃស្ថាប័នអយ្យការ

ស្ថាប័នអយ្យការមានគោលការណ៍សំខាន់ៗពីរដូចជា ៖ គោលការណ៍គ្រឹះ និងគោលការណ៍នៃការចោទប្រកាន់ ។

### ៣.១ គោលការណ៍គ្រឹះរបស់អង្គការអយ្យការ

យោងទៅតាមច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា មាត្រា៧៥ បានកំណត់ពីគោលការណ៍សំខាន់ចំនួនបីដូចតទៅ ៖

#### ៣.១.១ គោលការណ៍ឯកភាព ឬ ឋានានុក្រម

ស្ថាប័នអយ្យការ គឺជាអង្គឯកភាពមួយដែលមានតួនាទីដឹកនាំ និងត្រួតពិនិត្យតាមដានលើគ្រប់ព្រះរាជអាជ្ញាទាំងអស់ក្នុងការបំពេញភារកិច្ចទៅតាមឋានានុក្រម ដោយមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជានាយឋានា-នុក្រមនៃអង្គការនេះ និងជាអ្នកដែលអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅកាន់អង្គការអយ្យការគ្រប់ជាន់ថ្នាក់ ។ ក្នុងនោះផងដែរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏ត្រូវមានសេនាធិការដែលជាអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ដើម្បីសម្របសម្រួលលើកិច្ចការទាំងនេះ ។ ម្យ៉ាងវិញទៀត ចំពោះអង្គការអយ្យការគ្រប់ជាន់ថ្នាក់ ត្រូវដឹកនាំ និងការទទួលខុសត្រូវរួម នៅក្រោមនាយឋានានុក្រមរបស់ខ្លួនរៀងៗខ្លួនផងដែរ ។

#### ៣.១.២ គោលការណ៍អវិភាគ

ស្ថាប័នអយ្យការ គឺជាអង្គអវិភាគ ដែលតម្រូវឲ្យព្រះរាជអាជ្ញា ត្រូវបំពេញមុខងារនៅស្ថាប័នអយ្យការអមសាលាជម្រះក្តីណាមួយដែលមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបានមានន័យថាតំណាងស្ថាប័នអយ្យការជាច្រើនរូប អាចធ្វើការងារពីររួមគ្នាបានក្នុងសំណុំរឿងតែមួយ ទៅតាមការចាត់តាំងរបស់នាយឋានានុក្រម[16]។

[15] ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

[16] មាត្រា៧៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

### ៣.១.៣ គោលការណ៍ឯករាជ្យ

ស្ថាប័នអយ្យការគឺជាស្ថាប័នឯករាជ្យ ដែលមិនស្ថិតក្រោមអំណាចនៃសាលាជម្រះក្តីណាមួយដែលខ្លួននៅអមនោះឡើយ ហើយក៏គ្មានអំណាចនៃស្ថាប័នណាមួយគ្រប់គ្រងលើកិច្ចការរបស់ព្រះរាជអាជ្ញាទេ ទោះបីជាក្នុងករណីអ្វីក៏ដោយ ។ ប៉ុន្តែសាលាជម្រះក្តីអាចលើកសំណើទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញា អំពីកំហុសរបស់ព្រះរាជអាជ្ញាបាន ។

ជារៀងរាល់ឆ្នាំ ព្រះរាជអាជ្ញាអមសាលាដំបូង ត្រូវធ្វើរបាយការណ៍អំពីបទល្មើស និងសកម្មភាពការងាររបស់ខ្លួនជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងចម្លងជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចដែនដី ។ ចំពោះអគ្គព្រះរាជអាជ្ញានៃស្ថាប័នមហាអយ្យការអមសាលាឧទ្ធរណ៍ ក៏ត្រូវធ្វើរបាយការណ៍អំពីបទល្មើស សកម្មភាពរបស់ខ្លួន និងសកម្មភាពរបស់អយ្យការអមសាលាដំបូងទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងចម្លងជូនអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ ចំណែកឯអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលក៏ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែរ ។

### ៣.១.៤ គោលការណ៍នៃការមិនទទួលខុសត្រូវ

ចៅក្រមអយ្យការបំពេញមុខងារជាសមូហភាព និងសម្រេចសេចក្តីតំណាងឲ្យស្ថាប័នអយ្យការទាំងមូលមិនមែនក្នុងនាមបុគ្គលនោះឡើយ ដូចនេះទើបចៅក្រមអយ្យការមិនទទួលខុសត្រូវចំពោះការសម្រេចចិត្តរបស់ខ្លួននោះទេ ។

នៅពេលព្រះរាជអាជ្ញាបានចោទប្រកាន់បុគ្គលណាម្នាក់ដើម្បីឲ្យស្ថាប័នយុត្តាធិការធ្វើការជំនុំជម្រះ ហើយបុគ្គលនៅត្រូវបានតុលាការប្រកាសថាគ្មានពិរុទ្ធភាព ឬសម្រេចឲ្យរួចផុតពីបទចោទព្រះរាជអាជ្ញាមិនត្រូវដាក់ឲ្យទទួលខុសត្រូវ ឬទទួលទណ្ឌកម្មអ្វីសោះឡើយ ។ ឧទាហរណ៍ ៖ សំណុំរឿងមួយដែលត្រូវបានព្រះរាជអាជ្ញាចោទប្រកាន់ពីបទល្មើស ប៉ុន្តែសំណុំរឿងនោះត្រូវបានតុលាការប្រកាសឲ្យរួចបទចោទទៅវិញ ។ ទោះបីជាគោលការណ៍នៃការមិនទទួលខុសត្រូវផ្តល់សិទ្ធិពិសេសដល់ចៅក្រមអយ្យការបែបនេះក៏ដោយ ក៏មិនមែនជាសេរីភាពគ្មានព្រំដែននោះទេ ពីព្រោះកំហុសបុគ្គលត្រូវតែទទួលខុសត្រូវស្មើគ្នាចំពោះមុខច្បាប់ ។ ដូច្នេះមុនធ្វើការចោទប្រកាន់ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែង គួរចោទ ឬមិនគួរចោទ ត្រូវសម្រេចដោយមនសិការ និងសម្បជញ្ញៈរបស់ខ្លួន ។

### ៣.១.៥ គោលការណ៍មិនអាចប្តឹងជំទាស់

តុលាការដែលមានតួនាទីស្វែងរកយុត្តិធម៌ឲ្យជនរងគ្រោះ មិនត្រូវមានភាពលំអៀងទៅលើភាគីណាមួយឡើយ ហើយបើភាគីណាយល់ឃើញថាសមាសភាពចៅក្រមជំនុំជម្រះមិនអាចរកយុត្តិធម៌ឲ្យខ្លួនបាន ភាគីនោះមានសិទ្ធិសុំផ្លាស់ប្តូរសមាសភាពជំនុំជម្រះនោះបានសមស្របតាមមូលហេតុដែលកំណត់ក្នុងច្បាប់ ។

គោលការណ៍នេះអាចអនុវត្តបានទៅលើថៅក្រមជំនុំជម្រះគ្រប់ប្រភេទរឿងក្ដី ប៉ុន្តែមិនអាចអនុវត្តបានគ្រប់កាលៈទេសៈទៅលើថៅក្រមអយ្យការឡើយ ជាពិសេសរឿងក្ដីព្រហ្មទណ្ឌ[17] ។ ឧទាហរណ៍ ជនរងគ្រោះម្នាក់បានដឹងថាជនល្មើសជាមួយនឹងព្រះរាជអាជ្ញារងដែលកាន់សំណុំរឿងរបស់ខ្លួនជាសាច់ញាតិ ឃើញបែបនេះគាត់មានការព្រួយបារម្ភពីការលំអៀងមកលើខ្លួនគាត់ពីសំណាកព្រះរាជអាជ្ញារង ដែលអាចរារាំងដល់ការផ្ដល់យុត្តិធម៌ដល់គាត់ ដូចនេះគាត់ចង់ស្នើសុំប្ដឹងជំទាស់ព្រះរាជអាជ្ញារងនោះមិនឲ្យកាន់សំណុំរឿងតទៅទៀត ។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិយ៉ាងច្បាស់ បណ្ដឹងជំទាស់អាចត្រូវទទួលបានពាក់ព័ន្ធតែថៅក្រមអាសនៈប៉ុណ្ណោះ ដូចនេះថៅក្រមអយ្យការមិនអាចត្រូវបានប្ដឹងជំទាស់ ឬដកហូតសមត្ថកិច្ចចេញពីសំណុំរឿងពីសំណាកភាគីបានឡើយ ។

## ៣.២ គោលការណ៍នៃការចោទប្រកាន់

នៅក្នុងប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌជាសាកល មានគោលការណ៍នៃការចោទប្រកាន់ចំនួន០២ធំៗគឺ (ក) គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និង (ខ) គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ។ អង្គការអយ្យការ ជាទូទៅគឺប្រើប្រាស់នូវគោលការណ៍ទាំងពីរនេះក្នុងការចោទប្ដឹង ។ ប៉ុន្តែការជ្រើសរើសនូវគោលការណ៍ណាមួយមកអនុវត្ត គឺអាស្រ័យលើស្ថានភាពនៃសង្គមជាក់ស្ដែង ។

### ៣.២.១ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់

គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ត្រូវបានយកមកប្រើប្រាស់នៅប្រទេសអាឡឺម៉ង់ និងច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់កម្ពុជា ។ ប្រសិនបើបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ព្រះរាជអាជ្ញាត្រូវតែធ្វើការប្ដឹងចោទប្រកាន់ដែលប្រៀបបាននឹងម៉ាស៊ីនយន្តដោយមិនពិចារណាថាជារឿងតូចតាច ឬមានការប៉ះពាល់សណ្ដាប់ធ្នាប់សង្គមតិចតួចអ្វីនោះទេ គឺឲ្យតែមានអង្គហេតុដែលជាបទល្មើសកើតឡើង ព្រះរាជអាជ្ញាត្រូវធ្វើការប្ដឹងចោទប្រកាន់ទាំងអស់ ពោលគឺព្រះរាជអាជ្ញាគ្មានសិទ្ធិតម្កល់រឿងទុកអត់ចាត់ការនោះទេ ។

គោលការណ៍នេះ បានផ្ដល់នូវផលវិជ្ជមានផងដែរ គឺគ្មានការរំលោភអំណាច ឬបំពានច្បាប់ក្នុងការសម្រេចតម្កល់រឿងទុកអត់ចាត់ការ ដើម្បីជាប្រយោជន៍ខ្លួននោះទេ មានន័យថា ព្រះរាជអាជ្ញាបានដើរតួជាអញ្ញាក្រឹត្យ និងឯករាជ្យ ដោយមិនរណបទៅនឹងស្ថាប័នណាមួយឡើយ ។ រីឯផលអវិជ្ជមានវិញគឺគោលការណ៍នេះមិនអាចផ្ដល់ប្រសិទ្ធិភាពគ្រប់គ្រាន់ក្នុងការស្វែងរកភស្តុតាងទេ តែបែរជាបណ្ដាលឲ្យមានការកកស្ទះសំណុំរឿង ដែលផ្ទុយទៅនឹងភាពឆាប់រហ័ស និងយុត្តិធម៌ក្នុងសង្គមទៅវិញ ។ ដោយសារតែមានមូលហេតុបែបនេះហើយ ទើបបានជានាំឲ្យមានគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ។

[17] មាត្រា៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងថា "បណ្ដឹងជំទាស់អាចត្រូវទទួលបានពាក់ព័ន្ធតែថៅក្រមអាសនៈប៉ុណ្ណោះ......"។

### ៣.២.២ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌបច្ចុប្បន្នរបស់កម្ពុជាយកមកប្រើប្រាស់សម្រាប់ឲ្យអង្គការអយ្យការធ្វើការពិចារណាមុននឹងធ្វើចំណាត់ការតាមនីតិវិធី ។ នៅក្នុងគោលការណ៍នេះ បានធ្វើឲ្យព្រះរាជអាជ្ញាក្លាយទៅជានិយ័តករសង្គមមួយយ៉ាងពិតប្រាកដ ដែលមានសិទ្ធិសម្រេចដោយធ្វើការថ្លឹងថ្លែងមុននឹងសម្រេចថា ចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ ។ គោលការណ៍នេះបានផ្តល់ផលវិជ្ជមានដែលផលអវិជ្ជមាននៃគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់នោះ គឺផ្តល់ប្រសិទ្ធិភាពគ្រប់គ្រាន់ក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកមុននឹងធ្វើការចោទប្រកាន់ពីបទល្មើសមួយៗ ។ ចំណែកឯចំណុចអវិជ្ជមាននៃគោលការណ៍នេះ គឺអាចមានស្ថានភាពនាំឲ្យមានការរំលោភអំណាច ឬបំពានច្បាប់ដោយសារតែការតម្កល់រឿងទុកឥតចាត់ការ ឬការយល់ខុសក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ប៉ុន្តែចំណុចអវិជ្ជមាននេះ អាចដោះស្រាយបានអាស្រ័យលើឆន្ទៈរបស់រដ្ឋ ពោលគឺច្បាប់បានបើកផ្លូវឲ្យអ្នកប្តឹងដែលមិនសុខចិត្តទៅនឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ធ្វើការប្តឹងតវ៉ាក្នុងរយៈពេល២ខែ គិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងអំពីការតម្កល់រឿងទុកឥតចាត់ការទៅអគ្គព្រះរាជអាជ្ញា ដើម្បីពិនិត្យអត្ថិភាព នៃបទល្មើសថ្មីម្តងទៀត[18] ។

## ផ្នែកទី២៖ តំណាងអយ្យការ

### ១. តំណាងអយ្យការ

តំណាងអយ្យការ គឺមានតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងយុត្តិធម៌ និងវិធានច្បាប់នានា ដែលទាក់ទងទៅនឹងការអនុវត្តទៅតាមការទទួលខុសត្រូវរបស់ខ្លួន ដូចនេះដើម្បីលើកស្ទួយនូវការគោរព និងប្រតិបត្តិការភាពយុត្តិធម៌នៅក្នុងវិជ្ជាជីវៈរបស់ខ្លួនតំណាងចាំបាច់ ត្រូវមានលក្ខណៈសម្បត្តិជំនាញច្បាស់លាស់នៅក្នុងការបំពេញមុខងាររបស់ខ្លួន ។ ដើម្បីបំពេញឲ្យបាននូវលក្ខណៈសម្បត្តិជំនាញនោះអ្នកដែលអាចធ្វើជាតំណាងអយ្យការបានលុះត្រាតែជាមនុស្សដែលមានការជ្រើសរើសពីការប្រឡងប្រជែងដ៏ត្រឹមត្រូវ មានការហ្វឹកហ្វឺនផ្នែកច្បាប់ និងជំនាញរបស់ខ្លួនមានការតែងតាំងច្បាស់លាស់ និងមាននូវការកំណត់ពីទណ្ឌកម្មប្រសិនបើបុគ្គលនោះប្រព្រឹត្តកំហុសក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ព្រះរាជអាជ្ញា ។

### ១.១ ការជ្រើសរើស

ដើម្បីក្លាយខ្លួនជាតំណាងអយ្យការបាន លុះត្រាតែត្រូវគោរពលក្ខខណ្ឌចំនួន២ ដែលក្នុងនោះមានលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌពិសេស ។

[18] មាត្រា ៤១ កថាខណ្ឌទី៤ និងទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**ក. លក្ខខណ្ឌទូទៅ**

ត្រូវបានអនុញ្ញាតឲ្យប្រលងជ្រើសរើសជាសិស្សចៅក្រម (ចៅក្រមអយ្យការ) ចំពោះបេក្ខជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

-ត្រូវមានសញ្ជាតិខ្មែរពីកំណើត

-មានអាយុ ៣៥ (សាមសិបប្រាំ) ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ៤០ (សែសិប) ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង

-ត្រូវមានសញ្ញាប័ត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

-មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

-ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន[19]

ការកំណត់ចំនួននៃការជ្រើសរើសសិស្សចៅក្រម ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[20] ។

**ខ. លក្ខខណ្ឌពិសេស**

ការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌចៅក្រម (អយ្យការ) អាចធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងពីក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជី ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងបានបំពេញវិជ្ជាជីវៈរបស់ខ្លួនយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ បេក្ខជនអាចចុះឈ្មោះចូលរួមប្រជែងតាមបញ្ញត្តិនៃវាក្យខណ្ឌទី១ខាងលើនេះបានប្រសិន បើបេក្ខជននោះ មានអាយុមិនលើសពី ៤៥ (សែសិបប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង[21] ។

បុគ្គលដែលមានប្រឡងជាប់ចូលជាសិស្សចៅក្រម (អយ្យការ) ទាំងពីរលក្ខខណ្ឌ ត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈដែលរៀបចំដោយក្រសួងយុត្តិធម៌ ។ ហើយការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[22] ។

[19] មាត្រា១៩ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[20] មាត្រា២០ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[21] មាត្រា២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[22] មាត្រា២០ និង មាត្រា២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

## ១.២ ការចុះកម្មសិក្សា និងតែងតាំងស៊ុបចំពោះព្រះរាជអាជ្ញា

បុគ្គលដែលអាចក្លាយជាព្រះរាជអាជ្ញាបានគឺត្រូវតែបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យ និងតែងតាំងដោយព្រះរាជក្រឹត ជាព្រះរាជអាជ្ញាកម្មសិក្សា ក្នុងឋានន្តរស័ក្តិជាព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ។ ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវធ្វើរយៈពេលកម្មសិក្សារយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃតែងតាំង ។ ការធ្វើកម្មសិក្សា និងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃក្រុមប្រឹក្សានៃអង្គចៅក្រ[23]។ ចំពោះការតែងតាំងព្រះរាជអាជ្ញាកម្មសិក្សា មានអានុភាពដល់ការរៀបចំប្រាក់បៀវត្ស និងការគិតអំពីអតីតភាពការងារ នៅកំឡុងពេលនៃកម្មសិក្សានេះដែរ គ្រប់សិស្សព្រះរាជអាជ្ញាកម្មសិក្សាទាំងអស់ត្រូវតែគោរពទៅតាមលក្ខខណ្ឌតឹងតែង ប្រសិនខកខានមិនបានចូលកម្មសិក្សាលើសពី៣០ថ្ងៃ នោះក្រសួងយុត្តិធម៌មិនអនុញ្ញាតឲ្យបន្តកម្មសិក្សានោះទៀតឡើយ ។ ប៉ុន្តែក្នុងករណីដែលមិនមានបញ្ហាជាមួយកម្មសិក្សានេះទេនោះនឹងត្រូវបានក្រសួងយុត្តិធម៌តាំងស៊ុបក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិជាអានុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតាំងស៊ុបក្នុងក្របខណ្ឌព្រះរាជអាជ្ញា តាមសំណើរបស់មន្ត្រីក្រសួងយុត្តិធម៌ ។ មួយវិញទៀតចំពោះព្រះរាជអាជ្ញាកម្មសិក្សាដែលមិនមានសម្បទាគ្រប់គ្រាន់ ឬ សុខភាពមិនគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ឬ មានការខុសឆ្គងពីការបម្រើការងារមិនពេញលេញអាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌបានគ្រប់ពេលវេលា ដែលរាល់ការលុបឈ្មោះនេះមានរយៈពេល៣ខែយ៉ាងយូរក្រោយពីបញ្ចប់កម្មសិក្សា ។

ជារួមក្នុងនាមខ្លួនដែលជាព្រះរាជអាជ្ញាកម្មសិក្សា ត្រូវតែជាឯកត្តជនដែលមានសេចក្តីសុចរិត និងមានសមត្ថភាព ព្រមទាំងការហ្វឹកហ្វឺន ការអប់រំ ត្រូវយល់ដឹងអំពីឧត្តមគតិ និងករណីយកិច្ចប្រកបដោយសីលធម៌នៃតួនាទីរបស់ខ្លួន ហើយក៏ត្រូវយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិឯកជន ។

## ១.៣ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ

ក្នុងនាមជាភ្នាក់ងារដ៏សំខាន់ក្នុងក្របខ័ណ្ឌប្រព័ន្ធយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវរក្សាខ្ជាប់គ្រប់ពេលវេលា នូវកិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួន ។ ដូចនេះ រដ្ឋត្រូវតែធានា ថាព្រះរាជអាជ្ញាមានលទ្ធភាពបំពេញមុខងារ ឬមិនមានលទ្ធភាពបំពេញទៅតាមវិជ្ជាជីវៈរបស់ខ្លួន [24] ។ ធនធានមនុស្សខាងវិស័យយុត្តិធម៌ទាំងនេះពិតជាសំខាន់ណាស់ដែលរដ្ឋត្រូវគិតគូរលើកកម្ពស់ និងយកចិត្តទុកដាក់ផ្នែកសម្ភារៈ និងស្មារតី ជាពិសេសលក្ខណៈសម្បត្តិ

[23] គោលការណ៍ណែនាំស្តីអំពីតួនាទីរបស់ព្រះរាជអាជ្ញា

[24] គោលការណ៍ណែនាំស្តីអំពីតួនាទីរបស់ព្រះរាជអាជ្ញា

ខាងវិជ្ជាជីវៈ សមត្ថភាព សេចក្ដីសុចរិត និងបទពិសោធន៍ប្រកបដោយគោលការណ៍អានាគតិ និងមិនលំអៀង ។

ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាព ស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ ។ លក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិតាមវេនជ្រើសរើស និងតាមវេនអតីតភាពត្រូវកំណត់ដោយព្រះរាជក្រឹត្យ[25] ។

ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់សិស្សព្រះរាជអាជ្ញាត្រូវផ្អែកលើមូលដ្ឋានជាអាទិ៍ ៖

-ការគោរពវិន័យការងារឲ្យបានត្រឹមត្រូវ

-ការសម្រេចភារកិច្ចបានល្អ

-កិរិយាមាយាទ និងសីលធម៌ល្អ មិនធ្វើឲ្យប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម

-ការឆ្លងកាត់វគ្គបណ្ដុះបណ្ដាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

ក្នុងរយៈពេលនៃការបំពេញការងារ ព្រះរាជអាជ្ញាដែលបានខិតខំសិក្សាបន្ថែម ហើយបានទទួលសញ្ញាប័ត្រក្រោយឧត្តមសិក្សា ត្រូវបានលើកទឹកចិត្តដោយធ្វើការដំឡើងថ្នាក់បន្ថែម១ (មួយ) ថ្នាក់ទៀត ។

ជារៀលរាល់ឆ្នាំនៅសប្ដាហ៍ទី១ នៃខែមករា ព្រះរាជអាជ្ញាម្នាក់ៗត្រូវទទួលនូវព្រឹត្តិបត្រឯកជនដែលព្រះរាជអាជ្ញានោះត្រូវបំពេញតាមចំណុចសំនួរទាំងឡាយ ។ រាល់ការដាក់ពិន្ទុត្រូវបានបែងចែកជាផ្នែកខុសៗគ្នាដែរ ៖

១. ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូង ត្រូវបានដាក់ពិន្ទុដោយព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។

២. ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៣. ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ត្រូវបានដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

៤. ព្រះរាជអាជ្ញាដែលបានផ្លាស់ឲ្យទៅបំពេញកិច្ចនៅស្ថាប័នផ្សេងៗ ត្រូវដាក់ពិន្ទុដោយប្រធានស្ថាប័ននោះ ។

គណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវរៀបចំតារាងទៅតាមជំនាន់ព្រះរាជអាជ្ញាដែលតំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងតាមលំដាប់ថ្នាក់នៅក្នុងតារាងចុះឈ្មោះ ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងផ្ដល់យោបល់ ។ អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរៀបចំតារាងឈ្មោះព្រះរាជអាជ្ញាដែលត្រូវឡើងថ្នាក់ និងឋានន្តរស័ក្តិទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីរៀបចំសេចក្ដីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ ។

---

[25] មាត្រា២៧ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

### ១.៤ ការតែងតាំង ផ្លាស់ប្តូរ ការផ្តាច់មុខងារ ការដាក់ឲ្យនៅក្រោមក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញា

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកសម្រេច និងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រទៅលើការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រោមក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឲ្យផ្តាច់ពីមុខងារ ឬដាក់ឲ្យនៅក្រៅក្របខណ្ឌព្រះរាជអាជ្ញាបានតាមរយៈការស្នើសុំរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន។

ក្នុងករណីចាំបាច់ដែលត្រូវទៅបំពេញការងារជាបណ្តោះអាសន្ន នៅក្នុងតំណែងមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រមព្រះរាជអាជ្ញាអាចសុំផ្តាច់ពីការងារ ។ ការអនុញ្ញាតឲ្យផ្តាច់ពីមុខងារនេះ ត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ។ ក្នុងរយៈពេលនៃការអនុញ្ញាតឲ្យផ្តាច់មុខងារព្រះរាជអាជ្ញានោះត្រូវបានទទួលប្រាក់បៀវត្ស ព្រមទាំងបានទទួលសិទ្ធិក្នុងការឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងសិទ្ធិក្នុងការចូលនិវត្តន៍របស់ខ្លួន ប៉ុន្តែមិនមានប្រាក់បំណាច់មុខងារ និងប្រាក់រង្វាន់ផ្សេងៗទៀតនោះទេ ។

ក្នុងករណីចាំបាច់ដែលត្រូវទៅបំពេញការងារជាបណ្តោះអាសន្ននៅក្នុងសហគ្រាសសាធារណៈ ឬនៅតាមអង្គការអន្តរជាតិ ព្រះរាជអាជ្ញាអាចសុំនៅក្រៅក្របខណ្ឌ ។ ការអនុញ្ញាតឲ្យនៅក្របខណ្ឌនេះត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន ។ ព្រះរាជអាជ្ញាដែលដាក់ឲ្យនៅក្រៅក្របខណ្ឌ ពុំមានសិទ្ធិទទួលប្រាក់បៀវត្ស ប្រាក់បំណាច់មុខការងារ និងប្រាក់បំណាច់ផ្សេងៗទៀត ។ ព្រះរាជអាជ្ញាអាចត្រូវបានផ្អាកពីមុខងារបណ្តោះអាសន្ន ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីដែលព្រះរាជអាជ្ញានោះដែលកំពុងជាប់នៅនីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យនៃអង្គចៅក្រម ។ ព្រះរាជអាជ្ញាត្រូវលុបឈ្មោះពីក្របខណ្ឌព្រះរាជអាជ្ញា ក្នុងករណីដែលព្រះរាជអាជ្ញានោះទទួលបានទណ្ឌកម្មវិន័យថ្នាក់ទី២ (ពីរ) ឬនៅពេលដែលព្រះរាជអាជ្ញានោះ បានបោះបង់ការងារ ឬអវត្តមានលើសពី៣០ (សាមសិប) ថ្ងៃ ដោយអនុវត្តតាមមាត្រា ៥២ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឬដោយសាមីខ្លួនសុំលាឈប់ជាស្ថាពរ ។

ការលាឈប់របស់ព្រះរាជអាជ្ញាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន ។ ពាក្យសុំនេះត្រូវដាក់ជូនមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងចាត់ការតាមនីតិវិធី ។

ក្នុងករណីចាំបាច់ ដោយមូលហេតុផ្ទាល់ខ្លួន គ្រួសារ ឬវិសមិតភាព ព្រះរាជអាជ្ញាអាចស្នើសុំនៅទំនេរគ្មានប្រាក់បៀវត្ស អាចធ្វើឡើងក្នុងរយៈពេល ០១ឆ្នាំ ឬម្តង ២ឆ្នាំ ។ ការអនុញ្ញាតឲ្យនៅទំនេរនេះអនុញ្ញាតឲ្យធ្វើឡើងតែ ០២ (ពីរ) ដងគត់ ហើយរយៈពេលសរុបនៃការអនុញ្ញាតនេះមិនត្រូវឲ្យលើសពី៤ឆ្នាំឡើយ ដោយព្រះរាជអាជ្ញានោះមិនអាចទទួលបានប្រាក់បៀវត្សតាមការស្នើសុំរបស់សាមីខ្លួន លុះត្រាតែព្រះរាជអាជ្ញានោះ បានបំពេញមុខងារ

ក្នុងក្របខណ្ឌព្រះរាជអាជ្ញាបានយ៉ាងតិចបួនឆ្នាំសិន ដោយមិនគិតពីព្រះរាជអាជ្ញាដែលត្រូវទទួលទណ្ឌកម្មជាវិន័យថ្នាក់ទី២ (ពីរ) ។ រាល់ពាក្យស្នើសុំត្រូវមានការទាក់ទងទៅក្រសួងយុត្តិធម៌ ។

ទោះយ៉ាងណា ប្រសិនបើព្រះរាជអាជ្ញារូបនោះមានបំណងចង់បន្តធ្វើការវិញនោះ ត្រូវដាក់ពាក្យសុំមុន រយៈពេលដែលគាត់ឈប់ទំនេរនោះ ។ ដោយឡែកប្រសិនបើមិនមានការដាក់ពាក្យសុំបន្តទេនោះ ត្រូវចាត់ទុកថាត្រូវបានបោះបង់ការងារ ហើយលុបឈ្មោះចេញពីក្របខណ្ឌចាប់ពីថ្ងៃនោះតទៅ ។

ចំពោះព្រះរាជអាជ្ញាកម្មសិក្សា ដើម្បីឲ្យមានសុក្រឹតភាពក្នុងវិជ្ជាជីវៈត្រូវចាត់ទុកដូចជាព្រះរាជអាជ្ញាដែលកំពុងបំពេញមុខងារ ។

ចំពោះព្រះរាជអាជ្ញាអមតុលាការកំពូល មានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញាខ្ពស់បំផុត ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទាំងអស់មានឋានន្តរសក្ត័ជាឧត្តមព្រះរាជអាជ្ញា ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទាំងអស់មានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា ឬវរៈព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាអមសាលាដំបូងមានឋានន្តរស័ក្តិជាវរៈព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញារងអមសាលាដំបូងទាំងអស់មានឋានន្តរស័ក្តិជាវរៈព្រះរាជអាជ្ញា ឬអនុព្រះរាជអាជ្ញាឡើងទៅ ។

### ១.៥ កាតព្វកិច្ចទូទៅរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាត្រូវមានកាតព្វកិច្ចទទួលខុសត្រូវលើកិច្ចការរបស់ខ្លួន យ៉ាងម៉ឺងម៉ាត់ប្រកបដោយក្រមសីលធម៌ខ្ពស់ ។

នៅក្នុងជីវភាពរស់នៅផ្ទាល់ខ្លួនព្រះរាជអាជ្ញាមិនត្រូវប្រព្រឹត្តអំពើណាដែលនាំឲ្យខូចកិត្តិយសសេចក្តីថ្លៃថ្នូរ ឬប៉ះពាល់ដល់អង្គការអយ្យការទេ ការបំពានក្រមសីលធម៌ ឬផ្នែកវិន័យ ត្រូវទទួលរងនូវទណ្ឌកម្មតាមស្ថានទម្ងន់នៃកំហុស ។ មុនពេលអយ្យការនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទាំងអស់ត្រូវតែសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មុនពេលផ្សាយ ឬឲ្យផ្សាយទៅតាមគ្រប់មធ្យោបាយទាំងអស់គ្រប់អត្ថបទ ឬសំណេរ និងមតិផ្សេងៗផងដែរ ។ ប៉ុន្តែចំពោះការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈមិនមានការហាមឃាត់ឡើយ បើយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌដោយឡែកបើមិនគោរពទៅតាមបញ្ញត្តិនេះទេនឹងប្រឈមទៅនឹងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ [26]។

ដូច្នេះព្រះរាជអាជ្ញាទាំងអស់មិនអាចបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើនោះទេ ព្រោះនេះជាកត្តាមួយដែលធ្វើឲ្យនីតិវិធីមានការយឺតយ៉ាវ ឬកកស្ទះផងដែរ ។ ហើយការឈប់សម្រាកនេះក៏ត្រូវបានកំណត់ផងដែរ គឺមិនអនុញ្ញាតឲ្យឈប់ដោយពុំមានមូលហេតុលើសពី១៥ថ្ងៃទេ ក្នុងករណី

[26] មាត្រា៩៦ នៃច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

បំពាននៅចំណុចនេះនឹងប្រឈមក្នុងការដាក់វិន័យផ្អាកមិនឲ្យបើកប្រាក់បៀវត្ស ឬដាក់ឲ្យនៅទំនេរគ្មានប្រាក់បៀវត្ស គិតពីថ្ងៃដែលឈប់សម្រាកដោយគ្មានច្បាប់នោះ មួយវិញទៀតក្នុងរយៈពេល១ខែ ប្រសិនបើនៅមិនត្រលប់មកបំពេញការងារទេ នោះនឹងត្រូវលុបឈ្មោះពីក្របខណ្ឌ ។ ដូច្នេះដើម្បីជៀសវាងការដាក់ពិន័យ បើយោងទៅតាមមាត្រា៩៨ នៃច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាគឺរាល់ការឈប់សម្រាកនេះ គឺត្រូវមានការអនុញ្ញាត សម្រេចពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[27] ។

### ១.៦ ទណ្ឌកម្មវិន័យ

កំហុសរបស់ព្រះរាជអាជ្ញាក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ ភាពស្អាតស្អំ និងសេចក្ដីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ព្រះរាជអាជ្ញា នាំឲ្យមានទណ្ឌកម្មខាងវិន័យ ។ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្ដឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។ បណ្ដឹងដែលប្រឆាំងនឹងព្រះរាជអាជ្ញាដែល ចោទថាព្រះរាជអាជ្ញានោះបានប្រព្រឹត្តប្រាសចាកនឹងវិជ្ជាជីវៈ និងត្រូវតែដោះស្រាយឲ្យបានឆាប់រហ័ស និងត្រឹមត្រូវក្រោមនីតិវិធីសមស្រប ។ ព្រះរាជអាជ្ញាមានសិទ្ធិទទួលបានសវនាការដ៏ត្រឹមត្រូវមួយ ចំពោះសេចក្ដីសម្រេច ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញប្រកដដោយឯករាជ្យភាព ។ ពាក្យថា ទណ្ឌកម្ម មានន័យថាការដាក់ពិន័យនៅពេលបុគ្គលម្នាក់ប្រាសចាកខុសពីក្រឹតក្រមដែលបានកំណត់ ចំពោះព្រះរាជអាជ្ញាក៏ដូចគ្នា នៅពេលប្រព្រឹត្តខុសប្រាសចាកនឹងវិន័យ ឬលក្ខន្តិកៈរបស់ព្រះរាជអាជ្ញានោះ និងត្រូវប្រឈមនឹងទណ្ឌកម្មវិន័យទៀតផង ។ បើប្រៀបធៀបរវាងការដាក់ទណ្ឌកម្មវិន័យរបស់ចៅក្រម និងព្រះរាជអាជ្ញាគឺមិនមានភាពខុសគ្នានោះទេ ។ ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យ លើព្រះរាជអាជ្ញា ត្រូវជានានូវការវាយតម្លៃ និងការសម្រេចតាមសត្យានុម័ត ។ ការដាក់ទណ្ឌកម្មនឹងត្រូវកំណត់សម្រេច ដោយស្របតាមច្បាប់ ស្របតាមបទវិន័យវិជ្ជាជីវៈ និងស្របតាមបទដ្ឋាន និងក្រមសីលធម៌ឯទៀតដែលបានបង្កើតឡើងឲ្យស្រមទៅតាមគោលការណ៍លំនាំបច្ចុប្បន្នផង ។

នៅពេលព្រះរាជអាជ្ញារូបណា មានកំហុសក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ រួចបណ្ដាលឲ្យមានផលប៉ះពាល់ដល់កិត្តិយស សីលធម៌ និងសេចក្ដីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញានោះនឹងត្រូវទទួលទណ្ឌកម្ម [28] ប៉ុន្តែក៏ត្រូវបានលើកលែងមិនចាត់ទុកជាកំហុសនៅពេលដែលចៅក្រម ឬព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការអនុវត្តច្បាប់ ។

ទណ្ឌកម្មខាងវិន័យត្រូវបានបែងចែកជា២ថ្នាក់គឺ៖

ក. ទណ្ឌកម្មវិន័យថ្នាក់ទី១

- មានការស្ដីបន្ទោសដោយផ្ទាល់មាត់

[27] មាត្រា៥៣ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[28] មាត្រា៩៩ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

- ស្តីបន្ទោសដោយមានចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញមួយរយៈតែមិនត្រូវឲ្យលើស២ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលមានការចុះឈ្មោះរួច ។

ខ. ទណ្ឌកម្មថ្នាក់ទី២

- អាចផ្លាស់ដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម
- ការព្យួរពីការងារមិនឲ្យមានបៀវត្សក្នុងរយៈពេលមិនលើស១ឆ្នាំ
- កាត់បន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ
- ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ
- ការបណ្តេញចេញពីក្របខណ្ឌ

ទណ្ឌកម្មទាំងនេះត្រូវបានចេញដោយអនុក្រឹត្យបន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## ១.៧ ការចូលនិវត្តន៍

ព្រះរាជអាជ្ញាទាំងពីរភេទត្រូវចូលនិវត្តន៍នៅគ្រប់អាយុ ៦០ឆ្នាំ ដោយឡែកព្រះរាជអាជ្ញាទាំងអស់នៃមហាអយ្យការអមតុលាការកំពូល ដែលមានអាយុចាប់ពី៦០ឆ្នាំ ឡើងទៅ ត្រូវចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន ។ ប៉ុន្តែនៅពេលអាយុ ៦៥ឆ្នាំ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវសម្រេចលើការបន្តការងាររបស់ព្រះរាជអាជ្ញាទាំងអស់នៃមហាអយ្យការអមតុលាការកំពូល តាមការស្នើសុំរបស់សាមីខ្លួន ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រអំពីកិច្ចការនេះ ។

រយៈពេលនៃការចូលនិវត្តន៍សម្រាប់គ្រប់ព្រះរាជអាជ្ញាទាំងអស់៖

- ព្រះរាជអាជ្ញាដែលបានបម្រើការងារគ្រប់ ៣០ (សាមសិប) ឆ្នាំ ហើយអាចសុំចូលនិវត្តន៍បានមុនអាយុ ៦០ឆ្នាំ

- ព្រះរាអាជ្ញាដែលបានបម្រើការងារ ចាប់ពី៣០ ឆ្នាំឡើងទៅ មានសិទ្ធិទទួលសោធននិវត្តន៍អតីតភាពនាំប្រាក់បៀវត្សចុងក្រោយ ។

- ព្រះរាអាជ្ញាដែលបានបម្រើការងារបានចាប់ពី ២០ឆ្នាំឡើងទៅដល់ក្រោម ៣០ឆ្នាំមានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍សមាមាត្រ នៃប្រាក់បៀវត្សចុងក្រោយ ។

- ព្រះរាអាជ្ញាដែលបានបម្រើការងារក្រោម២០ឆ្នាំ ត្រូវទទួលត្រឹមប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗតែមួយលើក ។

រយៈពេលបម្រើការងារខាងលើ ត្រូវរាប់បញ្ចូលផងដែរនូវរយៈពេលបម្រើការងាររាជការសាធារណៈមុនកាន់តំណែងជាព្រះរាជអាជ្ញា ។

ប្រាក់សោធននិវត្តន៍របស់ព្រះរាជអាជ្ញា បើកនៅអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែមួយកន្លែងគត់ ។

ព្រះរាជអាជ្ញាដែលអត្ថិភាពគ្រប់ ៣០ (សាមសិប) ឆ្នាំ មិនត្រូវបានកាត់ប្រាក់សោធន៏និវត្តន៍ទុកទៀតឡើយ ។ ប៉ុន្តែ បើសិនព្រះរាជអាជ្ញាមានអតីតភាពមិនគ្រប់៣០ឆ្នាំទេ ត្រូវបានកាត់ប្រាក់សោធននិវត្តន៍រហូតដល់អតីតភាពការងារគ្រប់ចំនួន៣០ឆ្នាំ ដើម្បីទទួលបានប្រាក់សោធននិវត្តន៍អតីតភាព ។

ចំពោះព្រះរាជអាជ្ញាដែលមានបញ្ហា ដោយបាត់បង់កាយសម្បទាវិជ្ជាជីវៈ ត្រូវដាក់ឲ្យចូលនិវត្តន៍ដែលធ្វើឡើងដោយក្រុមប្រឹក្សានៃអង្គចៅក្រម តាមតយៈការបញ្ជាក់ពីក្រសួងសុខាភិបាល ។ ក្នុងករណីពិសេសមួយទៀតគឺ នៅពេលដែលព្រះរាជអាជ្ញាដែលមានបញ្ហាបាត់បង់កាយសម្បទាវិជ្ជាជីវៈដោយសារតែបំពេញកិច្ចការនោះ ត្រូវបានដាក់ឲ្យចូលនិវត្តន៍ដោយមានសិទ្ធិពិសេសទទួលបានប្រាក់សោធននិវត្តន៍សម្រាប់ទុព្វលភាព ដែលមានចំនួនស្មើនឹងសោធននិវត្តន៍អតីតភាព ដោយមិនគិតពីរយៈពេលបម្រើការងារ ។ ព្រះរាជអាជ្ញាដែលអាចទទួលបានប្រាក់សោធននិវត្តន៍នេះបាន លុះត្រាតែជំងឺ ឬពិការភាពនោះជាមូលហេតុផ្ទាល់ដែលនាំឲ្យមិនអាចបំពេញការងារបាន ។

ប្រសិនបើ ករណីដែលមានរបួសស្នាមផ្សេងៗត្រូវមានបញ្ជាក់ ដោយលិខិតកោសល្យវិច័យរបស់ពេទ្យជំនាញ ដែលចាត់ដោយក្រសួងសុខាភិបាល ។ ក្នុងករណីដែលព្រះរាជអាជ្ញាទទួលមរណៈភាពមកពីការបម្រើការងារស្ថិតស្ថាញ ដូចបានរៀបរាប់ខាងលើ សហព័ទ្ធ និងកូនដែលស្ថិតនៅក្នុងភាពជាអនីតិជន អាចទទួលប្រាក់បំណាច់ស្មើនឹងប្រាក់បៀវត្សរបស់អ្នកស្លាប់ចំនួន១២ខែ ព្រមទាំងមានការឧបត្ថម្ភដោយរដ្ឋទៅលើកូនក្នុងភាពជាអនីតិជន និងសហព័ទ្ធលើកលែងតែសហព័ទ្ធនោះរៀបអាពាហ៍ពិពាហ៍ថ្មី ។ ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងរៀបចំស្នើសុំទៅព្រះមហាក្សត្រដើម្បីសម្រេចនិវត្តន៍ ។

## ២. ព្រះរាជអាជ្ញា

នៅក្នុងស្ថាប័នអយ្យការគ្រប់ជាន់ថ្នាក់ គឺមានតំណាងអយ្យការ ដែលគេឲ្យនាមថា ព្រះរាជអាជ្ញា ។ ដើម្បីឲ្យកាន់តែស៊ីជម្រៅ យើងគប្បីដឹងឲ្យច្បាស់ថា អ្វីទៅជាព្រះរាជអាជ្ញា ? តើតំណាងអយ្យការ ឬព្រះរាជអាជ្ញាស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកណា ? និងមានមុខងារអ្វីខ្លះដែលព្រះរាជអាជ្ញាត្រូវបំពេញ ?

### ២.១ អ្វីទៅជាព្រះរាជអាជ្ញា ?

ព្រះរាជអាជ្ញា ជាមន្ត្រីដែលបម្រើការងារតាមស្ថាប័នអយ្យការនីមួយៗនៃព្រះរាជាណាចក្រកម្ពុជា ហើយព្រះរាជអាជ្ញា គឺជាបុគ្គលដែលមានតួនាទីយ៉ាងសំខាន់ក្នុងស្ថាប័នរបស់ខ្លួន ។

ពាក្យថា ព្រះរាជអាជ្ញា បានមកពីពាក្យ ព្រះរាជ + អាជ្ញា ។

ចំពោះ ពាក្យ ព្រះរាជ ជាពាក្យបាលី ដែលមានន័យដូចគ្នាទៅនឹងពាក្យ ព្រះរាជា ប្រែមកថាជាអ្នករុងរឿង ដោយវិសេស ឬជាអ្នកញ៉ាំងប្រជាពលរដ្ឋឲ្យមានភាពរីករាយ និងគ្រប់គ្រងប្រជានិករឲ្យមានស្វាមីភក្តិ ។ ពាក្យនេះគឺគេប្រើសម្រាប់ខ្សែរាជវង្ស ឬអ្នកដែលមានឋានៈខ្ពង់ខ្ពស់ ។ ចំណែកឯពាក្យមួយទៀត គឺ អាជ្ញា សំដៅទៅលើអំណាច ។

សរុបសេចក្តីមក ពាក្យថា ព្រះរាជអាជ្ញា ប្រែថា អំណាចរបស់អ្នកដឹកនាំ ក្នុងការស្វែករកយុត្តិធម៌ និងភាពសុខសាន្តដល់ប្រជាពលរដ្ឋ ។ បន្ថែមពីនេះ ពាក្យថា ព្រះរាជអាជ្ញា គឺមានន័យដូចគ្នាទៅនឹងពាក្យ រដ្ឋអាជ្ញា ដោយគ្រាន់តែពាក្យ ព្រះរាជអាជ្ញា ជាពាក្យដែលគេប្រើសម្រាប់ប្រទេសណាដែលមានស្តេចសោយរាជ្យ រីឯពាក្យថា រដ្ឋអាជ្ញា គេប្រើក្នុងប្រទេសដែលគ្មានស្តេចសោយរាជ្យ ។

## ២.២ សញ្ញាណព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា គឺជាពាក្យមួយដែលពុំទាន់មានច្បាប់ណាមួយបានផ្តល់នូវអត្ថន័យពេញលេញនោះទេ ប៉ុន្តែដោយយោងតាមការស្វែងយល់មួយចំនួនយើងក៏អាចឲ្យបាននូវអត្ថន័យសមស្របមួយដែរ ។ ព្រះរាជអាជ្ញាត្រូវបានឲ្យនិយមន័យថា គឺជាបុគ្គលដែលតំណាងឲ្យផលប្រយោជន៍សាធារណៈ និងជាគូក្តីដើមរបស់តុលាការ ។ ព្រះរាជអាជ្ញា មានតួនាទីដ៏សំខាន់ក្នុងការស្វែងរកភាពពិតនៃរឿងក្តី និងគ្រប់គ្រងការអនុវត្តវិធានច្បាប់នានានៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ។ ព្រះរាជអាជ្ញា ជាបុគ្គលដែលអាចទទួលបណ្តឹងទាមទារ ឬបរិហារពីនគរបាលយុត្តិធម៌ និងជនរងគ្រោះ ហើយថែមទាំងជាអ្នកថ្លឹងថ្លែងអំពីចំណាត់ការលើបណ្តឹងបរិហារ ដែលខ្លួនបានទទួលដោយផ្ទាល់ ឬមន្រ្តីនគរបាលយុត្តធម៌បញ្ជូនមក ។

ដោយសារបានមើលឃើញពីភាពចាំបាច់ខាងលើនេះហើយ ទើបអង្គការអយ្យការត្រូវបានបង្កើតឡើងដោយមានតួអង្គព្រះរាជអាជ្ញាជាអ្នកតំណាង។

# ជំពូកទី២

# រចនាសម្ព័ន្ធស្ថាប័នអយ្យការ

## ផ្នែកទី១ ៖ ស្ថាប័នអយ្យការនៅអមសាលាជម្រះក្តី

### ១. អយ្យការអមតុលាការយោធា

#### ១.១ រចនាសម្ព័ន្ធ

តុលាការយោធាជាសាលាជម្រះក្តី ដែលត្រូវបង្កើតឡើងឲ្យមានតែមួយគត់នៅរាជធានីភ្នំពេញ ។ តុលាការយោធាមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលពាក់ព័ន្ធនឹងយោធា និងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស កេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់កងយុទ្ធពលខេមរភូមិន្ទ ។

ស្ថាប័នអយ្យការត្រូវតែមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ ដែលក្នុងរឿងក្តីព្រហ្មទណ្ឌនេះព្រះរាជអាជ្ញាជាអ្នកប្តឹងទៅតុលាការ (ដើមបណ្តឹង) ហើយត្រូវតែបង្ហាញឲ្យច្បាស់នូវអ្វីដែលខ្លួនបានចោទប្រកាន់ ។ នៅពេលជំនុំជម្រះតំណាងអយ្យការត្រូវចូលរួមជាចាំបាច់ បើពុំដូច្នោះទេ តុលាការមិនអាចធ្វើការជំនុំជម្រះ ឬកាត់ទោសជនល្មើសបានឡើយ ។ ស្ថាប័នអយ្យការ ធ្វើការចោទប្រកាន់ខាងព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យមានការអនុវត្តច្បាប់ ហើយធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងសិទ្ធិអំណាចដឹកនាំការស៊ើបអង្កេតដល់នគរបាលយុត្តិធម៌ ។

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមតុលាការយោធា ជាតំណាងអយ្យការអមតុលាការយោធា ។ អយ្យការអមតុលាការយោធា គឺជាស្ថាប័នដែលនៅអមតុលាការយោធា ដែលមានមុខងារអនុវត្តរបស់ខ្លួនតាមច្បាប់ជាធរមាន ក្នុងនាមជាតំណាងឲ្យអំណាចនីតិប្រតិបត្តិក្នុងការការពារផលប្រយោជន៍សាធារណៈ និងផ្តល់សេចក្តីសុខ និងសណ្តាប់ធ្នាប់សង្គម ។ អយ្យការអមតុលាការយោធា មានសមាសភាពដូចតទៅ ៖

-ព្រះរាជអាជ្ញា

-ព្រះរាជអាជ្ញារង

-ក្រឡាបញ្ជី

-មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត

#### ១.២ មុខងារអយ្យការអមតុលាការយោធា

អយ្យការអមតុលាការយោធា មានមុខងារចម្បង គឺអនុវត្តបណ្តឹងអាជ្ញា សុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ យុត្តាធិការជំនុំជម្រះ អនុវត្តមុខងារផ្សេងៗតាមការកំណត់របស់ច្បាប់ដែលមានជាធរមាន និងដឹកនាំសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ មុខងារនេះត្រូវបានប្រគល់ទៅឲ្យព្រះរាជអាជ្ញាអមតុលាការយោធា ហើយព្រះរាជអាជ្ញារងអមតុលាការយោធាទាំងអស់ចូលរួមអនុវត្តមុខងារនេះក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាអមតុលាការយោធា។

ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹងព្រហ្មទណ្ឌ និងពាក្យបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។ ព្រះរាជអាជ្ញាមានជម្រើសនៃការចោទប្រកាន់ពីរគឺ ៖ ធ្វើការចោទប្រកាន់បទល្មើស និងសម្រេចតម្កល់រឿងទុកអត់ចាត់ការ ។

ការចោទប្រកាន់អាចធ្វើឡើងតាមរយៈបីរូបភាពគឺ៖

-ការបើកការស៊ើបសួរ

-ការបញ្ជូនទៅជម្រះផ្ទាល់

-នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។

## ១.៣ អំណាចរបស់ព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍

ព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍គឺជានាយឋានានុក្រមនៃអយ្យការអមតុលាការឧទ្ធរណ៍ និងមានអំណាចគ្រប់គ្រងលើព្រះរាជអាជ្ញារងអមតុលាការឧទ្ធរណ៍ទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ក. អំណាចឋានានុក្រម

ព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍ មានអំណាចឋានានុក្រមដែលអាចធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារងទាំងអស់ធ្វើការចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញតាមការគួរ ។ នាមុនពេលសវនាការសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារងដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងនោះត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍ជាមុនដើម្បីពិនិត្យ ណែនាំ និងសម្រេច ប្រសិនបើព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍ មិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាណែនាំជាលាយលក្ខណ៍អក្សរឲ្យព្រះរាជអាជ្ញារងដែលធ្វើសេចក្តីសន្និដ្ឋាននោះឲ្យកែតម្រូវ បើព្រះរាជអាជ្ញារងនោះនៅតែមិនព្រមធ្វើតាមនោះ ព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តងឲ្យធ្វើជាតំណាងអយ្យការនៅក្នុងសវនាការ។

### ខ. អំណាចរដ្ឋបាល

ព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍ចាត់តាំង និងបែងចែកដល់ព្រះរាជអាជ្ញារងអមតុលាការឧទ្ធរណ៍ទៅក្នុងការងារផ្សេងៗនៃអយ្យការ និងក្នុងអង្គជំនុំជម្រះ។ ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាអមតុលាការឧទ្ធរណ៍ចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសខ្លួនបាន។ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងត្រួតពិនិត្យមូលកភាពនៃការអនុវត្តវិធានឃាត់ខ្លួនដូចជាការគោរពទម្រង់ច្បាប់នៃការឃាត់ខ្លួន និងការកាន់កាប់ទីកន្លែងឃាត់ខ្លួនជាអាទិ៍។

### គ. អំណាចដឹកនាំ និងសម្របសម្រួលដល់កិច្ចការស៊ើបអង្កេត

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ សមត្ថកិច្ចរបស់ព្រះរាជអាជ្ញាគឺមានវិសាលភាពទូទាំងប្រទេស។

ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងស៊ើបអង្កេត និង ធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និង ភ្នាក់ងារនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសថ្មីក្នុងករណីពិសេសណាមួយ។ ជាមួយគ្នានេះផងដែរ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាមានសិទ្ធិអំណាចចូលរួមស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។ ចំណែកព្រះរាជអាជ្ញារងគឺស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើស។

ព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណាក់កាលស៊ើបអង្កេតផងដែរ ដូចជាការចង្អុលបង្ហាញតម្រុយធ្វើការស៊ើបអង្កេតដាក់វិធានការស្រាវជ្រាវ ផ្តល់ការអនុញ្ញាតឲ្យធ្វើការឆែកឆេរ ការអនុញ្ញាតឲ្យធ្វើការឃាត់ខ្លួន ការដោះលែង ការដឹកនាំការឆែកឆេរ និងឲ្យយោបល់នានាពេលដែលនគរបាលយុត្តិធម៌សុំយោបល់ពីព្រះរាជអាជ្ញាជៀសវាងការអនុវត្តវិធានការផ្សេងៗក្នុងការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌មិនត្រឹមត្រូវតាមនីតិវិធីកំណត់ដោយច្បាប់ ដែលជាហេតុអាចនាំឲ្យមានការប្តឹងសុំមោឃភាពនៃនីតិវិធីណាមួយជាអសារបង់ ឬក្នុងករណីអាចធ្ងន់ធ្ងរហួតដល់មានការទទួលទណ្ឌកម្មវិន័យផងដែរ ។

## ២. អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

### ២.១ រចនាសម្ព័ន្ធ

សាលាដំបូងជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបង្កើតឲ្យមាននៅរាជធានីភ្នំពេញ និងនៅតាមគ្រប់បណ្តាខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា។ សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយ ដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យសាលាជម្រះក្តីផ្សេងទៀតដែលបង្កើតឡើយដោយច្បាប់ដាច់ដោយឡែក។ អយ្យការអមសាលាដំបូង គឺនៅអមសាលាដំបូងរាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

ស្ថាប័នអយ្យការត្រូវតែមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ ដែលក្នុងរឿងក្តីព្រហ្មទណ្ឌនេះព្រះរាជអាជ្ញាជាអ្នកប្តឹងទៅតុលាការ ហើយត្រូវតែបង្ហាញឲ្យច្បាស់នូវអ្វីដែលខ្លួនបានចោទប្រកាន់ ។ នៅពេលជំនុំជម្រះតំណាងអយ្យការត្រូវចូលរួមជាចាំបាច់ បើពុំដូច្នោះទេ តុលាការមិនអាចធ្វើការជំនុំជម្រះ ឬកាត់ទោស

ជនល្មើសបានឡើយ។ អង្គការអយ្យការ ធ្វើការចោទប្រកាន់ខាងព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យមានការអនុវត្តច្បាប់ ហើយធានារ៉ាប់រងការអនុវត្តសេចក្ដីសម្រេចខាងព្រហ្មទណ្ឌ និងសិទ្ធិអំណាចដឹកនាំការស៊ើបអង្កេតដល់នគរបាលយុត្តិធម៌ ។

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ជាតំណាងអយ្យការអមសាលាដំបូង ។ អយ្យការអមសាលាដំបូង គឺជាស្ថាប័នដែលនៅអមសាលាដំបូងរាជធានី-ខេត្ត ដែលមានមុខងារអនុវត្តរបស់ខ្លួនតាមច្បាប់ជាធរមាន ។

ក្នុងនាមជាតំណាងឲ្យអំណាចនីតិប្រតិបត្តិក្នុងការការពារផលប្រយោជន៍សាធារណៈ និងផ្ដល់សេចក្ដីសុខ និងសណ្ដាប់ធ្នាប់សង្គម។ អយ្យការអមសាលាដំបូង មានសមាសភាពដូចតទៅៈ

-ព្រះរាជអាជ្ញា

-ព្រះរាជអាជ្ញារង

-ក្រឡាបញ្ជី

-មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ។

## ២.២ មុខងារអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

អយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានមុខងារចម្បង គឺអនុវត្តបណ្ដឹងអាជ្ញា សុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ យុត្តាធិការជំនុំជម្រះ អនុវត្តមុខងារផ្សេងៗតាមការកំណត់របស់ច្បាប់ដែលមានជាធរមាន និងដឹកនាំសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ មុខងារនេះត្រូវបានប្រគល់ទៅឲ្យព្រះរាជអាជ្ញាអមសាលាដំបូង ហើយព្រះរាជអាជ្ញារងអមសាលាដំបូងទាំងអស់ចូលរួមអនុវត្តមុខងារនេះក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ។

ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្ដឹងព្រហ្មទណ្ឌ និងពាក្យបណ្ដឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។ ព្រះរាជអាជ្ញាមានជម្រើសនៃការចោទប្រកាន់ពីរគឺ ៖ ធ្វើការចោទប្រកាន់បទល្មើស និងសម្រេចតម្កល់រឿងទុកអត់ចាត់ការ ។

ការចោទប្រកាន់អាចធ្វើឡើងតាមរយៈបីរូបភាពគឺ ៖

-ការបើកការស៊ើបសួរ

-ការបញ្ជូនទៅជម្រះផ្ទាល់

-នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

### ក. ការបើកការស៊ើបសួរ

នៅពេលដែលព្រះរាជអាជ្ញា យល់ឃើញថា សំណុំរឿងដែលខ្លួនទទួលបាន មានភាពស្មុគស្មាញដែលចាំបាច់ក្នុងការស្រាវជ្រាវបន្ថែម នោះព្រះរាជអាជ្ញានឹងចោទប្រកាន់តាមរយៈការបើកការស៊ើបសួរទៅចៅក្រមស៊ើបសួរដើម្បីស៊ើបសួរបន្ថែម ។

ការស៊ើបសួរនេះ អាចបើកប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។

និទ្ទេសដែលចុះនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួររួមមានៈ

-សេចក្តីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

-ឈ្មោះបុគ្គលដែលត្រូវស៊ើបសួរ ប្រសិនបើអាចកំណត់បាន

ដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវចុះការបរិច្ឆេទ និងចុះហត្ថលេខា ។ ទម្រង់នៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរនេះមានលក្ខណៈត្រូវតែគោរព បើពុំដូច្នោះទេត្រូវចាត់ទុកជាមោឃៈ ។

ចំពោះបទមជ្ឈិមព្រះរាជអាជ្ញាអាចបើកការស៊ើបសួរក៏បាន មិនធ្វើការបើកស៊ើបសួរក៏បាន ។

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ មានន័យថា ព្រះរាជអាជ្ញាមិនអាចធ្វើបណ្តឹងអាជ្ញាក្រៅពីការបើកការស៊ើបសួរនោះទេ ព្រោះបញ្ញត្តិនេះចែងឡើងដើម្បីការពារសិទ្ធិរបស់ពលរដ្ឋជាមូលដ្ឋាន ដែលគោល-ការណ៍សច្ចាធារណ៍នៃនិរទោស (ការសន្មតថា គ្មានទោស) ។រីឯបទមជ្ឈិម (មាត្រា ៤៥)[29] ក៏អាចត្រូវបានធ្វើបណ្តឹងអាជ្ញាតាមវិធីនេះផងដែរ កាលណាវាមានភាពស្មុគស្មាញនៃរឿងក្តី ឬមានភស្តុតាងមិនច្បាស់លាស់ក្នុងការបញ្ជាក់អត្ថិភាពនៃបទល្មើស ។

គោលការណ៍នៃការស៊ើបអង្កេត និងការស៊ើបសួរ ដែលជ្រើសរើសយកប្រើប្រាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺផ្អែកទៅលើអត្ថិភាពនៃអង្គហេតុជាបទល្មើស ។ ប៉ុន្តែដើម្បីឲ្យមានប្រសិទ្ធិភាព នៃការជំនុំជម្រះក្រមនីតិវិធីព្រហ្មទណ្ឌបានប្រគល់សមត្ថកិច្ចដល់ចៅក្រមស៊ើបសួរក្នុងការស្វែងរកបុគ្គល ដែលពាក់ព័ន្ធទៅនឹងអង្គហេតុនៃការចោទប្រកាន់ ព្រោះនៅដំណាក់កាលស៊ើបអង្កេតរបស់ព្រះរាជអាជ្ញាមិនបានកំណត់ពីអត្តសញ្ញាណ ឬមិនអាចកំណត់អត្តសញ្ញាណបានឡើយ ។

ការស៊ើបអង្កេតនៅដំណាក់កាលព្រះរាជអាជ្ញា គឺគ្រាន់តែការពិនិត្យអំពីតម្រុយនៃបទល្មើសប៉ុណ្ណោះ ។ ហើយមុននឹងឈានទៅដល់ការជំនុំជម្រះ គឺទាមទារឲ្យមានវត្តមានរបស់ចៅក្រមស៊ើបសួរ ដើម្បីធ្វើការស្វែងរកភស្តុតាងដាក់បន្ទុកឲ្យលើសពីវិមតិសង្ស័យ និងភស្តុតាងដោះបន្ទុកជាមុនសិន ។ ការស្វែងរកភស្តុតាង របស់ចៅក្រមស៊ើបសួរ គឺធ្វើឡើងដើម្បីបញ្ជាក់អំពីការទទួលបានយុត្តិធម៌ចំពោះមុខច្បាប់សម្រាប់ជនត្រូវចោទ ឬជនជាប់ចោទនៅដំណាក់កាលជំនុំជម្រះ ។ ម៉្យាងទៀតនៅដំណាក់កាលស៊ើបអង្កេតគឺពុំមានរយៈពេលយូរក្នុងការស្វែងរកភស្តុ

[29] មាត្រា ៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

តាងនោះទេ ។ ផ្ទុយមកវិញ នៅដំណាក់កាលស៊ើបសួរនេះចៅក្រមស៊ើបសួរ មានរយៈពេលយូរក្នុងការស្វែងរកភស្តុតាងនានា ។

ដូច្នេះ ប្រសិនបើមានលក្ខខណ្ឌណាមួយខាងលើ ព្រះរាជអាជ្ញាមិនអាចធ្វើការបញ្ជូនរឿងក្តីទៅចៅក្រមជំនុំជម្រះបានភ្លាមឡើយ គឺត្រូវចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរទៅចៅក្រមស៊ើបសួរជាអ្នកបន្តសមត្ថកិច្ចស៊ើបសួរ ។ ប៉ុន្តែកាលណាលក្ខខណ្ឌខាងលើទាំងអស់មានគ្រប់គ្រាន់ ព្រះរាជអាជ្ញាអាចសម្រេចបញ្ជូនរឿងក្តីទៅតុលាការជំនុំជម្រះបាន ។

### ខ. ការបង្ហាញខ្លួនភ្លាម

កាលណាលក្ខខណ្ឌច្បាប់ត្រូវបានបំពេញ និងតាមរយៈការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញានៅក្នុងសំណុំរឿងណាមួយដែលគប្បីប្រើប្រាស់នីតិវិធីចោទប្រកាន់ដែលមានលក្ខណៈសង្ខេប និងឆាប់រហ័សកុំឲ្យមានការកកស្ទះសំណុំរឿងនោះគឺការបង្ហាញខ្លួនភ្លាម ។ លិខិតចោទប្រកាន់នៃនីតិវិធីបង្ហាញខ្លួនភ្លាមនេះត្រូវធ្វើឡើងតាមរយៈ កំណត់ហេតុស្តីអំពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។ កំណត់ហេតុស្តីអំពីការបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមអាចធ្វើទៅបាន លុះត្រាបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ៖

-ជាបទល្មើសជាក់ស្តែង (បទមជ្ឈិមជាក់ស្តែង)

-បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ យ៉ាងតិច១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ

-ជនជាប់ចោទជានីតិជន

-រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

ដោយឡែកព្រះរាជអាជ្ញាត្រូវធ្វើការ ៖

-ត្រួតពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឲ្យខ្លួន

-ឲ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស

-ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ

-ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។

ដូច្នេះ ព្រះរាជអាជ្ញាអាចធ្វើនីតិវិធីនេះ ដោយបញ្ជូនជនជាប់ចោទជាមួយនឹងសំណុំរឿងទៅចៅក្រមជំនុំជម្រះតាមរយៈកំណត់ហេតុស្តីអំពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ដើម្បីធ្វើការជំនុំជម្រះនៅថ្ងៃដែលបង្ហាញខ្លួននេះតែម្តង ។ ប៉ុន្តែប្រសិនបើជនជាប់ចោទត្រូវការរយៈពេលដើម្បីរៀបចំការពារខ្លួន ការជំនុំជម្រះ (សវនាការ) សំណុំរឿងនេះនឹងត្រូវលើកទៅពេលសវនាការជំនុំជម្រះលើកក្រោយ តែចៅក្រមជំនុំជម្រះនឹងសម្រេចជំនុំជម្រះមុនអង្គសេចក្តីពាក់ព័ន្ធនឹងការឃុំខ្លួនជាមុនសិន ហើយសវនាការជំនុំជម្រះលើកក្រោយ គឺមិនឲ្យលើសរយៈពេលពីរសប្តាហ៍នោះទេ ។

## គ. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការអនុវត្តសេចក្ដីសម្រេច

នាពេលដែលព្រះរាជអាជ្ញា យល់ឃើញថា សំណុំរឿងដែលខ្លួនទទួលបាន មិនមានភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែមទេ ព្រះរាជអាជ្ញាត្រូវធ្វើការបញ្ជូនរឿងក្ដៅទៅតុលាការជំនុំជម្រះតែម្ដង ។

ការបញ្ជូនទៅជម្រះផ្ទាល់មិនអាចធ្វើទៅបានទេចំពោះបទឧក្រិដ្ឋ ។ ការបញ្ជូនទៅជម្រះផ្ទាល់អាចធ្វើទៅបានចំពោះបទមជ្ឈិម និងបទលហុជាកាតព្វកិច្ចព្រះរាជអាជ្ញាដែលត្រូវតែបញ្ជូនទៅជំនុំជម្រះផ្ទាល់តែម្ដង ។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ព្រះរាជអាជ្ញាធ្វើឡើងតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាការបញ្ជាខ្លួននៅមុខតុលាការជាន់ដំបូង ។

និទ្ទេសដែលមានចុះក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន ៖

-អត្តសញ្ញាណនៃជនជាប់ចោទ

-សេចក្ដីសង្ខេបនៃអង្គហេតុ

-ឈ្មោះបទល្មើស

-អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ។

ដីកានេះត្រូវចង្អុលប្រាប់តុលាការពី ទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីខ្លួនបាន ។ ដូច្នេះ ប្រសិនបើមានលក្ខខណ្ឌខាងលើបានបំពេញអស់ហើយ ព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿងនេះ ទៅចៅក្រមជំនុំជម្រះផ្ទាល់ ដោយព្រះរាជអាជ្ញាត្រូវកោះហៅ និងប្រាប់ព័ត៌មានដល់ជនជាប់ចោទតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដើម្បីឲ្យមានវត្តមានតាមកាលបរិច្ឆេទជំនុំជម្រះរបស់ចៅក្រមជំនុំជម្រះ ។

ស្ថាប័នអយ្យការមានមុខងារចម្បងមួយទៀត គឺការអនុវត្តសេចក្ដីសម្រេចស្ថាពរខាងព្រហ្មទណ្ឌ ដូចជា សាលក្រម និងសាលដីកាស្ថាពរ ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថា ការអនុវត្តទោសត្រូវធ្វើតាមគំនិតផ្ដើមរបស់អយ្យការ មានន័យថានៅពេលដែលសាលក្រម ឬសាលដីកាដែលសម្រេចអំពីទោសដែលចូលស្ថាពរនោះការអនុវត្តទោសត្រូវធ្វើដោយស្ថាប័នអយ្យការជាន់ដំបូង គឺអយ្យការអមសាលាដំបូងរាជធានីខេត្ត និងអយ្យការយោធា ។ នៅក្នុងការអនុវត្តសេចក្ដីសម្រេចនេះ គឺតំណាងអយ្យការអាចសុំកងកម្លាំងសាធារណៈដើម្បីអនុវត្ត ហើយបើសិនមានការលំបាកដែលទាក់ទងនឹងការអនុវត្តទោសនោះតំណាងអយ្យការត្រូវលើកជូនតុលាការជាន់ដំបូង ឬតុលាការជាន់ខ្ពស់ដែលបានចេញសេចក្ដីសម្រេចដើម្បីដោះស្រាយ ។

មួយវិញទៀតការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនដែលចេញដោយចៅក្រមស៊ើបសួរ គឺត្រូវបានផ្សព្វផ្សាយដោយព្រះរាជអាជ្ញាផងដែរ ដែលជាអ្នកទទួលបន្ទុកផ្សព្វផ្សាយ ឬណែនាំដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួននេះ ។

### ឃ. ការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គឺជាជម្រើសនៃការចោទប្រកាន់ដែលកើតចេញពីគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ហើយជានីតិវិធីថ្មីមួយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលផ្តល់អំណាចយ៉ាងធំធេងដល់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងក្តីណាមួយឥតចាត់ការតាមរយៈការថ្លឹងថ្លែងរបស់ខ្លួនបើសិនខ្លួនយល់ឃើញថាបទល្មើសមួយដែលមិនអាចចោទប្រកាន់ ឬមិនគួរចោទប្រកាន់ដើម្បីផលប្រយោជន៍សាធារណៈក៏ដូចជាសង្គមទាំងមូល ។ បទល្មើសដែលមិនគួរចោទប្រកាន់ គឺជាបទល្មើសតូចតាចមិនជះឥទ្ធិពលធ្ងន់ធ្ងរដល់សង្គម ចំណែកឯព្យសនកម្មចំពោះជនរងគ្រោះទាំងផ្នែកសីលធម៌ និងសេដ្ឋកិច្ចក៏មានតិចតួច ហើយជនរងគ្រោះមិនអើពើផងដែរ ។ ចំពោះបទល្មើសដែលមិនអាចចោទប្រកាន់ដូចជា មាត្រា៨០នៃរដ្ឋធម្មនុញ្ញដែលបញ្ញត្តិអំពីអភ័យឯកសិទ្ធិតំណាងរាស្ត្រ និងមានមូលហេតុគតិយុត្តផ្សេងទៀត ។ ការតម្កល់រឿងទុកឥតចាត់ការមានការជាប់ទាក់ទងទៅនឹងការរលត់បណ្តឹងអាជ្ញាដែលមានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមានដូចខាងក្រោម ៖

-មរណៈភាពនៃជនល្មើស

-ការផុតបណ្តឹងអាជ្ញា

-ការលើកលែងទោសជាទូទៅ

-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

-អាជ្ញាអស់ជំនុំ

ប្រសិនបើបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទេ ឬត្រូវតែបញ្ឈប់ ។ ព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកអត់ចាត់ការលើបណ្តឹងព្រហ្មទណ្ឌមួយបាន ដោយផ្អែកលើសំអាងច្បាប់ និងសំអាងហេតុ ។

ការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំទេ ព្រះរាជអាជ្ញាអាចធ្វើការសើរើសេចក្តីសម្រេចរបស់ខ្លួនបានគ្រប់ពេល នៅពេលបទល្មើសមិនទាន់ផុតអាជ្ញាយុកាល និងបណ្តឹងអាជ្ញាមិនទាន់រលត់ ។

ការតម្កល់រឿងទុកឥតចាត់ការនេះ ប្រសិនបើភាគីធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចដែនដី ដើម្បីឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ពិនិត្យលើសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាជាន់ដំបូងដែលសម្រេចតម្កល់រឿងទុលអត់ចាត់ការឲ្យដំណើរការឡើងវិញ ។ ការតវ៉ានេះត្រូវធ្វើឡើងក្នុងរយៈពេល ២ ខែគិតចាប់ពីថ្ងៃដែលទទួលបានដំណឹងពីការតម្កល់រឿងទុកឥតចាត់ការ ។ ជាលទ្ធផលប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថាការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ញាឲ្យព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់ឡើងវិញ ប្រសិនបើអគ្គព្រះអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថាចំណាត់ការរបស់ព្រះរាជអាជ្ញាជាន់ដំបូង ត្រឹមត្រូវតាមគតិច្បាប់ហើយ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នឹងសម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាជាន់ដំបូងទុកជាបានការដដែល ។

## ២.៣ អំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត

ព្រះរាជអាជ្ញាអមសាលាដំបូងគឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង និងមានអំណាចគ្រប់គ្រងលើព្រះរាជអាជ្ញារងអមសាលាដំបូងទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**ក.អំណាចឋានានុក្រម .**

ព្រះរាជអាជ្ញាអមសាលាដំបូងមានអំណាចឋានានុក្រមដែលអាចធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារងទាំងអស់ធ្វើការចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញតាមការគួរ ។ នាមុនពេលសវនាការសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារងដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងនោះត្រូវតែបញ្ជូនទៅព្រះ-រាជអាជ្ញាអមសាលាដំបូងជាមុនដើម្បីពិនិត្យ ណែនាំ និងសម្រេច ប្រសិនបើព្រះរាជអាជ្ញាអមសាលាដំបូង មិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាណែនាំជាលាយលក្ខណ៍អក្សរឲ្យព្រះរាជអាជ្ញារងដែលធ្វើសេចក្តីសន្និដ្ឋាននោះឲ្យកែតម្រូវ បើព្រះរាជអាជ្ញារងនោះនៅតែមិនព្រមធ្វើតាមនោះ ព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តងឲ្យធ្វើជាតំណាងអយ្យការនៅក្នុងសវនាការ ។

**ខ. អំណាចរដ្ឋបាល**

ព្រះរាជអាជ្ញាអមសាលាដំបូងចាត់តាំង និងបែងចែកដល់ព្រះរាជអាជ្ញារងអមសាលាដំបូងទៅក្នុងការងារផ្សេងៗនៃអយ្យការ និងក្នុងអង្គជំនុំជម្រះ ។ ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាអមសាលាដំបូងត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសខ្លួនបាន ។ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងត្រួតពិនិត្យមូលកភាពនៃការអនុវត្តវិធានឃាត់ខ្លួនដូចជាការគោរពទម្រង់ច្បាប់នៃការឃាត់ខ្លួន និងការកាន់កាប់ទីកន្លែងឃាត់ខ្លួនជាអាទិ៍ ។

**គ. អំណាចដឹកនាំ និងសម្របសម្រួលដល់កិច្ចការស៊ើបអង្កេត**

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ សមត្ថកិច្ចរបស់ព្រះរាជអាជ្ញាគឺមានកំណត់នៅក្នុងច្បាប់ទៅតាមដែនដីរបស់ខ្លួនរួមមាន៖

-ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស

-ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យ បានប្រព្រឹត្តបទល្មើស

-ព្រះរាជអាជ្ញានៃទីចាប់ខ្លួនជនដែលគេសង្ស័យ បានប្រព្រឹត្តបទល្មើស

ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងស៊ើបអង្កេត និង ធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និង ភ្នាក់ងារនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាល

យុត្តិធម៌ និងរៀបចំជំនួសថ្មីក្នុងករណីពិសេសណាមួយ ។ ជាមួយគ្នានេះផងដែរ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាមានសិទ្ធិអំណាចចូលរួមស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន ។ ចំណែកព្រះរាជអាជ្ញារងគឺស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើស ។

ព្រះរាជអាជ្ញាមានភារកិច្ចដឹកនាំសម្របសម្រួលសកម្មភាពការងារមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួននៅដំណាក់កាលស៊ើបអង្កេត ហើយព្រះរាជអាជ្ញាមានអំណាចលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលត្រូវបានផ្តល់នីតិសម្បទាស្របច្បាប់ ។

ព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណាក់កាលស៊ើបអង្កេតផងដែរ ដូចជាការចង្អុលបង្ហាញតម្រុយធ្វើការស៊ើបអង្កេតដាក់វិធានការស្រាវជ្រាវ ផ្តល់ការអនុញ្ញាតឲ្យធ្វើការឆែកឆេរ ការអនុញ្ញាតឲ្យធ្វើការឃាត់ខ្លួន ការដោះលែង ការដឹកនាំការឆែកឆេរ និងឲ្យយោបល់នានាពេលដែលនគរបាលយុត្តិធម៌សុំយោបល់ពីព្រះរាជអាជ្ញាជៀសវាងការអនុវត្តវិធានការផ្សេងៗក្នុងការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌មិនត្រឹមត្រូវតាមនីតិវិធីកំណត់ដោយច្បាប់ដែលជាហេតុអាចនាំឲ្យមានការប្តឹងសុំមោឃភាពនៃនីតិវិធីណាមួយជាអសារបង់ ឬក្នុងករណីអាចធ្ងន់ធ្ងរហួតដល់មានការទទួលទណ្ឌកម្មវិន័យផងដែរ ។

## ៣. មហាអយ្យការអមសាលាឧទ្ធរណ៍

### ៣.១ រចនាសម្ព័ន្ធ

សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្តីថ្នាក់ទី២ ។ សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការផ្សេងទៀត ។ នៅអមសាលាឧទ្ធរណ៍មានមហាអយ្យការដែលមានសមាសភាពដូចតទៅ ៖

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍

-ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រឡាបញ្ជី

-មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។

នៅមុនឆ្នាំ២០២០ សាលាឧទ្ធរណ៍មានតែមួយគត់នៅព្រះរាជាណាចក្រកម្ពុជា ដូចតុលាការកំពូលដែរ ពោលគឺមានទីតាំងនៅរាជធានីភ្នំពេញ ។ មហាអយ្យការអមសាលាឧទ្ធរណ៍ក៏មានតែមួយដូចគ្នានៅអមសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ។ ប៉ុន្តែក្រោយមក មានការដាក់ឲ្យដំណើរការ និងកំណត់សមត្ថកិច្ចសាលាឧទ្ធរណ៍ចំនួន ៣ បន្ថែមទៀត តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ក្នុងគោលបំណងដាក់ឲ្យដំណើរការ និងកំណត់សមត្ថកិច្ចសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់ចំនួន៣ បន្ថែមនោះ គឺតំបន់ត្បូងឃ្មុំ តំបន់ព្រះសីហនុ និងតំបន់បាត់ដំបង ដើម្បីសម្រួលដល់រឿងក្តីរបស់ប្រជាពលរដ្ឋតាមខេត្តនីមួយៗ ។ ដូចនេះ សាលាឧទ្ធរណ៍តំបន់នីមួយៗមានអមដោយមហាអយ្យការមួយ ស្របតាមបញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីអង្គការតុលាការ និងច្បាប់ជាធរមានពាក់ព័ន្ធដទៃផ្សេងទៀត ។

### ៣.២. មុខងារអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

មហាអយ្យការអមសាលាឧទ្ធរណ៍មានមុខងារចម្បង គឺឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ មុខងារនេះត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ហើយអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចូលរួមអនុវត្តមុខងារក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

### ៣.៣. អំណាចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

#### ក. អំណាចឋានានុក្រម

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍ និងមានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទាំងអស់ ។ សេចក្តីសន្និដ្ឋានរបស់អគ្គ-ព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដើម្បីពិនិត្យនៅមុន ពេលសវនាការ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាណែនាំជាលាយលក្ខណ៍អក្សរឲ្យតំណាងមហាអយ្យការដែលធ្វើសេចក្តីសន្និដ្ឋាននោះឲ្យកែតម្រូវ បើតំណាងមហាអយ្យការនោះនៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអាចចាត់តាំងអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ លើសពីនេះទៅទៀតអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញាអមសាលាដំបូងដែលនៅក្រោមដែនដីសមត្ថកិច្ចឲ្យធ្វើការចោទប្រកាន់បានដោយអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

#### ខ. អំណាចផ្នែករដ្ឋបាល

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៅក្នុងការងារផ្សេងៗនៃមហាអយ្យការ និងក្នុងអង្គជំនុំជម្រះ ក្នុងករណីមានធុរៈ ឬមាន

ជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារង អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ឲ្យបំពេញកិច្ចទាំងឡាយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការដ៏ល្អនៃនគរបាលយុត្តិធម៌ ។

**គ. អំណាចធ្វើអធិការកិច្ច**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចនៅអង្គការអយ្យការទាំងឡាយដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន និងធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ។ ប្រធានអង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌គ្រប់រូបត្រូវគោរពតាមអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

## ៤. មហាអយ្យការអមតុលាការកំពូល

### ៤.១ រចនាសម្ព័ន្ធ

មហាអយ្យការអមតុលាការកំពូល មានសមត្ថកិច្ចអមតុលាការកំពូលដែលជាយុត្តាធិការលំដាប់ខ្ពស់បំផុតតែមួយគត់នៅព្រះរាជាណាចក្រកម្ពុជា ដែលមានទីតាំងនៅរាជធានីភ្នំពេញ ។ មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចជា ៖

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល
- ព្រះរាជអាជ្ញាអមតុលាការកំពូល
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និង អាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល ។

### ៤.២ មុខងារអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

មហាអយ្យការអមតុលាការកំពូលមានមុខងារចម្បង គឺចូលរួមសុំឲ្យមានការគោរពច្បាប់នៅក្នុងពេលដែលមានបណ្តឹងសារទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀតដែលដាក់ជូនតុលាការកំពូលពិនិត្យ ។ មុខងារនេះត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ហើយអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលចូលរួមអនុវត្តមុខងារក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

## ៤.៣ អំណាចរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

### ក. អំណាចឋានានុក្រម

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល ដែលមានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទាំងអស់ ។ ចៅក្រមអយ្យការទាំងអស់នៃមហាអយ្យការតុលាការបំពេញមុខងារក្រោមការចាត់ចែង ណែនាំ និងទទួលខុសត្រូវរួមដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា ។ មុនពេលចូលរួមសវនាការ សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលពិនិត្យ ណែនាំ និងសម្រេច ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ជាណែនាំជាលាយលក្ខណ៍អក្សរឲ្យតំណាងមហាអយ្យការដែលធ្វើសេចក្តីសន្និដ្ឋាននោះឲ្យកែតម្រូវ ។ បើតំណាងមហាអយ្យការនោះនៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអាចចាត់តាំងអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។

### ខ. អំណាចផ្នែករដ្ឋបាល

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទៅក្នុងការងារផ្សេងៗនៃមហាអយ្យការ និងក្នុងអង្គជំនុំជម្រះ ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារង អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន ។

### គ. សមាជិកភាពស្វ័យប្រវត្តិនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

នៅពេលដែលចៅក្រមអយ្យការណាម្នាក់ត្រូវបានទទួលតំណែងជាអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលនោះ គឺត្រូវទទួលបានតំណែងជាសមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាស្វ័យប្រវត្តិ អនុលោមតាមមាត្រា៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលបានកំណត់អំពីសមាសភាពនៃសមាជិកទាំង១១រូប ដែលក្នុងនោះមាន៣រូបជាសមាជិកស្វ័យប្រវត្តិដូចជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ លើសពីនេះទៅទៀតមុខងារជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលនេះមានលក្ខណៈពិសេសដោយមិនមានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលឡើយ ។

# ផ្នែកទី២ ៖ ប្រវត្តិអយ្យការអមតុលាការជាន់ទាប

## ១. អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

តាមការសិក្សាស្រាវជ្រាវអំពីប្រវត្តិអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្រុមយើងខ្ញុំសូមបង្ហាញអំពីប្រវត្តិ រចនាសម្ព័ន្ធ តួនាទី និងការអនុវត្តជាក់ស្តែងរបស់ព្រះរាជអាជ្ញានៅទីនោះ ។

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានទីតាំងស្ថិតនៅផ្ទះលេខ២៧ ផ្លូវមុន្នីរ៉េត (២១៧) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

### ១.១ ប្រវត្តិអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

#### ១.១.១ ការរៀបចំដំណើរការអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ រដ្ឋាភិបាលបានប្រគល់តួនាទី និងភារកិច្ចឲ្យក្រសួងយុត្តិធម៌ទទួលបន្ទុកវិស័យយុត្តិធម៌ ដើម្បីខិតខំកសាងប្រព័ន្ធតុលាការកម្ពុជាឡើងវិញ បន្ទាប់ពីត្រូវបានបំផ្លិចបំផ្លាញអស់ទាំងស្រុងនៅក្នុងរបបមួយនេះ ។ លុះមកដល់ឆ្នាំ១៩៨០ ទើបសម្រេចបង្កើតសាលាដំបូង និងអយ្យការអមសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយបានរៀបចំដំណើរការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនចាប់តាំងពីពេលនោះរហូតមកដល់បច្ចុប្បន្ននេះ ។

#### ១.១.២ ប្រវត្តិថ្នាក់ដឹកនាំអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ព្រះរាជអាជ្ញា ដែលជាថ្នាក់ដឹកនាំនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាប់ពីឆ្នាំ១៩៨០ រហូតមកដល់បច្ចុប្បន្នមាន ៖

១. លោក ជា ជេដ្ឋ

២. លោក កាន់ ឈីន

៣. លោក អ៊ុក សាវុធ

៤. លោក យ៉េត ចរិយា

៥. លោក កែវ សុធា

៦. ឯកឧត្តម ច្រឹង ខ្មៅ

#### ១.១.៣ តួនាទី និងតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ព្រះរាជអាជ្ញាមានអំណាច និងតួនាទី ចោទប្រកាន់នូវរាល់ប្រព្រឹត្តកម្មនៃបទល្មើសព្រហ្មទណ្ឌនានាក្នុងនាមតំណាងអង្គការអយ្យការជាអ្នកទទួលខុសត្រូវលើការសុំឲ្យអនុវត្តទណ្ឌកម្ម និងធានារ៉ាប់រងសេចក្តីសម្រេចខាងព្រហ្មទណ្ឌនៅចំពោះមុខតុលាការព្រហ្មទណ្ឌ មានន័យថាអង្គការអយ្យការជាអ្នកធានារ៉ាប់រង និងទទួលខុសត្រូវចំពោះសេចក្តីសន្និដ្ឋានមួយក្នុងនាមចៅក្រមអយ្យការ ដើម្បីឲ្យតុលាការអនុវត្តសេចក្តីសម្រេចខាងព្រហ្មទណ្ឌទៅតាមគោលការណ៍ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ ។

ដើម្បីធានារ៉ាប់រងកិច្ចការគ្រប់យ៉ាងនូវដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ ក៏ដូចជាសេចក្ដីសម្រេចខាងព្រហ្មទណ្ឌ ប្រកបដោយយុត្តិធម៌ ។

## ១.២ រចនាសម្ព័ន្ធ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ១.២.១ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដឹកនាំដោយព្រះរាជអាជ្ញា ០១ រូប និងព្រះរាជអាជ្ញារង ១៨ រូប ព្រមទាំងក្រឡាបញ្ជីមួយចំនួន ។

ខាងក្រោមនេះ គឺជាតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ៖

| | | |
|---|---|---|
| ១. | ឯកឧត្តម ច្រឹង ខ្មៅ | ព្រះរាជអាជ្ញា |
| ២. | លោក ប្លង់ សុផល | ព្រះរាជអាជ្ញារង |
| ៣. | លោក ហេង ផេង | ព្រះរាជអាជ្ញារង |
| ៤. | លោក សាយ ណូរ៉ា | ព្រះរាជអាជ្ញារង |
| ៥. | លោក គឹម ហុងសាន | ព្រះរាជអាជ្ញារង |
| ៦. | លោក វង្ស សារ៉ាត | ព្រះរាជអាជ្ញារង |
| ៧. | លោក ម៉ុត ដារ៉ា | ព្រះរាជអាជ្ញារង |
| ៨. | លោក សុក កែវបណ្ឌិត | ព្រះរាជអាជ្ញារង |
| ៩. | លោក អ៊ុំ សុភក្តិ | ព្រះរាជអាជ្ញារង |
| ១០. | លោក ស៊ិត វណ្ណៈ | ព្រះរាជអាជ្ញារង |
| ១១. | លោក ទី មុនិន្ទ | ព្រះរាជអាជ្ញារង |
| ១២. | លោក លឹម ប៊ុនហេង | ព្រះរាជអាជ្ញារង |
| ១៣. | លោក ចៃ សុង | ព្រះរាជអាជ្ញារង |
| ១៤. | លោក សឿ ឡុងឌី | ព្រះរាជអាជ្ញារង |
| ១៥. | លោកស្រី សុង ឆវ័ន្ត | ព្រះរាជអាជ្ញារង |
| ១៦. | លោក សំម ឫទ្ធីវ៉ាសនា | ព្រះរាជអាជ្ញារង |
| ១៧. | លោក ឆាយ ហុង | ព្រះរាជអាជ្ញារង |
| ១៨. | លោក សេង ហៀង | ព្រះរាជអាជ្ញារង |
| ១៩. | លោក ទុង រតនា | ព្រះរាជអាជ្ញារង |

## ២. អយ្យការអមតុលាការយោធា

### ២.១. ប្រវត្តិអយ្យការអមតុលាការយោធា

តាមការសិក្សាស្រាវជ្រាវអំពីប្រវត្តិអយ្យការអមតុលាការយោធា ក្រុមយើងខ្ញុំសូមបង្ហាញអំពីប្រវត្តិ រចនាសម្ព័ន្ធ តួនាទី និងការអនុវត្តជាក់ស្តែងរបស់ព្រះរាជអាជ្ញានៅទីនោះ ។

អយ្យការអមតុលាការយោធា បង្កើតឡើងវិញក្រោយរបបកម្ពុជាប្រជាធិបតេយ្យដែលជារបបប្រល័យពូជសាសន៍ និងបានសម្លាប់ប្រជារាស្ត្រខ្មែរប្រហែលជាង១លាននាក់ ។ អយ្យការអមតុលាការយោធាបង្កើតឡើងក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៨១ ដែលមានទីតាំងស្ថិតនៅសង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ រហូតដល់ឆ្នាំ២០០៥ អយ្យការអមតុលាការយោធា បានប្តូរទីតាំងទៅសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

បច្ចុប្បន្នអយ្យការអមតុលាការយោធា មានទីតាំងស្ថិតនៅ តុលាការយោធាលេខ១៥ ផ្លូវ៦២០ ភូមិដំណាក់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ[30] ។

### ២.១.២ ប្រវត្តិថ្នាក់ដឹកនាំអយ្យការអមតុលាការយោធា

ព្រះរាជអាជ្ញា ដែលជាថ្នាក់ដឹកនាំនៅអយ្យការអមតុលាការយោធា ចាប់ពីឆ្នាំ១៩៨០ រហូតមកដល់បច្ចុប្បន្នមាន ៖

១. នាយឧត្តមសេនីយ៍ សៅ សុខ រដ្ឋលេខាធិការក្រសួងការពារជាតិ (បច្ចុប្បន្ន)

២. ឧត្តមសេនីយ៍ឯក ព្រំ សានថុន

### ២.១.៣ តួនាទី និងតំណាងអយ្យការអមតុលាការយោធា

ព្រះរាជអាជ្ញាមានអំណាច និងតួនាទី ចោទប្រកាន់នូវរាល់ប្រព្រឹត្តកម្មនៃបទល្មើសព្រហ្មទណ្ឌនានាក្នុងនាម តំណាងអង្គការអយ្យការជាអ្នកទទួលខុសត្រូវលើការសុំឲ្យអនុវត្តទណ្ឌកម្ម និងធានារ៉ាប់រងសេចក្តីសម្រេចខាងព្រហ្មទណ្ឌនៅចំពោះមុខតុលាការព្រហ្មទណ្ឌ មានន័យថាអង្គការអយ្យការជាអ្នកធានារ៉ាប់រង និងទទួលខុសត្រូវចំពោះសេចក្តីសន្និដ្ឋានមួយក្នុងនាមចៅក្រមអយ្យការ ដើម្បីឲ្យតុលាការអនុវត្តសេចក្តីសម្រេចខាងព្រហ្មទណ្ឌទៅតាមគោលការណ៍ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ ។

ដើម្បីធានារ៉ាប់រងកិច្ចការគ្រប់យ៉ាងនូវដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ ក៏ដូចជាសេចក្តីសម្រេចខាងព្រហ្មទណ្ឌ ប្រកបដោយយុត្តិធម៌ ។

---

[30] ប្រវត្តិតុលាការយោធាពីឆ្នាំ ១៩៥៤-២០២០

## ២.២ រចនាសម្ព័ន្ធ របស់អយ្យការអមតុលាការយោធា

### ២.២.១ អយ្យការអមតុលាការយោធា

អយ្យការតុលាការយោធា ដឹកនាំដោយព្រះរាជអាជ្ញា ០១ រូប និងព្រះរាជអាជ្ញារង ១៨ រូប ព្រមទាំងក្រឡាបញ្ជីមួយចំនួន ។

ខាងក្រោមនេះ គឺជាតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ៖

| | | |
|---|---|---|
| ១. | ឧត្តមសេនីយ៍ឯក ព្រុំ សនថុន | ព្រះរាជអាជ្ញា |
| ២. | ឧត្តមសេនីយ៍ទោ សក់ ផារិន | ព្រះរាជអាជ្ញារង |
| ៣. | ឧត្តមសេនីយ៍ទោ ម៉ែន ហុង | ព្រះរាជអាជ្ញារង |
| ៤. | ឧត្តមសេនីយ៍ទោ ម៉ក់ សីហា | ព្រះរាជអាជ្ញារង |
| ៥. | ឧត្តមសេនីយ៍ទោ ព្រុំ សន្ធូណៅរ៉ូ | ព្រះរាជអាជ្ញារង |
| ៦. | ឧត្តមសេនីយ៍ទោ ហួន សែមសារ | ព្រះរាជអាជ្ញារង |
| ៧. | ឧត្តមសេនីយ៍ទោ ណាវ៉េត ប៊ុណារ៉ាត់ | ព្រះរាជអាជ្ញារង |
| ៨. | ឧត្តមសេនីយ៍ត្រី អៀង សុទ្ធរិទ្ធ | ព្រះរាជអាជ្ញារង |
| ៩. | ឧត្តមសេនីយ៍ត្រី ហ៊ុន សុខុម | ព្រះរាជអាជ្ញារង |
| ១០. | ឧត្តមសេនីយ៍ត្រី ព្រុំ ដារ៉ា | ព្រះរាជអាជ្ញារង |
| ១១. | ឧត្តមសេនីយ៍ត្រី វ័ន្ន សារុន | ព្រះរាជអាជ្ញារង |
| ១២. | ឧត្តមសេនីយ៍ត្រី សាវ សាវេត | ព្រះរាជអាជ្ញារង |
| ១៣. | ឧត្តមសេនីយ៍ត្រី អ៊ុន សំអន | ព្រះរាជអាជ្ញារង |
| ១៤. | ឧត្តមសេនីយ៍ត្រី ឡាន ចន្ទ័ដារ៉ា | ព្រះរាជអាជ្ញារង |
| ១៥. | ឧត្តមសេនីយ៍ត្រី នង ខេមរា | ព្រះរាជអាជ្ញារង |
| ១៦. | ឧត្តមសេនីយ៍ត្រី ម៉ន ប៉ាន់ | ព្រះរាជអាជ្ញារង |
| ១៧. | វរសេនីយ៍ឯក ទឹម ហៃមរ៉ា | ព្រះរាជអាជ្ញារង |
| ១៨. | វរសេនីយ៍ឯក ថុន សាម៉ីឌី | ព្រះរាជអាជ្ញារង |
| ១៩. | វរសេនីយ៍ឯក គួយ ឈឿន | ព្រះរាជអាជ្ញារង |

# ជំពូកទី៣

# នីតិវិធី និងចំណាត់ការរបស់អយ្យការក្នុងរឿងក្តីព្រហ្មទណ្ឌ

## ផ្នែកទី១៖ នីតិវិធីស៊ើបអង្កេត

ការស៊ើបអង្កេត គឺជានីតិវិធីមួយដែលត្រូវបានដឹកនាំដោយព្រះរាជអាជ្ញា ហើយត្រូវធ្វើឡើងដោយការសម្ងាត់ ។ ការស៊ើបអង្កេតនេះ ត្រូវបានចែកចេញជាពីរផ្នែក គឺការស៊ើបអង្កេតជាក់ស្តែង (១) និងការស៊ើបអង្កេតបឋម (២) ។

### ១. ការស៊ើបអង្កេតករណីជាក់ស្តែង

យោងតាមមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ យើងអាចកំណត់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងបានដោយមានលក្ខខណ្ឌមួយចំនួន ។ លក្ខខណ្ឌកំណត់បទល្មើសទាំងនោះមានដូចជា ជាបទល្មើសដែលកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម កាលណានៅក្រោយពេលមានបទល្មើសបន្តិច ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រកីង បុគ្គលដែលត្រូវរកឃើញថាមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីចង្វាក់ផ្សេងៗទៀត ដែលអាចនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្តឬបានចូលរួមប្រព្រឹត្តបទល្មើស ។

ក្នុងករណីមានបទឧក្រិដ្ឋ ឬមជ្ឈិមបានកើតឡើងនៅក្នុងទីកន្លែងមួយដែលអ្នកកាន់កាប់នៅទីនោះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាល នោះក៏អាចចាត់ទុកថាជាបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងដែរ ។

#### ១.១ ការឆែកឆេរ

ការឆែកឆេរ ជាវិធីមួយដែលបង្កើតឡើងក្នុងការរុករក និងប្រមូលនូវភស្តុតាងដើម្បីធ្វើការដាក់បន្ទុក ។ ក្នុងករណីបទល្មើសជាក់ស្តែងនេះ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបាន តែត្រូវទទួលការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតនោះដោយផ្ទាល់មាត់ក៏ដោយ ។ ការឆែកឆេរនេះ ត្រូវតែធ្វើឡើងដោយ មន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវធ្វើការឆែកឆេរចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ដែលមិនមែនជាសមត្ថកិច្ចដែលមិនមែនកងកម្លាំងរួមប្រតិបត្តិការជាមួយ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរបានទៅតាមម៉ោងនីត្យានុកូលដែលច្បាប់បានកំណត់ ចាប់ពីម៉ោង៦ព្រឹក ដល់ម៉ោង១៨ល្ងាច ប៉ុន្តែក៏អាចធ្វើការឆែកឆេរបាននៅ

ក្រោយម៉ោងដែលបានកំណត់ដែរ ក្នុងករណីបទល្មើសជាក់ស្តែង មានសម្រែកឲ្យជួយពីក្នុងទីកន្លែង ។ ការឆែកឆេរនៅទីកន្លែងណាមួយត្រូវធ្វើឡើងដោយបើកចំហរដល់សាធារណៈ និងករណីឆែកឆេរទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន ។

### ១.២ ការឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឃាត់ខ្លួនបុគ្គលណាមួយដែលសង្ស័យថាបានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តបទល្មើស ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត ប៉ុន្តែរាល់ការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមទៅកាន់ព្រះរាជអាជ្ញា ព្រមទាំងបញ្ជូននូវភស្តុតាងទាំងអស់ដែលតម្រូវឲ្យមានការឃាត់ខ្លួននោះ ។ ការឃាត់ខ្លួន មានចិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង[31] ដោយគិតពីពេលដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។ ក្នុងករណីរកឃើញថាមានពិរុទ្ធលើបុគ្គលដែលឃាត់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបានប្រសិនបើជាការចាំបាច់ តែការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញាដើម្បីផ្ទៀងផ្ទាត់ និងអនុញ្ញាតដោយធ្វើជាលាយលក្ខណ៍អក្សរ ។

ចំពោះការឃាត់ខ្លួនលើបុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវឲ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនលើបុគ្គលនោះដោយប្រាប់ពីមូលហេតុនៃការឃាត់ខ្លួននោះ ។ ពិសេសមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់សាមីខ្លួនអោយបានដឹងថា ខ្លួនមានសិទ្ធិរកជំនួយមេធាវី ។ ក្នុងករណីចាំបាច់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាល ក៏អាចហៅអ្នកបកប្រែ និងជំនួយពីគ្រូពេទ្យឲ្យធ្វើការពិនិត្យទៅលើបុគ្គលដែលឃាត់ខ្លួននោះបានដែរ ។

ប្រសិនបើបុគ្គលដែលត្រូវឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីជូនដំណឹងដល់អាណាព្យាបាលរបស់បុគ្គលនោះ ហើយមិនអាចពន្យាពេលនៃការឃាត់ខ្លួនបានទេ ចំពោះអនីតិជន ។

### ១.៣ ការបញ្ជូនខ្លួន

នៅពេលដែលផុតកំណត់នៃការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួននោះត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញា ឬដោះលែងឲ្យមានសេរីភាពវិញ ដោយសេចក្តីសម្រេចនេះត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ។ ប្រសិនបើបុគ្គលដែលត្រូវឃាត់ខ្លួន ត្រូវបានបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ដូច្នេះបុគ្គលនោះត្រូវបានគេនាំខ្លួនយកទៅចំពោះមុខព្រះរាជអាជ្ញាភ្លាម ។ ក្នុងករណីថាការបង្ហាញខ្លួននៃបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារតែ

មានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ព្រះរាជអាជ្ញានឹងទទួលបាននូវរយៈពេលដ៏ឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។

## ២. ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋមនេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងការស៊ើបអង្កេតជាក់ស្តែងដែរ ដោយធ្វើការស្វែងរកនូវភស្តុតាងក្នុងការដាក់បន្ទុក និងធ្វើឡើងដោយពុំបានកំណត់នូវពេលវេលាជាក់លាក់ទេ ។ ការស៊ើប

[31] មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អង្កេតបឋម អាចដំណើរការទៅបានដោយមានការផ្តួចផ្តើមពីមន្ត្រីនគរបាលយុត្តិធម៌ ឬតាមការស្នើរសុំរបស់ព្រះរាជអាជ្ញា ក្នុងករណីដែលមានបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ឬករណីដែលចិរវេលានៃការស៊ើបអង្កេតជាក់ស្តែងបានកន្លងផុតទៅ ។

### ២.១ ការឆែកឆេរ

ការឆែកឆេរក្នុងករណីស៊ើបអង្កេតបឋមនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្នុងលក្ខខណ្ឌទទួលបានការយល់ព្រម និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ដោយការយល់ព្រមនោះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរថែមទាំងត្រូវសរសេរដោយដៃអ្នកកាន់កាប់ទីកន្លែងផ្ទាល់ ។ ក្នុងករណីបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរនោះនៅក្នុងកំណត់ហេតុ ក៏ត្រូវសរសេរឲ្យបានច្បាស់លាស់ថាអ្នកកាន់កាប់ទីកន្លែងពុំចេះអក្សរ និងយល់ព្រមឲ្យមានការឆែកឆេរ ។

បើសិនជាអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធមិនព្រមឲ្យមានការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីការអនុញ្ញាតឲ្យឆែកឆេរ តាមការស្នើរសុំពីព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញា ជាអ្នកដឹកនាំដោយផ្ទាល់នូវការឆែកឆេរនោះ ។

### ២.២ ការបញ្ជាឲ្យចូលខ្លួន

ការបញ្ជាឲ្យចូលខ្លួនត្រូវបានអនុវត្តទៅលើបុគ្គលណាដែលត្រូវបានសង្ស័យថា បានចូលរួមប្រព្រឹត្តបទល្មើស ហើយមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស្តាប់ចម្លើយ និងប្រមូលនូវព័ត៌មានរឿងហេតុនោះ ពីពួកគេ ។

បុគ្គលដែលកោះហៅចាំបាច់ត្រូវតែចូលទៅបង្ហាញខ្លួន ប្រសិនបើបុគ្គលណាមួយមានការរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឲ្យចូលខ្លួន ។ ការបញ្ជាឲ្យចូលខ្លួននេះ អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់នូវកងកម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះឲ្យចូលខ្លួន ហើយការបញ្ជាឲ្យចូលខ្លួននេះ ត្រូវមានចុះអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា រួមទាំងបោះត្រា ។

## ផ្នែកទី២៖ នីតិវិធីស៊ើបសួរ

### ១. ការអនុវត្តដីការបស់តុលាការ

នៅក្នុងកិច្ចនីតិវិធីនេះ នឹងធ្វើការសិក្សាពីដីការបស់តុលាការដែលជាការសម្រេចរបស់ចៅក្រមស៊ើបសួរក្នុងនោះមានដូចជា ដីកាសន្និដ្ឋានរឿងឲ្យស៊ើបសួរ (១.១) ដីកាបង្គាប់ឲ្យចាប់ខ្លួន (១.២) និងដីកាបង្គាប់ឲ្យឃុំខ្លួន (១.៣) ។

### ១.១ ដីកាសន្និដ្ឋានរឿងឲ្យស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ជាប្រភេទមួយនៃបណ្ដឹងអាជ្ញាក្នុងការចោទប្រកាន់ដែលតំណាងអយ្យការប្រើសម្រាប់បញ្ជូនសំណុំរឿងព្រហ្មទណ្ឌទៅចៅក្រមស៊ើបសួរ មានន័យថាការស៊ើបសួរ ត្រូវបានបើកដោយព្រះរាជអាជ្ញា តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ ដោយឡែក បើសិនជាពុំមានដីកានេះទេ ចៅក្រមស៊ើបសួរមិនអាចបំពេញនូវកិច្ចស៊ើបសួរណាមួយបានឡើយ ហើយការស៊ើបសួរនេះ អាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលបង្ហាញឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។ ចៅក្រមស៊ើបសួរ មានសិទ្ធិស៊ើបសួរតែអំពីអង្គហេតុដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានរឿងឲ្យស៊ើបសួរតែប៉ុណ្ណោះ ។

ក្នុងករណីបើមានលេចឡើងនូវអង្គហេតុថ្មីដែលជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ នោះចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនោះទៅកាន់ព្រះរាជអាជ្ញា ។ រីឯព្រះរាជអាជ្ញា អាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរលើអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ប៉ុន្តែប្រសិនបើគ្មានដីកាបញ្ជូនរឿងឲ្យស៊ើបសួរទេនោះ ចៅក្រមស៊ើបសួរក៏ពុំមានអំណាចក្នុងការស៊ើបសួរអំពីអង្គហេតុថ្មីនេះដែរ ។

### ១.២ ដីកាបង្គាប់ឲ្យចាប់ខ្លួន

ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ដោយការចេញដីកានេះ អាចត្រូវធ្វើទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។ ដីកាបង្គាប់ឲ្យចាប់ខ្លួននេះ ជាវិធានការមួយបង្ខិតបង្ខំដល់ជនត្រូវចោទ ដើម្បីឲ្យជននោះមានវត្តមានក្នុងតុលាការ ។ ដីកានេះ គឺជាការបញ្ជាដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ហើយជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ ។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា១៩៦ ចែងថា ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបានលុះត្រាតែ បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬបុគ្គលដែលបានពាក់ព័ន្ធ បានគេចខ្លួនមិនដឹងថាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ជាគោលការណ៍ មុននឹងចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងនេះទៅកាន់ព្រះរាជអាជ្ញាជាមុនសិន ដើម្បីឲ្យព្រះរាជអាជ្ញាពិនិត្យ និងផ្តល់យោបល់ ។ ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឲ្យចាប់ខ្លួនដោយបញ្ជាក់ពីមូលហេតុ ។ ដីកានេះ ត្រូវបានអនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ។

### ១.៣ ដីកាបង្គាប់ឲ្យឃុំខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យឃុំខ្លួន ដែលដីកានេះ ជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌល ឃុំខ្លួនឲ្យទទួលឃុំជនត្រូវចោទ ហើយចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានលុះត្រាតែជនត្រូវចោទជាកម្មវត្ថុ

នៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន មានន័យថាការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទនោះអាចជាភាពចាំបាច់ដូចជា ៖ ដើម្បីបញ្ចប់បទល្មើស ឬបង្កាបទល្មើសកុំឲ្យកើតមានជាថ្មី រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ជនរងគ្រោះ ឬមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ការពារសន្តិសុខឲ្យជនត្រូវចោទ និងដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស ។

ប្រធានពន្ធនាគារ ត្រូវតែទទួល និងឃុំខ្លួនបុគ្គល ដែលមានដីកាបង្គាប់ឲ្យឃុំខ្លួនរហូតទាល់តែបានទទួលដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ ។

### ២. ស្នើសុំឲ្យបំពេញកិច្ច

ជាគោលការណ៍ ចៅក្រមស៊ើបសួរអាចត្រូវបានភាគីនៃរឿងក្តី ស្នើសុំឲ្យមានការបំពេញកិច្ចស៊ើបសួរ ប្រសិនបើគេយល់ឃើញថា ការបំពេញកិច្ចណាមួយនោះមានប្រយោជន៍ដល់រឿងក្តី ។ អ្នកដែលមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរការបំពេញកិច្ចមានដូចជា ដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទ ។

ដូចគ្នានេះដែរ ព្រះរាជអាជ្ញាក៏អាចស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរបានផងដែរ កាលណាព្រះរាជអាជ្ញាយល់ឃើញថា ការបំពេញនេះ ព្រះរាជអាជ្ញាត្រូវធ្វើឡើងតាមរយៈសេចក្តីសន្និដ្ឋាន ។ ម្យ៉ាងវិញទៀត ប្រសិនបើចៅក្រមស៊ើបសួរមិនបានធ្វើការឆ្លើយតបក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេនោះ ព្រះរាជអាជ្ញាអាចប្តឹងទៅកាន់សភាស៊ើបសួរដោយផ្ទាល់តាមរយៈពាក្យសុំដើម្បីឲ្យមានការសម្រេចជំនួស ។

### ៣. ស្នើសុំឲ្យដោះលែង

ជាគោលការណ៍នៃវិធាននិរន្តរាយ ជនត្រូវចោទត្រូវមានសេរីភាពជានិច្ច ។ បន្ទាប់ពីមានការសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរក៏អាចដាក់ឲ្យជនត្រូវចោទស្ថិតនៅក្រៅឃុំជាបណ្តោះអាសន្នវិញផងដែរ កាលណាចៅក្រមស៊ើបសួរយល់ឃើញថាមានមូលហេតុសមរម្យ ឬក្រោយពីទទួលបានបណ្តឹងស្នើសុំពីជនត្រូវចោទ ។ ការដោះលែងនេះ ត្រូវធ្វើឡើងក្រោយពីព្រះរាជអាជ្ញាបានពិនិត្យសំណុំរឿង ហើយបានការផ្តល់យោបល់ទៅកាន់ចៅក្រមស៊ើបសួរវិញ ។

ក្នុងនេះផងដែរ ព្រះរាជអាជ្ញាមានតួនាទីដ៏សំខាន់មួយពោលគឺ ស្នើសុំឲ្យចៅក្រមស៊ើបសួរមានការដោះលែងជន-ត្រូវចោទ ។ ការស្នើសុំនេះ ធ្វើឡើងតាមរយៈពាក្យបណ្តឹងទៅកាន់ចៅក្រមស៊ើបសួរ ។ ក្នុងករណីពុំមានការឆ្លើយតបដោយចៅក្រមស៊ើបសួរ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹង ព្រះរាជអាជ្ញាអាចធ្វើការស្នើសុំទៅកាន់សភាស៊ើបសួរឲ្យសម្រេចជំនួសវិញ ។

## ៤. ស្នើសុំឲ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ជនត្រូវចោទដែលត្រូវបានគេចោទប្រកាន់អំពីបទល្មើសណាមួយ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអាចត្រូវបានគេដាក់ឲ្យស្ថិតក្រោយការត្រួតពិនិត្យតាមផ្លូវតុលាការ ប៉ុន្តែអនីតិជន មិនអាចត្រូវបានគេដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការឡើយ ។ ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាការដាក់ឲ្យជនត្រូវចោទស្ថិតនៅក្រៅឃុំដោយគោរពតាមកាតព្វកិច្ចមួយឬច្រើន ដែលតុលាការបានជ្រើសរើស និងកំណត់នៅក្នុងដីកាបង្គាប់ឲ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ ក្រៅពីគំនិតផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរផ្ទាល់ ព្រះរាជអាជ្ញាក៏អាចដាក់ឲ្យជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការផងដែរ តាម រយៈសេចក្តីសន្និដ្ឋានសរុបរបស់ខ្លួន។ បន្ទាប់ពីចៅក្រមស៊ើបសួរ បានទទួលនូវបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាហើយនោះ ចៅក្រមស៊ើបសួរត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ។ ផ្ទុយមកវិញ ប្រសិនបើចៅក្រមស៊ើបសួរ ពុំបានចេញសេចក្តីសម្រេចបន្ទាប់ពីរយៈពេល ៥ថ្ងៃ ទេនោះ ព្រះរាជអាជ្ញាអាចប្តឹងសុំទៅកាន់សភាស៊ើបសួរឲ្យធ្វើសេចក្តីសម្រេចជំនួស។

ដូចដែលបានរៀបរាប់ខាងលើ ព្រះរាជអាជ្ញាមានតួនាទីអាចស្នើសុំឲ្យចៅក្រមស៊ើបសួរដាក់ជនត្រូវចោទក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ បន្ថែមពីលើនេះ ព្រះរាជអាជ្ញាក៏អាចប្តឹងសុំឲ្យមានការលើកលែង ឬកែប្រែការត្រួតពិនិត្យដោយតុលាការ ហើយការកែប្រែវិញនោះ គឺសំដៅដល់ការកែប្រែខ្លឹមសារនៃកាតព្វកិច្ច ដោយក្នុងនោះរួមមាន ការលុបចោលកាតព្វកិច្ច និងការបញ្ចូលកាតព្វកិច្ចថ្មី ។ ដូចគ្នាទៅនឹងការស្នើសុំឲ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែរ បណ្តឹងសុំឲ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា ត្រូវមានការឆ្លើយតបមកវិញដោយចៅក្រមស៊ើបសួរក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃបន្ទាប់ពីទទួលបានបណ្តឹង បើពុំដូច្នោះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅកាន់សភាស៊ើបសួរឲ្យធ្វើការសម្រេចជំនួសវិញ ។

## ៥. ប្រគល់វត្ថុចាប់យក

ព្រះរាជអាជ្ញា មានសមត្ថកិច្ចនៅក្នុងការបង្គាប់ឲ្យប្រគល់វត្ថុដែលចាប់យកទៅឲ្យម្ចាស់ដើមវិញ កាលណាព្រះរាជអាជ្ញាយល់ឃើញថា វត្ថុដែលចាប់យកមិនមានផលប្រយោជន៍ដល់ដំណើរការនៃការស្វែងរកការពិតនៅក្នុងរឿងក្តីទេនោះ ។ ដោយឡែក ចំពោះវត្ថុគ្រោះថ្នាក់ ឬខុសច្បាប់ ព្រះរាជអាជ្ញាមិនអាចប្រគល់ត្រឡប់មកវិញទេ ដោយព្រះរាជអាជ្ញាត្រូវធ្វើការរឹបអូស រក្សាទុកជាសម្បត្តិរដ្ឋ ឬបំផ្លាញចោល ។ ព្រះរាជអាជ្ញា មិនមានសមត្ថកិច្ចប្រគល់វត្ថុចាប់យកឡើយ កាលណាការចោទប្រកាន់ត្រូវបានធ្វើឡើងដោយយុត្តាធិការស៊ើបសួរ ឬយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ។ ការប្រគល់វត្ថុចាប់យកនេះ ក្នុងករណីនេះអាចធ្វើទៅបាន ដរាបណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទជាស្ថាពរតែប៉ុណ្ណោះ ។ ការសម្រេចនេះ ព្រះរាជអាជ្ញាអាចធ្វើឡើងដោយការសម្រេចដោយឯកឯង ។

## ៦. ការឆែកឆេរ និងការធ្វើកោសលវិច័យ

### ៦.១ ការឆែកឆេរ

នៅក្នុងដំណាក់កាលនេះ ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរដោយការឆែកឆេរ ។ ការឆែកឆេរនេះត្រូវបានធ្វើឡើងដោយមន្ត្រីនគរបាលដែលដឹកនាំដោយព្រះរាជអាជ្ញា បន្ទាប់ពីចៅក្រមស៊ើបសួរធ្វើសេចក្តីសម្រេចឲ្យធ្វើការឆែកឆេរ ។ ការឆែកឆេរក្នុងដំណាក់កាលនេះ ក៏មិនមានលក្ខណៈខុសគ្នាពីការឆែរឆេរក្នុងដំណាក់កាលស៊ើបអង្កេតដែរ គឺការឆែកឆេរត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេនោះ ត្រូវធ្វើឡើងនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលខ្លួនចាត់តាំង ប៉ុន្តែសាក្សីនោះមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។ ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ (ពីរ) នាក់ ។

### ៦.២ ការធ្វើកោសលវិច័យ

ហេតុដែលនាំឲ្យមានការធ្វើកោសលវិច័យ គឺអាស្រ័យទៅលើករណីមួយចំនួនផ្នែកបញ្ហាបច្ចេកទេសបានកើតឡើង នោះចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ។ ការធ្វើកោសលវិច័យនេះ ត្រូវធ្វើឡើងដោយអ្នកជំនាញដែលមានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិ ឬដោយអ្នកជំនាញដែលចេញពីការចាត់តាំង ។

ក្នុងករណី ចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ នោះចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដែលមានសំអាងហេតុ ។ ដីកាសម្រេចនោះ ត្រូវធ្វើឡើងក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បើពាក្យសុំចេញដោយព្រះរាជអាជ្ញា និង ១(មួយ) ខែ បើសិនពាក្យសុំនោះចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដោយត្រូវជូនដំណឹងឲ្យអ្នកប្តឹងសុំជាបន្ទាន់នូវដីកាសម្រេចនោះ ។

នៅពេលដែលការធ្វើកោសលវិច័យបានបញ្ចប់ អ្នកជំនាញត្រូវធ្វើរបាយការណ៍អំពីការធ្វើកោសលវិច័យនោះ ដែលត្រូវពណ៌នាយ៉ាងច្បាស់លាស់អំពីប្រតិបត្តិការរបស់ខ្លួន ហើយធ្វើសេចក្តីសន្និដ្ឋាន ។ បន្ទាប់ពីរបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចរាល់ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានទៅដល់ព្រះរាជអាជ្ញា ។

## ៧. ប្តឹងមោឃភាព និងប្តឹងមោឃកម្ម

ការប្តឹងមោឃភាព និងការប្តឹងមោឃកម្មមិនដូចគ្នាទេ ។ ការប្តឹងមោឃភាព សំដៅដល់ការប្តឹងចំពោះទម្រង់លិខិតនៃនីតិវិធី ។ ចំណែកឯការប្តឹងមោឃកម្ម គឺសំដៅដល់ការប្តឹងចំពោះកិច្ចនៃនីតិវិធី ។ ទម្រង់លិខិត ឬកិច្ចនៃនីតិវិធីដែលមានមោឃភាព គឺជាទម្រង់លិខិតទាំងឡាយណាដែលធ្វើឡើងដោយមានការបំពានទៅនឹងវិធានឬទម្រង់ការសំខាន់ៗដែលបានចែងដោយច្បាប់ និងជាពិសេសវាបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិការពារខ្លួននៃភាគីដែលបានរងការបំពាន ។ នៅក្នុងវិធាននរន្តរាយ ព្រះរាជអាជ្ញាមានសមត្ថកិច្ចនៅក្នុងការប្តឹងឲ្យសភាស៊ើបសួរឲ្យធ្វើមោឃភាព ឬមោឃកម្មទៅលើលិខិត និងកិច្ចនៃនីតិវិធីណាមួយ ដែលខ្លួនយល់ឃើញថា លិខិត ឬកិច្ចនោះ

មានមោឃភាព ។ ការប្ដឹងនេះត្រូវធ្វើឡើងតាមរយៈពាក្យសុំដែលមានសំអាងហេតុ បញ្ជូនទៅកាន់សភាស៊ើបសួរ បន្តការស៊ើបសួរដោយខ្លួនឯងតែម្ដង ។

### ៨. ការធ្វើសេចក្ដីសន្និដ្ឋានស្ថាពរ

ក្រៅពីធ្វើការចោទប្រកាន់ និងបញ្ជូនជនជាប់ចោទទៅកាន់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាមានតួនាទីសំខាន់មួយទៀតគឺ ការធ្វើសេចក្ដីសន្និដ្ឋានស្ថាពរ ក្រោយពីធ្វើចៅក្រមស៊ើបសួរ បានបិទបញ្ចប់ការស៊ើបសួរ ។ ថ្វីត្បិត តួនាទីនេះត្រូវប្រព្រឹត្តិឡើងនៅក្នុងដំណាក់កាលនៃវិធាននរន្តរាយក៏ដោយ តែវាពិតជាមានសារៈសំខាន់ខ្លាំងណាស់ដល់ប្រសិទ្ធិភាពកិច្ចនីតិវិធី និងសិទ្ធិសេរីភាពរបស់ជនជាប់ចោទ ពោលគឺនៅក្នុងដំណាក់កាលនេះ បានបើកសិទ្ធិឲ្យព្រះរាជអាជ្ញាសារជាថ្មីម្ដងទៀត នៅក្នុងពិនិត្យ ឆ្លើយតប ឬស្នើសុំឲ្យមានការស៊ើបសួរម្ដងទៀត ។

កាលណាចៅក្រមស៊ើបសួរយល់ឃើញថាកិច្ចស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅកាន់ភាគីនៃរឿងក្ដី និងព្រះរាជអាជ្ញា ។ បន្ទាប់ពីមានការជូនដំណឹងរយៈពេល ២ថ្ងៃ ចៅក្រមស៊ើបសួរនឹងបង្វិលសំណុំរឿងទាំងមូលទៅកាន់ព្រះរាជអាជ្ញា ដើម្បីធ្វើការពិនិត្យ និងធ្វើសេចក្ដីសន្និដ្ឋានស្ថាពរ ។ ក្រោយពីទទួលបាននូវសំណុំរឿង ក្នុងករណីព្រះរាជអាជ្ញាយល់ឃើញថា មានភាពចាំបាច់ក្នុងការស៊ើបសួរម្ដងទៀត ព្រះរាជអាជ្ញាអាចស្នើសុំចៅក្រមស៊ើបសួរឲ្យបំពេញកិច្ចណាមួយដែលខ្លួនយល់ថាប្រយោជន៍ ។ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបានសំណុំរឿង ក្នុងករណីជនជាប់ចោទជាប់ឃុំ និង ៣០(សាមសិប) ថ្ងៃ ក្នុងករណីជនជាប់ចោទស្ថិតនៅក្រៅឃុំ ។

ចំពោះករណីព្រះរាជអាជ្ញាមានការយល់ឃើញដូចគ្នានឹងចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់បន្ទាប់ពីពិនិត្យសំណុំរឿងរួច នោះព្រះរាជអាជ្ញាត្រូវធ្វើសេចក្ដីសន្និដ្ឋានស្ថាពរដោយមានសំអាងហេតុ និងជាលាយលក្ខណ៍អក្សរ ។ ក្នុងដំណាក់កាលនេះ ព្រះរាជអាជ្ញាក៏អាចធ្វើការប្ដឹងសុំឲ្យបញ្ជូនជនជាប់ចោទទៅកាន់តុលាការ ឬលើកលែងការចោទប្រកាន់ផងដែរ ។

## ផ្នែកទី៣៖ នីតិវិធីជំនុំជម្រះ

### ១. កោះហៅ

#### ១.១ កោះហៅជនជាប់ចោទ

ក្នុងករណីដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឲ្យចូលសវនាការ តាមរយៈដីកាកោះហៅ ។ ព្រះរាជអាជ្ញាត្រូវធ្វើដីកាកោះហៅជនជាប់ចោទ ដោយមាននិទ្ទេសដូចជាអត្តសញ្ញាណជនជាប់ចោទ កាលបរិច្ឆេទ និងទីកន្លែងកំណើតនៃជនជាប់ចោទ លំនៅដ្ឋាននៃជនជាប់ចោទ ការយោងដីកា ឬសាលដីកាបញ្ជូនរបស់តុលាការដែលត្រូវទទួលបណ្ដឹងដើម្បជំនុំជម្រះ ទីកន្លែង កាលបរិច្ឆេទ និងម៉ោងសវនាការ កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា និងបញ្ជាក់អំពីសិទ្ធិមានមេធាវីការពារខ្លួន ។

ដីកាកោះហៅ អាចត្រូវបានប្រគល់ជូនជនជាប់ចោទដោយផ្ទាល់ដៃរបស់ព្រះរាជអាជ្ញា ។ ក្នុងករណីនេះព្រះរាជអាជ្ញាត្រូវធ្វើការប្រគល់ចុងដីកាកោះឲ្យជនជាប់ចោទ ដោយព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសលើដើមដីកាអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់ ព្រមទាំងឲ្យជនជាប់ចោទចុះហត្ថលេខានៅលើដើមដីកានោះផងដែរ ។

ការប្រគល់ដីកាកោះហៅដល់ជនជាប់ចោទ ក៏អាចធ្វើបានតាមរយៈមធ្យោបាយផ្សេងៗដែលមានចែងដោយក្រមព្រហ្មទណ្ឌដែរ ជាអាទិ៍ តាមរយៈអាជ្ញាសាលា ក្រឡាបញ្ជី អាជ្ញាធរពន្ធនាគារ ។ ល ។ ចំពោះរយៈពេលនៃការបញ្ជូនដីកាកោះវិញនោះ ព្រះរាជអាជ្ញា ត្រូវគោរពតាមវិធានរយៈពេលស្របតាមទីកន្លែងរស់នៅជាក់ស្តែងរបស់ជនជាប់ចោទដែលច្បាប់បានកំណត់ ។

### ១.២ កោះហៅដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ

នៅក្នុងដំណាក់កាលនៃនីតិវិធីជំនុំជម្រះ ការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ក៏ជាតួនាទីនិងភារកិច្ចរបស់ព្រះរាជអាជ្ញាដែរ ។ ដូចគ្នាទៅនឹងជនជាប់ចោទដែរ ព្រះរាជអាជ្ញាកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឬជនរងគ្រោះតាមរយៈដីកាកោះហៅ ។ ការកោះហៅជនរងគ្រោះត្រូវធ្វើឡើង កាលណាជនរងគ្រោះមិនបានធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។

ដីកាកោះហៅនេះ ព្រះរាជអាជ្ញាត្រូវមាននិទ្ទេសដូចជា អត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះលំនៅឋានដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់តុលាការដែលត្រូវជំនុំជម្រះ ទីកន្លែង កាលបរិច្ឆេទ ពេលវេលានៃសវនាការ កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា បញ្ជាក់អំពីឋានៈជាជនរងគ្រោះ ។

នីតិវិធីនៃការប្រគល់ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ត្រូវធ្វើឡើងដូចគ្នាទៅនឹងការប្រគល់ដីកាកោះហៅដល់ជនជាប់ចោទដែរ ។

### ១.៣ កោះហៅអ្នកពាក់ព័ន្ធ

ការកោះហៅអ្នកពាក់ព័ន្ធមកកាន់សវនាការពិតជាមានសារៈសំខាន់ណាស់ ចំពោះសក្ខីកម្មនៃរឿងក្តី និងដំណើរការជំនុំជម្រះ ។ ហេតុដូចនេះហើយ ក្រៅពីការកោះហៅជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ការកោះហៅជនពាក់ព័ន្ធក៏ជាតួនាទី និងភារកិច្ចរបស់ព្រះរាជអាជ្ញាដែរ ។ អ្នកពាក់ព័ន្ធនៅក្នុងចំណុចនេះគឺសំដៅដល់សាក្សី អ្នកជំនាញ អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ ដីកាកោះហៅជនពាក់ព័ន្ធខាងលើនេះ ព្រះរាជអាជ្ញាត្រូវមាននិទ្ទេសដូចជា អត្តសញ្ញាណ លំនៅដ្ឋាន ឈ្មោះជនជាប់ចោទ តុលាការដែលត្រូវជំនុំជម្រះ ទីកន្លែង កាលបរិច្ឆេទ និងម៉ោងសវនាការ កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា និងបញ្ជាក់អំពីឋានៈនៃអ្នកពាក់ព័ន្ធ ហើយចំពោះអ្នកដែលមានឋានៈជាសាក្សី ត្រូវបញ្ជាក់បន្ថែមអំពីលក្ខខណ្ឌដែលអាចត្រូវបានផ្តន្ទាទោសតាមច្បាប់ ។

នីតិវិធីនៃការប្រគល់ដីកាកោះហៅអ្នកពាក់ព័ន្ធ ធ្វើឡើងដូចគ្នាទៅនឹងការប្រគល់ដីកាកោះហៅដល់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះដែរ ។

## ២. អញ្ជើញមេធាវី

មេធាវី ជាបុគ្គលចាំបាច់មួយនៅក្នុងអង្គសវនាការក្នុងនាមជាអ្នកការពារសិទ្ធិសេរីភាពរបស់ភាគី កាលណាជន-ត្រូវចោទមានមេធាវីអម ដូចនេះរាល់ពេលដែលដីកាត្រូវបានជូនដំណឹងដល់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាក៏ត្រូវជូនដំណឹងនេះដល់មេធាវីផងដែរ ។ ព្រះរាជអាជ្ញា ត្រូវកោះអញ្ជើញមេធាវី តាមផ្លូវប្រៃសណីយ៍ ឬតាមផ្លូវរដ្ឋបាល ហើយក្នុងលក្ខខណ្ឌចាំបាច់ ការកោះហៅអាចធ្វើបានតាមគ្រប់មធ្យោបាយចំណែកឯវិធីហៅ និងកាលបរិច្ឆេទនៃការកោះហៅ ត្រូវចុះនិទ្ទេសដោយក្រឡាបញ្ជីនៅក្នុងសំណុំរឿង។

## ៣. ដេញដោល

នៅក្នុងអំឡុងពេលពិភាក្សាដេញដោលនៃសវនាការ ព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរសួរទៅកាន់ជនជាប់ចោទ ។ ក្រៅពីនេះ ព្រះរាជអាជ្ញាក៏អាចចោទជាសំណួរទៅកាន់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ផងដែរ ។ គ្រប់សំណួរទាំងឡាយដែលត្រូវបានចោទសួរ ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ វៀរលែងតែមានការតវ៉ា នោះប្រធានសវនាការអាចធ្វើការសម្រេចដោយឥស្សរចិត្តរបស់ខ្លួនថាសំណួរណាមួយនោះ មានភាពចាំបាច់ក្នុងការចោទឡើងដែរឬទេ ។

## ៤. ធ្វើសេចក្តីសន្និដ្ឋាន

បន្ទាប់ពីកិច្ចពិភាក្សាដេញដោលត្រូវបានបញ្ចប់ ព្រះរាជអាជ្ញាមានតួនាទីនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ ។ នៅក្នុងដំណើរការនេះ ព្រះរាជអាជ្ញាក៏អាចឆ្លើយតបទៅកាន់មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនជាប់ចោទបានផងដែរ ។ លើសពីនេះ ព្រះរាជអាជ្ញាក៏អាចធ្វើការប្តឹងសុំទៅកាន់ប្រធានសវនាការនៅពេលដែលខ្លួនឡើងធ្វើសេចក្តីសន្និដ្ឋាន កាលណាខ្លួនយល់ឃើញថា ការប្តឹងសុំនោះមានភាពសមស្រប និងមានប្រយោជន៍ដល់យុត្តិធម៌នៃរឿងក្តី ។

# ផ្នែកទី៤៖ នីតិវិធីដោយឡែក

## ១. អធិការកិច្ចពន្ធនាគារ

ព្រះរាជអាជ្ញា មិនត្រឹមតែមានមុខងារក្នុងកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះទេ ពោលគឺព្រះរាជអាជ្ញានៅមានតួនាទី និងភារកិច្ចនៅក្នុងពន្ធនាគារថែមទៀតផង ។ ព្រះរាជអាជ្ញា ត្រូវមានភារកិច្ចនៅក្នុងការធ្វើអធិការកិច្ចជាប្រចាំលើពន្ធនាគារ ។ ក្នុងកាលៈទេសៈពន្ធនាគារបានជួបនឹងឧប្បត្តិហេតុធ្ងន់ធ្ងរ ត្រូវធ្វើការជូនដំណឹងទៅកាន់ព្រះរាជអាជ្ញាជាបន្ទាន់ និងជាពិសេសកាលណាមានទណ្ឌិតណាម្នាក់បានរត់ចេញពីពន្ធនាគារ មណ្ឌលឃុំខ្លួន ព្រះរាជអាជ្ញា

ត្រូវចេញបញ្ជាស្វែងរកចាប់ខ្លួន តាមរយៈដីកាបង្គាប់ឲ្យចាប់ខ្លួន ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ដោយការជូនដំណឹង និងផ្តល់យោបល់ដោយព្រះរាជអាជ្ញា។

## ២. ការដោះលែងដោយមានលក្ខខណ្ឌ

ព្រះរាជអាជ្ញា ក៏បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការដោះលែងទណ្ឌិតណាម្នាក់ ដោយមានលក្ខខណ្ឌផងដែរ ។ ថ្វីត្បិត ការដោះលែងនេះត្រូវបានធ្វើឡើងដោយប្រធានតុលាការជាន់ដំបូងក៏ដោយ ប៉ុន្តែដើម្បីធ្វើការស្នើសុំនេះទៅបាន នៅពេលណាដែលប្រធានតុលាការស្នើសុំយោបល់ពីព្រះរាជអាជ្ញាជាមុនសិន ទើបប្រធានតុលាការធ្វើការដាក់សំណើរជូនទៅកាន់ប្រធានតុលាការ អំពីការដោះលែងទណ្ឌិតណាម្នាក់ដោយមានលក្ខខណ្ឌ ២យ៉ាងគឺ ៖ លក្ខខណ្ឌទាក់ទងនឹងគំនិតមាយាទ (២.១) និងលក្ខខណ្ឌទាក់ទងនឹងថេរវេលានៃទោសដែលបានអនុវត្តរួច (២.២) ។

### ២.១ លក្ខខណ្ឌទាក់ទងនឹងគំនិតមាយាទ

ទណ្ឌិតណាម្នាក់អាចត្រូវបានគេដោះលែងឲ្យមានសេរីភាពឡើងវិញ ប្រសិនបើគេបានពិនិត្យឃើញថាទណ្ឌិតនោះមានគំនិតមាយាទ និងមានសម្បទានគ្រប់គ្រាន់ សមល្មម ដែលអាចបញ្ចូលទៅជាសមាជិកនៃសង្គមវិញបាន ។

### ២.២ លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលបានអនុវត្តរួចរាល់

ទណ្ឌិតណាម្នាក់អាចត្រូវបានគេដោះលែងឲ្យមានសេរីភាពឡើងវិញ ប្រសិនបើទណ្ឌិតនោះបានអនុវត្តទោសចំនួនពាក់កណ្តាលនៃទោសសរុប ទោសតិចជាង ឬស្មើមួយឆ្នាំ)ំ២ ឬ ទណ្ឌិតបានអនុវត្តទោសចំនួន (/៣ នៃទោស ក្នុងករណីផ្សេងពីនេះ ។ ចំពោះទណ្ឌិតដែលត្រូវអនុវត្តទោសអស់មួយជីវិត ក៏អាចមានឱកាសទទួលបានការដោះលែងដោយមានលក្ខខណ្ឌដែរ ប្រសិនទណ្ឌិតនោះបានអនុវត្តទោស ២០ ឆ្នាំរួច[32] (ម្តៃ)។ ចំពោះទណ្ឌិតដែលជាប់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម គ្មានការបន្ធូបន្ថយទោស ឬការដោះលែងតាមលក្ខខណ្ឌនេះបានទេ ។

## ៣. ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ទណ្ឌិតដែលធ្លាប់បានប្រកាសទោសដោយសាលក្រម អាចទទួលបានសម្បទានឡើងវិញតាមផ្លូវតុលាការកាលណាទណ្ឌិតនោះបានបំពេញនូវលក្ខខណ្ឌរយៈពេលទៅតាមប្រភេទទោសរបស់ខ្លួន ហើយបានធ្វើពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញទៅកាន់ព្រះរាជអាជ្ញា ដោយបានដាក់ជូននូវភស្តុតាងចាំបាច់ដែលទាមទារ ។ ប្រសិនបើបានផ្តល់នីតិសម្បទាឡើងវិញដល់ទណ្ឌិតដែលបានស្នើសុំ ព្រះរាជអាជ្ញាមានភារកិច្ចត្រូវចាត់ការស៊ើប

[32] មាត្រា ៥១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អង្កេតអំពីសីលធម៌របស់ទណ្ឌិតនោះ នៅគ្រប់ទីកន្លែងដែលទណ្ឌិតធ្លាប់បានរស់នៅ តាំងពីពេលដែលបានដោះលែងឲ្យមានសេរីភាពវិញ ។ ក្រោយពីបានធ្វើការស៊ើបអង្កេតហើយនោះ ព្រះរាជអាជ្ញាត្រូវបញ្ជូនសំណុំរឿងទៅកាន់អគ្គព្រះរាជអាជ្ញាដើម្បីធ្វើការសម្រេច ដោយមានយោបល់ និងសំអាងហេតុភ្ជាប់ទៅជាមួយ ។ បន្ទាប់ពីទទួលបានសំណុំរឿងពីព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញាត្រូវប្តឹងទៅកាន់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដោយហេតុថាមានតែសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ប៉ុណ្ណោះ ដែលមានសមត្ថកិច្ចសម្រេចផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ[33] ។

[33] មាត្រា ៥៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន និងផ្តល់យោបល់

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវតាមរយៈបទបញ្ញត្តិច្បាប់ និងឯកសារផ្សេងៗទាក់ទងជាមួយនឹងស្ថាប័នអយ្យការ ដែលផ្តោតសំខាន់លើខ្លឹមសាររបស់ ប្រវត្តិស្ថាប័នអយ្យការ ក្របខណ្ឌព្រះរាជអាជ្ញា រចនាសម្ព័ន្ធ និងគោលការណ៍នៃអង្គការអយ្យការ, មុខងារ និងតួនាទីអង្គការអយ្យការនៅអមតុលាការនីមួយៗ នីតិវិធី និងចំណាត់ការរបស់អយ្យការក្នុងសំណុំរឿងព្រហ្មទណ្ឌ ដែលជាស្នូលដ៏សំខាន់ក្នុងការសិក្សាស្វែងយល់លម្អិតលើប្រធានបទទាំងមូលទាក់ទងនឹងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ។

មានលក្ខខណ្ឌជាច្រើនទៀត ដែលតម្រូវឲ្យតំណាងអយ្យការត្រូវតែគោរពតាមបទបញ្ញត្តិជាចាំបាច់ចំពោះចំណាត់ការលើបណ្តឹងរបស់ខ្លួន ។ រវាងការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការ គឺជាជម្រើសមួយដែលតំណាងអយ្យការត្រូវថ្លឹងថ្លែងឲ្យបានម្មត់ចត់ជាទីបំផុត នៅមុនពេលដែលធ្វើសេចក្តីសម្រេច ។ ជារួមការអនុវត្តតួនាទី សិទ្ធិអំណាចរបស់តំណាងអយ្យការត្រូវបានគោរពតាមបទបញ្ញត្តិច្បាប់យ៉ាងខ្ជាប់ខ្ជួន ទើបបានជាការមុខងារជាក់ស្តែងបង្ហាញនូវភាពស៊ីសង្វាក់គ្នាជាមួយបទបញ្ញត្តិដែលមានជាធរមាន ។ ជាក់ស្តែងព្រះរាជអាជ្ញាពុំមានបញ្ហានៃការកកស្ទះសំណុំរឿងក្នុងការអនុវត្តមុខងារនោះទេ ។ តែផ្ទុយទៅវិញគាត់ជាផ្នែកមួយដ៏សំខាន់ក្នុងការជួយសម្រួលបញ្ហាខាងនីតិវិធី ការចោទប្រកាន់តាមរយៈការបញ្ជូនរឿងទៅចៅក្រមដើម្បីជម្រះផ្ទាល់ តាមនីតិវិធីការបញ្ជូនទៅជម្រះផ្ទាល់ និងការបង្ហាញខ្លួនភ្លាមសម្រាប់បទមជ្ឈិមដែលត្រូវបានអនុញ្ញាត ។ ម៉្យាងវិញទៀត តំណាងអយ្យការជាតួអង្គដ៏សំខាន់ ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈ និងការពារផលប្រយោជន៍សង្គម ការពារផលប្រយោជន៍ទូទៅ ។ ដូចនេះតំណាងអយ្យការត្រូវបំពេញការងារដោយមានឆន្ទៈ មានទំនួលខុសត្រូវ និងមានមនសិកាខ្ពស់ដើម្បីស្វែងរកយុត្តិធម៌ជូនសង្គមជាតិ ។

ជាទីបញ្ចប់ ក្រុមសិក្សាស្រាវជ្រាវ លើគម្រោងការសរសេរបញ្ចប់សិក្សានេះ បានស្តែងចេញនូវលទ្ធផលនៃការស្វែងយល់បន្ថែមជាមួយនឹងកម្រងរបាយការណ៍ដែលបានទទួលចំណេះដឹងផ្ទាល់ពីកន្លែងចុះកម្មសិក្សា និងឆ្លុះបញ្ចាំងពីការរកឃើញអំពីចំណុចខ្វះចន្លោះ ឬរបបគំហើញនៃចំណេះដឹងថ្មីដែលធ្វើឲ្យយើងស្វែងយល់កាន់តែច្បាស់ជាមួយនឹងអនុសាសន៍យល់ឃើញជាមួយលើប្រធានបទ ។ ក្រុមយើងខ្ញុំ មានសង្ឃឹមយ៉ាងមុតមាំថា ប្រសិនបើអ្នកអនុវត្តច្បាប់ទាំងអស់ចូលរួមចំណែកសាមគ្គីគ្នាបម្រើសង្គមតាមរយៈការផ្តល់ភាពយុត្តិធម៌ មានឆន្ទៈដោះស្រាយប្រកបដោយមនសិការនោះពិតជាអាចដោះស្រាយបានរាល់នូវបញ្ហាទាំងឡាយជាក់ជាមិនខាន មិនតែប៉ុននោះវាថែមទាំងអាចកាត់បន្ថយនូវភាពអយុត្តិធម៌ និងទទួលបាននូវទំនុកចិត្តរបស់ប្រជាជនលើវិស័យយុត្តិធម៌កាន់តែមានភាពល្អប្រសើរឡើងវិញ ។

ដើម្បីចូលរួមចំណែកក្នុងការធ្វើសេចក្តីសម្រេចចិត្តឲ្យបានល្អប្រសើរប្រកបដោយភាពយុត្តិធម៌ ក្រុមស្រាវជ្រាវ សូមជូននូវយោបល់ខ្លះៗចំពោះការបំពេញការងាររបស់តំណាងអយ្យការដូចខាងក្រោម ៖

ក. នៅគ្រប់ពេលដែលធ្វើចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ តំណាងអយ្យការគប្បីធ្វើការស៊ើបអង្កេតផ្ទាល់ដល់ទីកន្លែងកើតហេតុភ្លាមៗ ប្រមូលភស្តុតាងឲ្យបានគ្រប់គ្រាន់មុននឹងធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យចៅក្រមស៊ើបសួរ ។ ព្រោះជាក់ស្តែងតំណាងអយ្យការពុំសូវបានចុះស៊ើបអង្កេតផ្ទាល់ពេលរឿងហេតុកើតឡើងភ្លាមៗនោះទេ ដោយលោកច្រើនប្រមូលភស្តុតាង ឬឲ្យមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកដែលចុះដល់ទីកន្លែងកើតហេតុ ។

ខ. ត្រូវបំពេញមុខងារដោយផ្អែកលើគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់

គ. តំណាងអយ្យការផ្អែកលើគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់

ឃ. តំណាងអយ្យការគួរពង្រឹងទំនាក់ទំនងល្អជាមួយយុត្តាធិការស៊ើបសួរ នគរបាលយុត្តិធម៌ ឬមន្ត្រីសាធារណៈដទៃទៀតដែលពាក់ព័ន្ធលើការអនុវត្តមុខងាររបស់ខ្លួន

ង. គ្រប់សេចក្តីផ្អែកលើបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ជាធរមាន និងគួរគប្បីបញ្ជាក់សំអាងហេតុត្រឹមត្រូវដើម្បីធ្វើការចោទប្រកាន់ ឬសេចក្តីសម្រេចណាមួយ ដើម្បីធានាថាភាគីនៃរឿងក្តីដែលខ្លួនកំពុងធ្វើចំណាត់ការទទួលបានយុត្តិធម៌ និងទទួលយកនូវការអនុវត្តនោះ

ច. តំណាងអយ្យការគួរតែមានឯករាជ្យភាពដូចចៅក្រមជំនុំជម្រះដែរ ក្នុងការអនុវត្តបណ្តឹងអាជ្ញាដោយពុំទាមទារឲ្យមានគោលការណ៍ឋានានុក្រមដូចច្បាប់បានកំណត់នោះទេ ។

# អនុសាសន៍

តបតាមការសិក្សាខាងលើ និងដោយបានមើលឃើញពីសារៈសំខាន់នៃតួនាទី និងភារកិច្ចរបស់ព្រះរាជអាជ្ញាក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសំណូមពរដល់មន្ត្រីដែលជាអ្នកប្រតិបត្តិផ្នែកច្បាប់ ជាពិសេសព្រះរាជអាជ្ញាគួរណាគប្បីនូវ ៖

១. ការបំពេញកាតព្វកិច្ចរបស់ខ្លួនប្រកបដោយអនាគតិទាំង៤យ៉ាង គឺ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ ដើម្បីការពារថែរក្សានូវតម្លៃច្បាប់ និងលើកកម្ពស់ជំនឿទុកចិត្តពីសាធារណៈជន ពោលគឺ ធ្វើការសម្រេចដោយសេចក្ដីមិនលំអៀង ឈរលើគោលការណ៍ច្បាប់ មិនស៊ីសំណូក មិនទទួលការគាបសង្កត់ ការគំរាមកំហែង ការជ្រៀតជ្រែក ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី ដើម្បីបង្ហាញឲ្យគេមើលឃើញថា ជាបុគ្គលមានចរិតយុត្តិធម៌ ។

២. ត្រូវបំពេញកាតព្វកិច្ចដោយយកចិត្តទុកដាក់ និងម្មត់ចត់ចំពោះគ្រប់នីតិវិធីទាំងឡាយ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍សេរីភាពជាចម្បង ដោយជៀងវាងឲ្យបានពីស្លាកស្នាមទុរយសនៃការឃុំខ្លួនមុនការជម្រះក្ដី ការចោទប្រកាន់ និងការផ្ដន្ទាទោស ព្រមទាំងពីផលមិនល្អដែលកើតមានពីការដាក់ឲ្យជាប់ពន្ធនាគារ ។

៣. ត្រូវធ្វើការចោទប្រកាន់ដោយផ្អែកលើមូលដ្ឋាន និងភស្តុតាងសមរម្យ ដោយអាចជឿជាក់បានថា ភស្តុតាង និងមូលដ្ឋានទាំងអស់នោះបានមកពីវិធីស្របច្បាប់ ហើយពុំបានកើតចេញពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ដូចជា ការធ្វើទារុណកម្ម ទណ្ឌកម្ម អំពើឃោរឃៅ អមនុស្សធម៌ ឬអំពើបន្ទាបបន្ថោកនានា ។

ជារួមមក ព្រះរាជអាជ្ញាគួរគប្បីបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ ឆាប់រហ័សប្រកបទៅដោយស្មារតីទទួលខុសត្រូវខ្ពស់ ត្រូវគោរព និងការពារសេចក្ដីថ្លៃថ្នូររបស់មនុស្ស លើកកម្ពស់សិទ្ធិមនុស្ស និងត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនជានិច្ច ។

# ឯកសារយោង


- រដ្ឋធម្មនុញ្ញរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦
- រដ្ឋធម្មនុញ្ញរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨១
- រដ្ឋធម្មនុញ្ញសម័យរដ្ឋកម្ពុជា ឆ្នាំ១៩៨៩
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមពិភាក្សាព្រហ្មទណ្ឌ ឆ្នាំ១៩៣៧
- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
- ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ២០១៤
- ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤
- ព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥
- អនុក្រឹត្យលេខ៩ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០២ និងព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០០៥
- អនុក្រឹត្យលេខ ១១៧ អនក្របក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨
- អនុក្រឹត្យលេខ ១១៨ អនក្របក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨
- សៀវភៅស្តីពីអយ្យការ : ប្រវត្តិ និងការសិក្សាប្រៀបធៀប (កុយនាម និង ឡុង បញ្ញារុធ ឆ្នាំ២០០៦)
- សេចក្តីផ្តើមនីតិ
- ប្រវត្តិតុលាការយោធាពីឆ្នាំ ១៩៥៤-២០២០ បោះពុម្ពផ្សាយឆ្នាំ២០២០

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១[34]

[34] សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៨៧, ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០, លេខ ៤២៩ អ.យ.ដ, របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
**សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៨៧**
ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០

ក្រឡាបញ្ជី ថេង វិធី
បន្ទប់ "ក" ជាន់ទី២

## <u>ដីកាកោះ</u>

**យើង** **តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

អញ្ជើញឈ្មោះ :

អាសយដ្ឋាន : ផ្ទះលេខ HE១៤ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

អោយចូលទៅកាន់ : អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ (ជាន់ទី២ បន្ទប់ "ក")

នៅថ្ងៃទី : ...១១... ខែ ...មករា... ឆ្នាំ ២០២១ វេលាម៉ោង ...០៩:០០... ព្រឹក

ដើម្បី : ឆ្លើយបំភ្លឺ

ពីដំណើររឿង : ឆបោក
តាមបណ្តឹងរបស់ក្រុមហ៊ុនមានកម្រិត
( ) គ្រុប ដែលមានអ្នកតំណាងឈ្មោះ ( )

សាមីខ្លួនត្រូវអញ្ជើញ តាមលិខិតអញ្ជើញនេះអោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃ ច័ន្ទ ១២កើត ខែ [illegible] ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០២០

**តំណាងអយ្យការ**

**ស៊ិត-ចន្ណា:**
**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៨៧
ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០
លេខ ៤៣៩ អ.យ.ង

## ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង **ស៊ិន ចន្ទ្ធា** តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៨១៨៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**យល់ឃើញថា:**

០១. អវត្តមានបទល្មើស
- ☐ ១.១.អវត្តមានបទល្មើស

០២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់
- ☑ ២.១.ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

០៣. មូលហេតុគតិយុត្ត
- ☐ ៣.១.ការដកពាក្យបណ្តឹង
- ☐ ៣.២.ការលើកលែងទោសជាទូទៅ
- ☐ ៣.៣.មរណភាពជនល្មើស
- ☐ ៣.៤.ផុតអាជ្ញាយុកាល
- ☐ ៣.៥.និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- ☐ ៣.៦.អាជ្ញាអស់ជំនុំ
- ☐ ៣.៧.ការសម្របសម្រួលជាមួយរដ្ឋ
- ☐ ៣.៨.ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល
- ☐ ៣.៩.អភ័យឯកសិទ្ធិ
- ☐ ៣.១០.អនិយ័តភាពនៃនីតិវិធី
- ☐ ៣.១១.ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

០៤. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

[1] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំស្ថានភាពចាំបាច់



អាសយដ្ឋាន: អគារលេខ ២៥ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ
Address: #25, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855) - 23 88 20 59

☐ ៤.១.ការស្វែងរកមិនបានផល
☐ ៤.២.ការបោះបង់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង[2]
☐ ៤.៣.ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ
☐ ៤.៤.ការខកខានរបស់ដើមបណ្ដឹង
☐ ៤.៥.អាកប្បកិរិយារបស់ជនរងគ្រោះ
☐ ៤.៦.ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស
☐ ៤.៧.និយ័តកម្មដោយឯកឯង[3]
☐ ៤.៨.ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

០៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា
☐ ៥.១.ការផ្សះផ្សាការខូចខាតដោយ/ដល់អនីតិជន
☐ ៥.២.សន្ទានកម្ម[4]
☐ ៥.៣.អធិបញ្ញាផ្ដល់ការព្យាបាល
☐ ៥.៤.ជនរងគ្រោះ/ដើមបណ្ដឹងបោះបង់បណ្ដឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា
☐ ៥.៥.និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា
☐ ៥.៦.ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]
☐ ៥.៧.ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬនៃវិជ្ជាជីវៈ
☐ ៥.៨.ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

០៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងទៀត
☐ ៦.១.ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

០៧. ជនល្មើសមិនត្រូវបានស្គាល់
☐ ៧.១.ជនល្មើសមិនត្រូវបានស្គាល់

០៨. ជំនួយការអប់រំ
☐ ៨.១.ការផ្ដល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការសង្កេតផ្សេងៗ ៖** កាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤ ឈ្មោះ ------ ជាតំណាងក្រុមហ៊ុន --------- បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ------ មានអ្នកតំណាងឈ្មោះ -------- ស្តីពីការផ្ទេរសិទ្ធិដីសម្បទានសេដ្ឋកិច្ចទំហំ ៨៧១៤,៩៦ ហិកតា ស្ថិតនៅឃុំស្រែជិះ ,ឃុំរលួសមានជ័យ និងឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ។ បន្ទាប់ពីចុះកិច្ចសន្យារួចមកឈ្មោះ ------ បានកក់ប្រាក់ឲ្យទៅឈ្មោះ ----- ចំនួនពីរលើកសរុបមានចំនួន ២,២២២,៣១៤.៩២ $ (**ពីរលានពីរសែនពីរម៉ឺនពីរពាន់បីរយដប់បួនដុល្លារអាមេរិក និងកៅសិបពីរសេន**) តាមខ្លឹមសារនៃកិច្ចសន្យា រួចឈ្មោះ ----- ពុំបានបំពេញកាតព្វកិច្ចឲ្យបានពេញលេញតាមខ្លឹមសារនៃកិច្ចសន្យា ទើបឈ្មោះ ---- ជាអ្នកតំណាងក្រុមហ៊ុន -----

ដាក់ពាក្យប្ដឹងតែម្ដង ។

---

[2] ដើមបណ្ដឹងឈប់ប្ដឹង
[3] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ
[4] ករណីចែងដោយច្បាប់
[5] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមាន ឱ្យឈប់ប្រព្រឹត្ត
[6] ករណីចែងដោយច្បាប់

## <u>បានឃើញ</u>

-ពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២០ របស់ឈ្មោះ_ _ _ _ . ជាអ្នកតំណាងក្រុមហ៊ុនមានកម្រិតវិនិយោគទុនប្រកពជីវស្វាហាប់អន្តរជាតិ (                ) ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ _ _ _ _ បានឆ្លើយបំភ្លឺនៅដំណាក់កាលអយ្យការថា ៖ ពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២០ ជាពាក្យបណ្តឹងរបស់ខ្លួនប្រាកដមែន សូមរក្សាទុកខ្លឹមសារ និងឯកសារភ្ជាប់ទុកជាបានការតាមផ្លូវច្បាប់ ។ ខ្លួនសូមជម្រាបជូនថា ៖ ឈ្មោះ _ _ _ _ ជាតំណាងក្រុមហ៊ុន _ _ _ _ អះអាងថាក្រុមហ៊ុនខ្លួនមានដីសម្បទានសេដ្ឋកិច្ចទំហំ ៨៧១៤,៥៦ ហិកតា ស្ថិតនៅឃុំល្វេសមានជ័យ និងឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ មានបំណងលក់សិទ្ធិអភិវឌ្ឍន៍ឲ្យមកក្រុមហ៊ុនខ្លួន (ក្រុមហ៊ុនមានកម្រិតវិនិយោគទុនប្រកពជីវស្វាហាប់អន្តរជាតិ                ) ក្នុងតម្លៃមួយហិកតា ៥២០ $ **(ប្រាំរយម្ភៃដុល្លារអាមេរិក)** និងមានការណែនាំបញ្ចុះបញ្ចូលពីបក្ខពួកដែលជាដៃជើងរបស់ឈ្មោះ _ _ _ _ ផងនោះធ្វើឲ្យខ្លួនយល់ព្រមចុះកិច្ចសន្យាទិញសិទ្ធិអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ចនេះ ដោយបានឲ្យឈ្មោះ _ _ _ _ ធ្វើជាតំណាងក្រុមហ៊ុនចុះកិច្ចសន្យាជាមួយឈ្មោះ _ _ _ _ នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៤ និងបានធ្វើការប្រគល់ប្រាក់ឲ្យទៅឈ្មោះ _ _ _ _ ជាបន្តបន្ទាប់សរុបចំនួន ២,២២២,៣១៤.៩២ $ **(ពីរលានពីរសែនពីរម៉ឺនពីរពាន់បីរយដប់បួនដុល្លារអាមេរិក និងកៅសិបពីរសេន)** ។ ក្រោយពីឈ្មោះ _ _ _ ទទួលប្រាក់កក់រួច ឈ្មោះ _ _ _ _ មិនបានបំពេញកាតព្វកិច្ចដូចដែលបានចុះក្នុងកិច្ចសន្យានោះទេ ខាងក្រុមហ៊ុនខ្លួនបានព្យាយាមឲ្យឈ្មោះ _ _ _ _ បំពេញកាតព្វកិច្ចក្នុងកិច្ចសន្យាតែឈ្មោះ _ _ _ _ ចេះតែគេចវេស ជាចុងក្រោយឈ្មោះ _ _ _ _ មិនមានដីសម្បទានសេដ្ឋកិច្ចខាងលើសម្រាប់ប្រគល់សិទ្ធិមកឲ្យក្រុមហ៊ុនខ្លួនធ្វើការវិនិយោគឡើយ ដែលបង្ហាញយ៉ាងច្បាស់ថាឈ្មោះ _ _ _ _ ពិតជាមានគំនិតទុច្ចរិតឆបោកយកប្រាក់ពីក្រុមហ៊ុនខ្លួនយ៉ាងពិតប្រាកដដែលធ្វើឲ្យក្រុមហ៊ុនខ្លួនទទួលរងនូវការខូចខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរដែលមិនអាចអត់ឱនឲ្យបានឡើយ ។ ដូចបានជម្រាបជូនខាងលើខ្លួនសូមប្តឹងពីឈ្មោះ _ _ _ _ និងបក្ខពួកពីបទ "ឆបោក" សំណូមពរចាប់ឃាត់ខ្លួនឈ្មោះ _ _ _ _ និងបក្ខពួកយកទៅផ្តន្ទាទោសដាក់ពន្ធនាគារឲ្យបានតឹងរ៉ឹងតាមផ្លូវច្បាប់ និងទាមទារឲ្យឈ្មោះ ហុង ម៉ុងហេង ធ្វើការទូទាត់សងប្រាក់ទាំងអស់ចំនួន ២,២២២,៣១៤.៩២ $ **(ពីរលានពីរសែនពីរម៉ឺនពីរពាន់បីរយដប់បួនដុល្លារអាមេរិក និងកៅសិបពីរសេន)** ឲ្យមកខ្លួនវិញ និងទាមទារសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងថ្លៃសេវាកម្មមេធាវីជាប្រាក់ចំនួន ៥០០,០០០ $ **(ប្រាំសែនដុល្លារអាមេរិក)** ។

-ឈ្មោះ _ _ _ _ បានឆ្លើយបំភ្លឺនៅដំណាក់កាលអយ្យការថា ៖ នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤ ខ្លួនតំណាងឲ្យក្រុមហ៊ុន _ _ _ _ _ បានចុះកិច្ចសន្យាផ្ទេរសិទ្ធិភាគហ៊ុនក្រុមហ៊ុន _ _ _ _ _ (ក្រុមហ៊ុនទទួលបានសម្បទានដីសេដ្ឋកិច្ចទំហំ ៨.៧១៤,៥៦ ហិកតា ដែលមានទីតាំងដីស្ថិតនៅឃុំស្រែជិះ ឃុំល្វេសមានជ័យ និងឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈលិខិតលេខ ១៤១១ សជណ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) ជាមួយនឹងក្រុមហ៊ុន _ _ _ _ _ តំណាងដោយឈ្មោះ _ _ _ _ ក្នុងតម្លៃ ៤,៤៤៤,៦២៩.៦០ $ (បួនលានបួនសែនបួនម៉ឺនបួនពាន់

ប្រាំមួយរយម្ភៃប្រាំបួនដុល្លារអាមេរិកនិងហុកសិបសេន) លក់ទិញភាគហ៊ុន ១០០ % (មួយរយភាគរយ) របស់ក្រុមហ៊ុនឈ្មោះ _ _ _ _ _ ។ ចំពោះការលក់ភាគហ៊ុនចំនួន ១០០ % (មួយរយភាគរយ) ឲ្យក្រុមហ៊ុន _ _ _ _ _ នេះ ក្រុមហ៊ុន _ _ _ _ តំណាងដោយខ្លួនបានបង្ហាញឯកសារទាំងអស់ពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចដូចមានបញ្ជាក់ទំហំ និងទីតាំងខាងលើ ហើយក៏បានជូនភាគីអ្នកទិញភាគហ៊ុនចុះទៅពិនិត្យមើលទីតាំងដី ដោយធ្វើការចំណាយពេលប្រហែលជាង ០១ ខែកន្លះមុននឹងក្រុមហ៊ុន _ _ _ _ _ សម្រេចចិត្តទិញភាគហ៊ុនចំនួន ១០០ % (មួយរយភាគរយ) របស់ក្រុមហ៊ុនឈ្មោះ _ _ _ _ _ ។ នៅក្នុងរឿងលក់ទិញនេះខ្លួនជាតំណាងឲ្យក្រុមហ៊ុន _ _ _ _ _ បានទទួលប្រាក់កក់ចំនួន ០២ លើកសរុបចំនួន ៥០ % (ហាសិបភាគរយ) ស្មើនឹងទឹកប្រាក់ចំនួន ២,២២២,៣១៤.៩២ $ (ពីរលានពីរសែនពីរម៉ឺនពីរពាន់បីរយដប់បួនដុល្លារអាមេរិក និងកៅសិបពីរសេន) ពីក្រុមហ៊ុន _ _ _ _ តំណាងដោយឈ្មោះ _ _ _ _ ។ ហើយប្រាក់កក់ចំនួន ៥០ % (ហាសិបភាគរយ) ខាងលើខ្លួនបានទូទាត់ជូនម្ចាស់ភាគហ៊ុនដើមក្រុមហ៊ុន _ _ _ _ _ ចំនួន ០២ លើករួមមាន ៖ លើកទី ១ ចំនួន ២០២,៦៧៤ $ (ពីរសែនពីរពាន់ប្រាំមួយរយចិតសិបបួនដុល្លារអាមេរិក) និងលើកទី ២ ចំនួន ១,៤១៨,៧១៨ $ (មួយលានបួនសែនមួយម៉ឺនប្រាំបីពាន់ប្រាំពីររយដប់ប្រាំបីដុល្លារអាមេរិក) ចូលទៅក្នុងគណនីធនាគារលេខ _ _ _ _ _ របស់ឈ្មោះ _ _ _ _

ដូចមានបញ្ជាក់ក្នុងលិខិតដោះលែងប្រាក់តម្កល់ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤ ចំណែកឯប្រាក់ដែលសេសសល់ជាប្រាក់កម្រៃជើងសាររបស់ខ្លួន ដើម្បីបំពេញនីតិវិធីចុះបញ្ជីលើដីទំហំ ៨.៧៦០,៦៤ ហិកតា ស្មើនឹងចំនួន ១៣ ប័ណ្ណ ។ ក្រោយពេលចុះកិច្ចសន្យាផ្ទេរភាគហ៊ុនចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤ បានរួចរាល់ និងគូភាគីបានអនុវត្តកាតព្វកិច្ចតាមខ្លឹមសារនៃកិច្ចសន្យានេះរយៈពេលជាង ០៦ ខែក្រោយមកគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា មានការប្រែប្រួលទើបសម្បទានដីសេដ្ឋកិច្ចនេះត្រូវបានរដ្ឋដកហូតយកទៅវិញតាមរយៈលិខិតលេខ ១៧៥៥ សជណ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិតលេខ ៥២៥៣/៣៤៨ កសក.នជ.ផក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ពាក់ព័ន្ធនឹងករណីខាងដូចលើនេះក្រុមហ៊ុន _ _ _ _ _ មានឈ្មោះ _ _ _ _ ជាតំណាងធ្លាប់បានដាក់ពាក្យបណ្តឹងប្តឹងប្រឆាំងនឹងខ្លួនម្តងរួចហើយ នៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៧ ពីបទ "ឆបោក" មានសំណុំរឿងព្រហ្មទណ្ឌលេខ ៧២៨៥ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ប៉ុន្តែក្រោយមកតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញយល់ឃើញថាករណីខាងលើជារឿងក្តីរដ្ឋប្បវេណី ហើយតំណាងអយ្យការសម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការតាមដីកាលេខ ២១០ អ.យ.ព ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៨ លុះមកដល់ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០២០ ក្រុមហ៊ុន _ _ _ _ _ បានលើកយកអង្គហេតុ និងភស្តុតាងដដែលដោយគ្រាន់តែប្តូរអ្នកតំណាងក្រុមហ៊ុនទៅជាឈ្មោះ _ _ _ _ ហើយបន្តដាក់ពាក្យប្តឹងខ្លួនពីបទ ឆបោក ប្រព្រឹត្តកាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤

ដដែលសាជាថ្មីម្តងទៀត ។ រឿងពិតជាក់ស្តែងក្រុមហ៊ុន _ _ _ _ _ ពិតជាទទួលបាននូវសម្បទានដីសេដ្ឋកិច្ច ដែលមានទំហំ និងបញ្ជាក់ទីតាំងខាងលើដូចមានក្នុងលិខិតលេខ ១៤១១ សជណ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយក៏បានលក់ភាគហ៊ុនក្រុមហ៊ុន _ _ _ _ _ ឲ្យក្រុមហ៊ុន _ _ _ _ ចំនួន ១០០ % (មួយរយភាគរយ) ដោយបានផ្ទេរភាគហ៊ុនរបស់ក្រុមហ៊ុន _ _ _ _ _ ចំនួន ៧០ % (ចិតសិបភាគរយ) បន្ទាប់ពីក្រុមហ៊ុន _ _ _ _ _ _ តំណាងដោយខ្លួនបានទទួលប្រាក់តែចំនួន ៥០ % (ហាសិបភាគរយ) ស្មើនឹងទឹកប្រាក់ចំនួន ២,២២២,៣១៤.៩២ $ (ពីរលានពីរសែនពីរម៉ឺនពីរពាន់បីរយដប់បួនដុល្លារអាមេរិក និងកៅសិបពីរសេន) ដូចមានក្នុងលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន _ _ _ _ ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៤ ហើយឈ្មោះ _ _ _ _ _ ក៏មានឈ្មោះក្នុងលក្ខន្តិកៈថ្មីនេះបានដាក់លិខិតទៅកាន់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសុំសិទ្ធិប្រទាន និងសុំចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចកាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ផងដែរ ប៉ុន្តែដោយរដ្ឋមានការកែប្រែគោលនយោបាយថ្មី ហើយសម្រេចដកយកដីនេះវិញតាមលិខិតលេខ **១៧៥៥ សជណ** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី (សម្រេចមិនឲ្យបន្ត និងនិរាករណ៍គម្រោងវិនិយោគរបស់ក្រុមហ៊ុន) និងលិខិតលេខ **៥២៥៣/៣៤៨ កសក.នជ.ផក** ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបណ្តាលឲ្យខូចខាតនូវផលប្រយោជន៍របស់ម្ចាស់ភាគហ៊ុននីមួយៗនៅក្នុងលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន _ _ _ _ _ យ៉ាងធ្ងន់ធ្ងរហើយរឿងរដ្ឋដកហូតយកដីនេះខ្លួន និងក្រុមហ៊ុន _ _ _ _ _ បានសុំឲ្យស្ថានទូតនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជាជួយអន្តរាគមន៍ ដាក់ជាលិខិតជាលាយលក្ខណ៍អក្សររហូតដល់ទៅ ០២ លើកដោយលើកទី ១ នៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ និងលើកទី ២ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ប៉ុន្តែពុំទទួលបានលទ្ធផលអ្វីឡើយ ។ ចំពោះប្រាក់ដែលខ្លួនបានទទួលពីក្រុមហ៊ុនចិននោះ ខ្លួនមិនអាចខ្ទាត់ត្រឡប់ទៅវិញបានទេ ដោយហេតុថាពេលបានទទួលប្រាក់មក ខ្លួនបានបញ្ជូនប្រាក់នេះទៅឲ្យក្រុមហ៊ុនវៀតណាមភ្លាម ហើយខ្លួនបានសហការជាមួយស្ថានទូតវៀតណាមធ្វើការតវ៉ាទៅរាជរដ្ឋាភិបាលដល់ទៅពីរលើក តែមិនបានសម្រេច ហើយសូម្បីតែភាគីខាងក្រុមហ៊ុនចិនក៏បានដាក់ពាក្យសុំសិទ្ធិប្រទានទៅរាជរដ្ឋាភិបាលដែរ ក៏នៅតែមិនបានទៀតដែលបង្ហាញយ៉ាងច្បាស់មិនមែនជាកំហុសរបស់ខាងក្រុមហ៊ុនខ្លួននោះឡើយ ។ នៅក្នុងរឿងក្តីនេះដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានប្តឹងចោទប្រកាន់រូបខ្លួនពីបទ **"ឆបោក"** ម្តងរួចមកហើយ ដែលមានសំណុំរឿងព្រហ្មទណ្ឌលេខ **៧២៨៥** ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ប៉ុន្តែត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញតម្កល់សំណុំរឿងទុកដោយឥតចាត់ការតាមដីកាតម្កល់រឿងទុកឥតចាត់ការលេខ ២១០ អ.យ.ព ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧ ។ ហើយការលក់ទិញភាគហ៊ុនបានប្រព្រឹត្តទៅនៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤ ឯថ្ងៃដាក់ពាក្យបណ្តឹងប្រឆាំងនិងអង្គហេតុខាងលើថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០២០ ដូច្នេះបើគិតពីថ្ងៃលក់ទិញភាគហ៊ុនមកដល់ថ្ងៃដាក់ពាក្យបណ្តឹង គឺមានចំរវេលាជាង ៦ ឆ្នាំទៅហើយយោងមាត្រា ១០ ក្រមនីតិវិធីព្រហ្មទណ្ឌអាជ្ញាយុកាលនៃបទល្មើសមជ្ឈិមមានត្រឹម ៥ ឆ្នាំប៉ុណ្ណោះ ។ តាមអង្គហេតុ និងភស្តុតាងដែលដើមបណ្តឹងរដ្ឋប្បវេណីបានយកមកធ្វើជាទឡ្ហីករប្តឹងប្រឆាំងនឹងរូបខ្លួននាពេលនេះ គឺអង្គហេតុ និងភស្តុតាងចាស់ដដែលៗ ដោយពុំមានអង្គហេតុ និងភស្តុតាងថ្មីដើម្បីនាំឲ្យមានការកែប្រែលទ្ធផលនៃដីកាតម្កល់រឿងទុកឥតចាត់ការមុន

នោះឡើយ ។ សំណូមពរស្នើសុំ **តុលាការកំពូលព្រះរាជអាជ្ញា** មេត្តាសម្រេចតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ **៨១៨៧** ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាយឥតចាត់ការ តទៅដោយសេចក្តីអនុគ្រោះ ។

-ឈ្មោះ _ _ _ _ បានឆ្លើយបំភ្លឺនៅចំណាក់កាលអយ្យការថា ៖ នៅពេលដែលក្រុមហ៊ុន _ _ _ _ ទទួលបានសដណ ប្រគល់ដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលមក នោះខ្លួនមិនបានលក់គម្រោងអភិវឌ្ឍន៍ក្នុងសដណនោះទេ គឺខ្លួនលក់តែភាគហ៊ុនឲ្យទៅដៃគូដើម្បីអភិវឌ្ឍន៍លើគម្រោងនៃសដណនោះ ព្រោះខ្លួនបានដឹងច្បាស់ថារាជរដ្ឋាភិបាលមិនអនុញ្ញាតឲ្យក្រុមហ៊ុនខ្លួនលក់គម្រោងអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ចនោះទេ ។ ខ្លួនមិនដឹងថារាជរដ្ឋាភិបាលដកហូតដីសម្បទានសេដ្ឋកិច្ចនេះដោយមូលហេតុអ្វីទេ ព្រោះគម្រោងរបស់ខ្លួនកំពុងដំណើរការ ហើយដៃគូដែលជាដើមបណ្តឹងក៏កំពុងដំណើរការអភិវឌ្ឍន៍ជាមួយគ្នា ។ រយៈពេលដែលខ្លួនដឹងថារាជរដ្ឋាភិបាលដកហូតដីសម្បទានសេដ្ឋកិច្ចនេះវិញ គឺមានរយៈពេលបីខែ បន្ទាប់ពីដើមបណ្តឹងចុះហត្ថលេខាលើលិខិតស្នើសុំទៅក្រសួងកសិកម្មដើម្បីចុះកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច (ថ្ងៃទី **១៥** ខែ កញ្ញា ឆ្នាំ ២០១៤) និងមានសដណលុបថ្ងៃទី **២៦** ខែ ធ្នូ ឆ្នាំ ២០១៤ រយៈពេល ០៦ ខែ ។ ខ្លួនមិនដឹងថារយៈពេលប៉ុន្មានដែលរាជរដ្ឋាភិបាលដកហូតដីសម្បទានសេដ្ឋកិច្ចនៃសដណនេះ នៅពេលដែលក្រុមហ៊ុនរបស់ខ្លួនអនុវត្តកាតព្វកិច្ចមិនត្រឹមត្រូវតាមលក្ខន្តិកៈនោះទេ ។

-លិខិតលេខ **១៤១១ សដណ** ចុះថ្ងៃទី **០៧** ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

-កិច្ចសន្យារបស់ក្រុមហ៊ុន _ _ _ _ _ ផ្ទេរភាគហ៊ុនឲ្យក្រុមហ៊ុន _ _ _ _ _ _ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤ ។

-លិខិតលេខ **១៧៥៥ សដណ** ចុះថ្ងៃទី **២៦** ខែ ធ្នូ ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

-លិខិតលេខ **៥២៥៣/៣៤៨ កសក.នជ.ផក** ចុះថ្ងៃទី **១២** ខែ សីហា ឆ្នាំ ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

-ពាក្យបណ្តឹងរបស់ឈ្មោះ _ _ _ _ ជាមេធាវីតំណាង និងការពារសិទ្ធិឲ្យឈ្មោះ _ _ _ _ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៧ ។

-ដីកាតម្កល់រឿងទុកឥតចាត់ការលេខ **២១០** អ.យ.ព ចុះថ្ងៃទី **២៦** ខែ មករា ឆ្នាំ **២០១៧** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-លិខិតរបស់ក្រុមហ៊ុន _ _ _ _ _ _

ប្រគល់សិទ្ធិឲ្យឈ្មោះ _ _ _ _ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០២០ ។

-លិខិតបំភ្លឺរបស់ឈ្មោះ _ _ _ _ ចុះថ្ងៃទី **១១** ខែ មករា ឆ្នាំ ២០២១ ។

-ពាក្យស្នើសុំកែតម្រូវរបស់ឈ្មោះ _ _ _ _ ចុះថ្ងៃទី **១៩** ខែ មករា ឆ្នាំ ២០២១ ។

-ពាក្យសុំតម្កល់រឿងទុកឥតចាត់ការរបស់ឈ្មោះ _ _ _ _ និងឈ្មោះ _ _ _ _ ជាមេធាវីតំណាង និងការពារសិទ្ធិឲ្យឈ្មោះ **ហុង ម៉ុងហេង** ចុះថ្ងៃទី **២២** ខែ មករា ឆ្នាំ ២០២១ ។

-លិខិតបំភ្លឺរបស់ឈ្មោះ _ _ _ ជាមេធាវីការពារ និងតំណាងឲ្យឈ្មោះ _ _ _ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២១ ។

-ឯកសារពាក់ព័ន្ធផ្សេងៗទាក់ទងនឹងរឿងនេះ ។

## យល់ឃើញថា

-កាលពីថ្ងៃទី **១២** ខែ មិថុនា ឆ្នាំ ២០១៤ ឈ្មោះ _ _ _ _ ជាអ្នកតំណាងក្រុមហ៊ុន _ _ _ _ បានចុះកិច្ចសន្យាផ្ទេរភាគហ៊ុនឲ្យក្រុមហ៊ុន _ _ _ _ _ _ ដែលមានអ្នកតំណាងឈ្មោះ _ _ _ _ នូវដីសម្បទានសេដ្ឋកិច្ចទំហំ **៨៧១៤,៩៦** ហិកតា ស្ថិតនៅឃុំស្រែជិះ ,ឃុំល្ហួសមានជ័យ និងឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ។ បន្ទាប់ពីចុះកិច្ចសន្យារួចមក គោលនយោបាយរបស់រាជរដ្ឋាភិបាលមានការប្រែប្រួល រាជរដ្ឋាភិបាលក៏បានចេញលិខិតលេខ **១៧៥៥ សជណ** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ សម្រេចមិនឲ្យបន្តនីតិវិធី និងនិរាករណ៍គម្រោងវិនិយោគរបស់ក្រុមហ៊ុន _ _ _ _ _ បណ្តាលឲ្យខូចខាតនូវផលប្រយោជន៍ដល់ក្រុមហ៊ុន _ _ _ _ _ _ ទើបឈ្មោះ _ _ _ _ ជាអ្នកតំណាងក្រុមហ៊ុន _ _ _ _ _ ដាក់ពាក្យប្តឹងតែម្តង ។

-តាមអង្គហេតុ ,តាមចម្លើយគូភាគី និងតាមការពិនិត្យឯកសារនានាជាភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចមកឃើញថា ៖ ក្រុមហ៊ុន _ _ _ _ _ ពិតជាទទួលបាននូវសម្បទានដីសេដ្ឋកិច្ច ដែលមានទំហំ និងបញ្ជាក់ទីតាំងខាងលើដូចមានក្នុងលិខិតលេខ **១៤១១ សជណ** ចុះថ្ងៃទី **០៧** ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រីប្រាកដមែន ។ លុះក្រោយមកដោយសារគោលនយោបាយរបស់រាជរដ្ឋាភិបាលមានការប្រែប្រួល រាជរដ្ឋាភិបាលក៏បានចេញលិខិតលេខ **១៧៥៥ សជណ** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ សម្រេចមិនឲ្យបន្តនីតិវិធី និងនិរាករណ៍គម្រោងវិនិយោគរបស់ក្រុមហ៊ុន _ _ _ _ _ _ ទើបបណ្តាលឲ្យខូចខាតផលប្រយោជន៍ដល់ក្រុមហ៊ុន _ _ _ _ ។

-ចំពោះអង្គហេតុដែលឈ្មោះ _ _ _ _ បានលើកយកមកប្តឹងនេះ ដូចគ្នានឹងអង្គហេតុនៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ **៧២៨៥** ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលតំណាងអយ្យការបានសម្រេចតម្កល់រឿងឥតចាត់ការតាមដីកាតម្កល់រឿងទុកឥតចាត់ការលេខ **២១០** អ.យ.ព ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៨ ម្តងរួចទៅហើយ ជាហេតុធ្វើឲ្យតំណាងអយ្យការមិនអាចលើកយកអង្គហេតុដដែលនេះ មកចាត់ការម្តងទៀតឡើយ ។

-តាមអង្គហេតុខាងលើនេះ គឺកើតឡើងនៅថ្ងៃទី **១២** ខែ មិថុនា ឆ្នាំ ២០១៤ មកម្ល៉េះ រហូតមកដល់ថ្ងៃដាក់ពាក្យបណ្តឹងចុះថ្ងៃទី **១៩** ខែ ធ្នូ ឆ្នាំ ២០២០ មានរយៈពេល ៦ ឆ្នាំ មកហើយ ជាហេតុធ្វើឲ្យបណ្តឹងរបស់ឈ្មោះ ផុតអាជ្ញាយុកាលនៃបទល្មើសតាមបញ្ញត្តិមាត្រា **១១** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយបណ្តឹងអាជ្ញាត្រូវរលត់តាមមាត្រា **៧** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-តាមអង្គហេតុ ,តាមចម្លើយគូភាគី និងតាមការពិនិត្យឯកសារនានាជាភស្តុតាងដែលមានក្នុងសំណុំរឿង រួចមកឃើញថា ៖ ពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដើម្បីឲ្យតំណាងអយ្យការបើកការស៊ើបសួរលើឈ្មោះ _ _ _ ពីបទ ឆបោក បានឡើយ ។

-គប្បីតំណាងអយ្យការពិនិត្យ ពិចារណាសំរេចតាមច្បាប់ ។

**<u>ហេតុដូច្នេះសម្រេច</u>**

-តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ **៨១៨៧** ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០ ទុកឥតចាត់ការតទៅ ។

-បង្គាប់ឲ្យក្រឡាបញ្ជីជូនដំណឹងដល់ភាគីដើមបណ្តឹងដើម្បីបើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

ថ្ងៃ សុក្រ ៦រោច ខែ ផល្គុន ឆ្នាំ ជូត ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២១

**ព្រះរាជអាជ្ញារង**

**ស៊ុត-ចន្ធា:**

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៨៧
ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០

**<u>កំណត់ហេតុស្តាប់ចម្លើយ</u>**

ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ពីរពាន់ប្រាំរយហុកសិបប្រាំ ខែ ជេស្ឋ ថ្ងៃ ព្រហស្បតិ៍ មួយរោច
ឆ្នាំពីរពាន់ម្ភៃមួយ ខែ ឧសភា ថ្ងៃទី ម្ភៃប្រាំពីរ វេលាម៉ោង ដប់ និងម្ភៃនាទីព្រឹក
យើង _ _ _ _ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
ដោយមានលោក _ _ _ _ ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយឈ្មោះ _ _ _ _ជាជនសង្ស័យ ដោយមានលោកស្រី _ _ _ _ និងលោកស្រី _ _ _ ⁄ ជាមេធាវីការពារក្តីដូចខាងក្រោមនេះ ៖

សួរ-ឆ្លើយ ៖ ខ្ញុំបាទឈ្មោះ អាយុ ៥០ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិផ្សារឆ្នាំង ឃុំផ្សារឆ្នាំង ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានទីលំនៅបច្ចុប្បន្នផ្ទះលេខ HE១៤ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរពាណិជ្ជករ ឪពុកឈ្មោះ _ _ "ស្លាប់" ម្តាយឈ្មោះ _ _ _ "រស់" ប្រពន្ធឈ្មោះ _ _ _ "លែងលះ" មានកូន ០២ នាក់ ទោសពីមុនគ្មាន ជានីតិជន ទូរស័ព្ទទំនាក់ទំនងលេខ _ _ _ _ _ ។

សួរ-ឆ្លើយ ៖ ខ្ញុំបាទសូមទទួលយកលោកស្រី _ _ _ និងលោកស្រី _ _ _ ធ្វើជាមេធាវីការពារឲ្យខ្ញុំបាទនៅក្នុងសំណុំរឿងនេះ ។

សួរ ៖ តើលោកមានដឹងថារាជរដ្ឋាភិបាលដកហូតដីសម្បទានសេដ្ឋកិច្ចនេះដោយមូលហេតុអ្វីទេ ?

ឆ្លើយ ៖ ខ្ញុំបាទមិនដឹងមូលហេតុអ្វីទេ ព្រោះគម្រោងរបស់ខ្ញុំបាទកំពុងដំណើរការ ហើយដៃគូដែលជាដើមបណ្តឹងក៏កំពុងដំណើរការអភិវឌ្ឍន៍ជាមួយគ្នា ។

ឆ្លើយ ៖ រយៈពេលដែលខ្ញុំបាទដឹងថារាជរដ្ឋាភិបាលដកហូតដីសម្បទានសេដ្ឋកិច្ចនេះវិញ គឺមានរយៈពេលបីខែបន្ទាប់ពីដើមបណ្តឹងចុះហត្ថលេខាលើលិខិតស្នើសុំទៅក្រសួងកសិកម្មដើម្បីចុះកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច (ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤) ។ ចាប់តាំងពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាលក់ភាគហ៊ុនថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤ រហូតដល់ថ្ងៃដែលរាជរដ្ឋាភិបាលលុបនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ គឺមានរយៈពេល ០៦ ខែ ។

សួរ ៖ តើលោកមានដឹងថារយៈពេលប៉ុន្មានដែលរាជរដ្ឋាភិបាលដកហូតដីសម្បទានសេដ្ឋកិច្ចនៃសជណនេះ នៅពេលដែលក្រុមហ៊ុនរបស់លោកអនុវត្តកាតព្វកិច្ចមិនត្រឹមត្រូវតាមលក្ខន្តិកៈ ?

សួរ ៖ ខ្ញុំបាទមិនដឹងទេ ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ ។

ឈប់សួរ បានអានឲ្យស្តាប់សាមីខ្លួនឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយយើង ។

| **អ្នកឆ្លើយ** | **មេធាវី** | **ក្រឡាបញ្ជី** | **តំណាងអយ្យការ** |
|---|---|---|---|

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៨៧
ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០

## កំណត់ហេតុស្តាប់ចម្លើយ

ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ពីរពាន់ប្រាំរយហុកសិបប្រាំ ខែ ជេស្ឋ ថ្ងៃ ព្រហស្បតិ៍ មួយរោច
ឆ្នាំពីរពាន់ម្ភៃមួយ ខែ ឧសភា ថ្ងៃទី ម្ភៃប្រាំពីរ វេលាម៉ោង ប្រាំបួន និងម្ភៃនាទីព្រឹក
យើង _ _ _ _ . តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
ដោយមានលោក _ _ _ _ ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយឈ្មោះ _ _ _ _ ជាជនសង្ស័យ ដោយមានលោកស្រី _ _ _ _ និងលោកស្រី _ _ _ _ ជាមេធាវីការពារក្តីដូចខាងក្រោមនេះ ៖

សួរ-ឆ្លើយ ៖ ខ្ញុំបាទឈ្មោះ _ _ _ _ _ អាយុ ៥០ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិផ្សារឆ្នាំង ឃុំផ្សារឆ្នាំង ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានទីលំនៅបច្ចុប្បន្នផ្ទះលេខ HE១៤ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរពាណិជ្ជករ ឪពុកឈ្មោះ _ _ _ "ស្លាប់" ម្តាយឈ្មោះ _ _ _ "រស់" ប្រពន្ធឈ្មោះ _ _ _ "លែងលះ" មានកូន ០២ នាក់ ទោសពីមុនគ្មាន ជានីតិជន ទូរស័ព្ទទំនាក់ទំនងលេខ _ _ _ _ _ ។

សួរ-ឆ្លើយ ៖ ខ្ញុំបាទសូមទទួលយកលោកស្រី _ _ _ _ និងលោកស្រី _ _ _ _ ធ្វើជាមេធាវីការពារឲ្យខ្ញុំបាទនៅក្នុងសំណុំរឿងនេះ ។

សួរ-ឆ្លើយ ៖ នៅពេលដែលក្រុមហ៊ុន _ _ _ _ _ _ ទទួលបានសដណប្រគល់ដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលមកនោះខ្ញុំបាទមិនបានលក់គម្រោងអភិវឌ្ឍន៍ក្នុងសដណនោះទេ គឺខ្ញុំបាទលក់តែភាគហ៊ុនឲ្យទៅដៃគូដើម្បីអភិវឌ្ឍន៍លើគម្រោងនៃសដណនោះ ព្រោះខ្ញុំបាទបានដឹងច្បាស់ថារាជរដ្ឋាភិបាលមិនអនុញ្ញាតឲ្យក្រុមហ៊ុនខ្ញុំបាទលក់គម្រោងអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ចនោះទេ ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ ។

ឈប់សួរ បានអានឲ្យស្តាប់សាមីខ្លួនឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយយើង ។

| អ្នកឆ្លើយ | មេធាវី | ក្រឡាបញ្ជី | តំណាងអយ្យការ |
|---|---|---|---|

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**
**រាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៨៧
ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២០

# កំណត់ហេតុស្តាប់ចម្លើយ

ឆ្នាំ ជូត ទោស័ក ព.ស ពីរពាន់ប្រាំរយហុកសិបបួន ខែ បុស្ស ថ្ងៃ ០ទូ ដប់បីកេច

ឆ្នាំពីរពាន់ម្ភៃមួយ ខែ មករា ថ្ងៃទី ដប់មួយ វេលាម៉ោង ប្រាំបួន និងម្ភៃនាទីព្រឹក

យើង _ _ _ _ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ដោយមានលោក _ _ _ ជាក្រឡាបញ្ជីអមផង បានស្តាប់យកចម្លើយឈ្មោះ _ _ _ _ ជាជនសង្ស័យ ដោយមានលោកស្រី _ _ _ _ និងលោកស្រី _ _ _ _ ជាមេធាវីការពារក្តីដូចខាងក្រោមនេះ ៖

សួរ-ឆ្លើយ ៖ ខ្ញុំបាទឈ្មោះ _ _ _ _ អាយុ ៥០ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិផ្សារឆ្នាំង ឃុំផ្សារឆ្នាំង ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានទីលំនៅបច្ចុប្បន្នផ្ទះលេខ អ៩១៤ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរពាណិជ្ជករ ឪពុកឈ្មោះ _ _ _ "ស្លាប់" ម្តាយឈ្មោះ _ _ _ "រស់" ប្រពន្ធឈ្មោះ _ _ _ _ "លែងលះ" មានកូន ០២ នាក់ ទោសពីមុនគ្មាន ជានីតិជន ខ្សែទូរស័ព្ទទំនាក់ទំនងលេខ _ _ _ _ _ _ ។

សួរ-ឆ្លើយ ៖ ខ្ញុំបាទសូមទទួលយកលោកស្រី _ _ _ _ និងលោកស្រី _ _ _ _ ធ្វើជាមេធាវីការពារឲ្យខ្ញុំបាទនៅក្នុងសំណុំរឿងនេះ ។

សួរ-ឆ្លើយ ៖ នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤ ខ្ញុំបាទតំណាងឲ្យក្រុមហ៊ុន _ _ _ _ _ _ _ _ បានចុះកិច្ចសន្យាផ្ទេរសិទ្ធិភាគហ៊ុនក្រុមហ៊ុន _ _ _ _ _ _ (ក្រុមហ៊ុនទទួលបានសម្បទានដីសេដ្ឋកិច្ចទំហំ ៨.៧១៤,៩៦ ហិកតា ដែលមានទីតាំងដីស្ថិតនៅឃុំស្រែជិះ ឃុំល្ហួសមានជ័យ និងឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈលិខិតលេខ ១៤១១ សជណ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) ជាមួយនឹងក្រុមហ៊ុន _ _ _ _ _ _ តំណាងដោយឈ្មោះ _ _ _ _ _ ក្នុងតម្លៃ ៤,៤៤៤,៦២៩.៦០ $ (បួនលានបួនសែនបួនម៉ឺនបួនពាន់ប្រាំមួយរយ ម្ភៃប្រាំបួនដុល្លារអាមេរិកនិងហុកសិបសេន) លក់ទិញភាគហ៊ុន ១០០ % (មួយរយភាគរយ) របស់ក្រុមហ៊ុនឈ្មោះ _ _ _ _ _ _ ។ ចំពោះការលក់ភាគហ៊ុនចំនួន ១០០ % (មួយរយភាគរយ) ឲ្យក្រុមហ៊ុន _ _ _ _ _ _ _ នេះក្រុមហ៊ុន _ _ _ _ _ _ តំណាងដោយខ្ញុំបាទបានបង្ហាញឯកសារទាំងអស់ពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចដូចមានបញ្ជាក់ទំហំ និងទីតាំងខាងលើ ហើយក៏បានជូនភាគីអ្នកទិញភាគហ៊ុនចុះទៅពិនិត្យមើលទីតាំងដីដោយធ្វើការចំណាយពេលប្រហែលជាង ០១ ខែកន្លះ មុននឹងក្រុមហ៊ុន _ _ _ _ សម្រេចចិត្តទិញភាគហ៊ុនចំនួន ១០០ % (មួយរយភាគរយ) របស់ក្រុមហ៊ុនឈ្មោះ _ _ _ _ _ _ ។ នៅក្នុងរឿងលក់ទិញនេះខ្ញុំបាទជាតំណាងឲ្យក្រុមហ៊ុន _ _ _ _ បានទទួលប្រាក់កក់ចំនួន ០២ លើកសរុបចំនួន ៥០ % (ហាសិបភាគរយ) ស្មើនឹង...

ប្រាក់ចំនួន ២,២២២,៣១៤.៩២ $ (**ពីរលានពីរសែនពីរម៉ឺនពីរពាន់បីរយដប់បួនដុល្លារអាមេរិក និងកៅសិបពីរសេន**) ពីក្រុមហ៊ុន ______

តំណាងដោយឈ្មោះ ____ ។ ហើយប្រាក់កក់ចំនួន **៥០ % (ហាសិបភាគរយ)** ខាងលើខ្ញុំបាទបានទូទាត់ជូនម្ចាស់ភាគហ៊ុនដើមក្រុមហ៊ុន ____ **ស៊ីហ្សឺរ** ចំនួន ០២ លើករួមមាន ៖ លើកទី ១ ចំនួន **២០២,៦៧៨ $ (ពីរសែនពីរពាន់ប្រាំមួយរាយចិតសិបប្រាំបួនដុល្លារអាមេរិក)** និងលើកទី ២ ចំនួន **១,៤១៨,៧១៨ $ (មួយលានបួនសែនមួយម៉ឺនប្រាំបីពាន់ប្រាំពីររយដប់ប្រាំបីដុល្លារអាមេរិក)** ចូលទៅក្នុងគណនីធនាគារលេខ **០០១០០០២៨២៣៩៣៧** របស់ឈ្មោះ ______ ដូចមានបញ្ជាក់ក្នុងលិខិតដោះលែងប្រាក់តម្កល់ចុះថ្ងៃទី **៣០** ខែ មិថុនា ឆ្នាំ ២០១៤ ចំណែកឯប្រាក់ដែលសេសសល់ជាប្រាក់កម្រៃជើងសាររបស់ខ្ញុំបាទ ដើម្បីបំពេញនីតិវិធីចុះបញ្ជីលើដីទំហំ **៨.៧៦០,៦៤** ហិកតា ស្មើនឹងចំនួន **១៣** ប័ណ្ណ ។ ក្រោយពេលចុះកិច្ចសន្យាផ្ទេរភាគហ៊ុនចុះថ្ងៃទី **១២** ខែ មិថុនា ឆ្នាំ ២០១៤ បានរួចរាល់ និងគូភាគីបានអនុវត្តកាតព្វកិច្ចតាមខ្លឹមសារនៃកិច្ចសន្យានេះរយៈពេលជាង ០៦ ខែក្រោយមកគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា មានការប្រែប្រួលទើបសម្បទានដីសេដ្ឋកិច្ចនេះត្រូវបានរដ្ឋដកហូតយកទៅវិញតាមរយៈលិខិតលេខ **១៧៥៥ សជណ** ចុះថ្ងៃទី **២៦** ខែ ធ្នូ ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីនិងលិខិតលេខ **៥២៥៣/៣៤៨ កសក.នផ.ផក** ចុះថ្ងៃទី **១២** ខែ សីហា ឆ្នាំ ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សួរ-ឆ្លើយ ៖ ពាក់ព័ន្ធនឹងករណីខាងដូចលើនេះក្រុមហ៊ុន ______ មានឈ្មោះ _____ ជាតំណាងធ្លាប់បានដាក់ពាក្យបណ្តឹងប្តឹងប្រឆាំងនឹងខ្ញុំបាទម្តងរួចហើយ នៅថ្ងៃចុះថ្ងៃទី **០២** ខែ តុលា ឆ្នាំ **២០១៧** ពីបទ **"ឆបោក"** មានសំណុំរឿងព្រហ្មទណ្ឌលេខ **៧២៨៥** ចុះថ្ងៃទី **១៦** ខែ វិច្ឆិកា ឆ្នាំ **២០១៧** ប៉ុន្តែក្រោយមកតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញយល់ឃើញថា ករណីខាងលើជារឿងក្តីរដ្ឋប្បវេណី ហើយតំណាងអយ្យការសម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការតាមដីកាលេខ **២១០** អ.យ.ព ចុះថ្ងៃទី **២៦** ខែ មករា ឆ្នាំ ២០១៨ លុះមកដល់ថ្ងៃទី **២១** ខែ ធ្នូ ឆ្នាំ ២០២០ ក្រុមហ៊ុន ______ បានលើកយកអង្គហេតុ និងភស្តុតាងដដែលដោយគ្រាន់តែប្តូរអ្នកតំណាងក្រុមហ៊ុនទៅជាឈ្មោះ ____ ហើយបន្តដាក់ពាក្យប្តឹងខ្ញុំបាទពីបទ **"ឆបោក"** ប្រព្រឹត្តកាលពីថ្ងៃទី **១២** ខែ មិថុនា ឆ្នាំ ២០១៤ ដដែលសាជាថ្មីម្តងទៀត ។

សួរ-ឆ្លើយ ៖ រឿងពិតជាក់ស្តែងក្រុមហ៊ុន ______ ពិតជាទទួលបាននូវសម្បទានដីសេដ្ឋកិច្ចដែលមានទំហំ និងបញ្ជាក់ទីតាំងខាងលើដូចមានក្នុងលិខិតលេខ **១៤១១ សជណ** ចុះថ្ងៃទី **០៧** ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយក៏បានលក់ភាគហ៊ុនក្រុមហ៊ុន តែ ទីញ ក្រចេះ ស៊ីហ្សឺឲ្យក្រុមហ៊ុន ______ ចំនួន **១០០ % (មួយរយភាគរយ)** ដោយបានផ្ទេរភាគហ៊ុនរបស់ក្រុមហ៊ុន ________ ចំនួន **៧០ % (ចិតសិបភាគរយ)** បន្ទាប់ពីក្រុមហ៊ុន ______ តំណាងដោយខ្ញុំបាទបានទទួលប្រាក់តែចំនួន **៥០ % (ហាសិបភាគរយ)** ស្មើនឹងទឹកប្រាក់ចំនួន **២,២២២,៣១៤.៩២ $ (ពីរលានពីរសែនពីរម៉ឺនពីរពាន់បីរយដប់បួនដុល្លារអាមេរិក និងកៅសិបពីរសេន)** ដូចមានក្នុងលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន _______ ចុះថ្ងៃទី **១៨** ខែ មិថុនា ឆ្នាំ ២០១៤ ហើយឈ្មោះ _______ ក៏មានឈ្មោះក្នុងលក្ខន្តិកៈថ្មីនេះបានដាក់លិខិតទៅកាន់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសុំសិទ្ធិប្រទាន និងសុំចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចកាលពីថ្ងៃទី **១៥** ខែ កញ្ញា ឆ្នាំ **២០១៤** ផងដែរ ប៉ុន្តែដោយរដ្ឋមានការកែប្រែគោលនយោបាយថ្មី ហើយសម្រេចដកយកដីនេះវិញតាមលិខិតលេខ **១៧៥៥ សជណ** ចុះថ្ងៃទី **២៦** ខែ ធ្នូ ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី **(សម្រេចមិនឲ្យបន្ត និងនិរាករណ៍គម្រោងវិនិយោគរបស់ក្រុមហ៊ុន)** និងលិខិតលេខ **៥២៥៣/៣៤៨ កសក.នផ.ផក** ចុះថ្ងៃទី **១២** ខែ សីហា ឆ្នាំ **២០១៥** របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបណ្តាលឲ្យខូចខាតនូវផលប្រយោជន៍របស់ម្ចាស់ភាគហ៊ុននីមួយៗ នៅក្នុងលក្ខន្តិកៈថ្មី

របស់ក្រុមហ៊ុន _ _ _ _ _ _ យាងធូនំធូរ ហើយរឿងផ្ទេរកម្មសិទ្ធដីនេះខ្ញុំបាទ និងក្រុមហ៊ុន _ _ _ _

បានសុំឲ្យស្ថានទូតនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជាជួយអន្តរាគមន៍ ដាក់ជាលិខិតជាលាយលក្ខណ៍អក្សរហុតដល់ទៅ **០២** លើក ដោយលើកទី១ នៅថ្ងៃទី **០៩** ខែ កុម្ភៈ ឆ្នាំ ២០១៥ និងលើកទី២ នៅថ្ងៃទី **១៤** ខែ កញ្ញា ឆ្នាំ ២០១៥ ប៉ុន្តែពុំទទួលបានលទ្ធផលអ្វីឡើយ ។

សួរ-ឆ្លើយ ៖ ចំពោះប្រាក់ដែលខ្ញុំបាទបានទទួលពីក្រុមហ៊ុនចិននោះ ខ្ញុំបាទមិនអាចទូទាត់ត្រឡប់ទៅវិញបានទេ ដោយហេតុថាពេលបានទទួលប្រាក់មក ខ្ញុំបាទបានបញ្ជូនប្រាក់នេះទៅឲ្យក្រុមហ៊ុនវៀតណាមភ្លាម ហើយខ្ញុំបាទបានសហការជាមួយស្ថានទូតវៀតណាមធ្វើការតវ៉ាទៅរាជរដ្ឋាភិបាលដល់ទៅពីរលើក តែមិនបានសម្រេច ហើយសូម្បីតែភាគីខាងក្រុមហ៊ុនចិនក៏បានដាក់ពាក្យសុំសិទ្ធិប្រទានទៅរាជរដ្ឋាភិបាលដែរ ក៏នៅតែមិនបានទៀតដែលបង្ហាញយ៉ាងច្បាស់មិនមែនជាកំហុសរបស់ខាងក្រុមហ៊ុនខ្ញុំបាទនោះឡើយ ។

ខ្ញុំបាទសូមបញ្ជាក់បន្ថែមថា ៖ នៅក្នុងរឿងក្តីនេះដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានប្តឹងចោទប្រកាន់រូបខ្ញុំបាទពីបទ "ឆបោក" ម្តងរួចមកហើយដែលមានសំណុំរឿងព្រហ្មទណ្ឌលេខ **៧២៨៥** ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ប៉ុន្តែត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញតម្កល់សំណុំរឿងទុកដោយឥតចាត់ការតាមដីកាតម្កល់រឿងទុកឥតចាត់ការលេខ ២១០ អយព ចុះថ្ងៃទី **២៦** ខែ មករា ឆ្នាំ ២០១៧ ។ ហើយការលក់ទិញភាគហ៊ុន បានប្រព្រឹត្តទៅនៅថ្ងៃទី **១៧** ខែ មិថុនា ឆ្នាំ ២០១៤ ឯថ្ងៃដាក់ពាក្យបណ្តឹងប្រឆាំងនិងអង្គហេតខាងលើថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០២០ ដូច្នេះបើគិតពីថ្ងៃលក់ទិញភាគហ៊ុនមកដល់ថ្ងៃដាក់ពាក្យបណ្តឹង គឺមានរយៈពេលជាង ៦ ឆ្នាំ ទៅហើយ យោងមាត្រា **១០** ក្រមនីតិវិធីព្រហ្មទណ្ឌ អាជ្ញាយុកាលនៃបទល្មើសបទល្មើសមជ្ឈិមមានត្រឹម ៥ ឆ្នាំប៉ុណ្ណោះ ។

ខ្ញុំបាទសូមជម្រាបជូនថា ៖ តាមអង្គហេតុ និងភស្តុតាងដែលដើមបណ្តឹងរដ្ឋប្បវេណីបានយកមកធ្វើជាទឡ្ហីករប្តឹងប្រឆាំងនឹងរូបខ្ញុំបាទនាពេលនេះ គឺអង្គហេតុ និងភស្តុងតាងចាស់ដដែលៗ ដោយពុំមានអង្គហេតុ និងភស្តុតាងថ្មីដើម្បីនាំឲ្យមានការកែប្រែលទ្ធផលនៃដីកាតម្កល់រឿងទុកដោយឥតចាត់មុននោះឡើយ ។

សំណូមពរស្នើសុំ **ឯកឧត្តមព្រះរាជអាជ្ញា** មេត្តាសម្រេចតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ **៨១៨៧** ចុះថ្ងៃទី **២២** ខែ ធ្នូ ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកដោយឥតចាត់ការតទៅដោយសេចក្តីអនុគ្រោះ ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ ។

ឈប់សួរ បានអានឲ្យស្តាប់សាមីខ្លួនឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬផ្តិតស្រាមដៃជាមួយយើង ។

**អ្នកឆ្លើយ** **មេធាវ** **ក្រឡាបញ្ជី** **តំណាងអយ្យការ**



# ឧបសម្ព័ន្ធទី២[35]

[35] សំណុំរឿងព្រហ្មទណ្ឌលេខ១៣ (ក), ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០, សាលាដំបូងខេត្តឧត្តរមានជ័យ

សាលាដំបូង
ខេត្តឧត្ដរមានជ័យ
សាលក្រមលេខព្រហ្មទណ្ឌៈ ១៥ (ក)
ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**នាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តឧត្ដរមានជ័យ**

បង្កើតឡើងតាមច្បាប់ស្ដីពីការចាត់តាំងតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៤ ។

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តឧត្ដរមានជ័យ នាថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២០ និងប្រកាសជាសាធារណៈ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២០ នៅវេលាម៉ោងប្រាំបួនព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

---------- ប្រធានសាលាដំបូងខេត្តឧត្ដរមានជ័យ

**តំណាងអយ្យការ**

-------- ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តឧត្ដរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក ---- ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្ដរមានជ័យ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ២៧៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ ---ភេទស្រី អាយុ៥៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតភូមិក្រសាំង ឃុំសំលាញ់ ស្រុកអង្គរជ័យ ខេត្តកំពត ទីលំនៅសព្វថ្ងៃនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្ដរមានជ័យ ប្ដីឈ្មោះ --------មានកូន៣នាក់ ឪពុកឈ្មោះ ----(ស) ម្ដាយឈ្មោះ --- (ស) ទោសពីមុខគ្មាន កម្រិតវប្បធ៌ម មិនចេះអក្សរ (ក្រៅឃុំ) ។

មានលោក ---- ជាមេធាវីការពារឲ្យជនជាប់ចោទ ។

ពីបទៈ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្ដរមានជ័យ កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២-ឈ្មោះ ---- ភេទស្រី អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតភូមិច្បារអំពៅ សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្ដរមានជ័យ ប្ដីឈ្មោះ ----- មានកូន នាក់ ឪពុកឈ្មោះ ---- (រ) ម្ដាយឈ្មោះ ---- (ស) ទោសពីមុខគ្មាន (ក្រៅឃុំ) ។

មានលោក សំ ទិត្យសីហា ជាមេធាវីការពារឲ្យជនជាប់ចោទ ។

ពីបទៈ **សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៩, មាត្រា៣៩១និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ _ _ _ _ _ _ _ _ ភេទស្រី អាយុ ៥៦ ឆ្នាំ មុខរបរ ទីប្រឹក្សាគ្លីនិកកែរសម្ផស្ស សព្វថ្ងៃនៅទីក្រុងបាំងកក ប្រទេសថៃ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ _ _ _ _ _ ភេទប្រុស អាយុ ៤៥ ឆ្នាំ មុខរបរ ប្រធានក្រុមហ៊ុន កើតនៅភូមិបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

មានលោក សុខ អ្នង ជាមេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។

**ដំណើររឿងរបស់ជនជាប់ចោទមានដូចតទៅ៖**

កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ មានករណី **រំលោភលើទំនុកចិត្តនិងសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិជប់គរគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ _ _ _ ភេទស្រី អាយុ៥៩ឆ្នាំ ដោយដំបូងឡើយជនរងគ្រោះឈ្មោះ _ _ _ _ _ _ _ _ ជាជនជាតិថៃបានទិញដីមួយកន្លែងនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ មានទទឹង១០០ម៉ែត្រនិងបណ្តោយ៥០០ម៉ែត្រ។ ដោយភាគីថៃមានការទុកចិត ភាគីថៃក៏បានឲ្យឈ្មោះ _ _ _ ឈរឈ្មោះជំនួសវិញ ដោយឈ្មោះ _ _ _ ចាន់សារ៉ាង និងឈ្មោះ _ _ _ _ _ បានផ្តិតមេដៃធ្វើលិខិតផ្ទេរសិទ្ធិឲ្យទៅឈ្មោះ _ _ _ នៅចំពោះអាជ្ញាធរមូលដ្ឋាន ក៏បានយកទៅចុះហត្ថលេខានៅភូមិ-ឃុំ ហើយឯកសារទុកនៅឈ្មោះ _ _ _ ។ ក្រោយមកឈ្មោះ _ _ _ មិនបានយកឯកសារទៅឲ្យភាគីថៃទេ បែរជាលួចយកទៅធ្វើប្លង់រឹង និងបានយកទៅដាក់បញ្ចាំឲ្យឈ្មោះ _ _ _ _ . ភេទស្រី អាយុ៤៦ឆ្នាំ ជាប្រាក់ចំនួន ១៥,000,000(ដប់ប្រាំលាន)បាត។ បន្ទាប់មកភាគីថៃដឹងបានឲ្យឈ្មោះ _ _ _ យកប្លង់និងផ្ទេរសិទ្ធិឲ្យទៅឈ្មោះ _ _ _ _ _ វិញ ប៉ុន្តែឈ្មោះ _ _ _ ព្យាយាមគេចមិនដោះស្រាយ។

បានឃើញៈ ដីកាសន្និដ្ឋានស្ពាពរលេខៈ ០១៧ជសសព ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ។

បានឃើញៈ ដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ លេខៈ ០២២ ពស.ព្រទ/២០ ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តឧត្តរមានជ័យ។

បានឃើញៈ ដីកាចាត់តាំងចៅក្រមជំនុំជំរះលេខៈ ០៣០ ដចត/២០ របស់ប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ ។

**នាពេលសវនាការ ៖**

-ក្រោយពីបានដំណើរការកិច្ចដេញដោល

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ _ _ _

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ _ _ _ _

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ _ _ _ _ _ _ _

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងឈ្មោះ– – – – –

-ក្រោយពីបានស្តាប់ចម្លើយសាក្សីឆ្លើយបំភ្លឺ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សំណូមពររបស់ដើមបណ្តឹងប្បរដ្ឋវេណី

-ក្រោយពីបានពិនិត្យភស្តុតាង និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តឧត្តរមានជ័យ

## យល់ឃើញថា ៖

-កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ មានករណី **រំលោភលើទំនុកចិត្តនិងសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិជប់គរគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ– – – ភេទស្រី អាយុ៥៩ឆ្នាំ ដោយជនរងគ្រោះឈ្មោះ – – – – – – – – ជាជនជាតិថៃ បានទិញដីមួយកន្លែងនៅភូមិជប់គរគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ មានទទឹង១០០ម៉ែត្រនិងបណ្តោយ៥០០ម៉ែត្រ។ ហើយភាគីថៃបានឲ្យឈ្មោះ – – – ឈរឈ្មោះជំនួសវិញ ក្រោយពីផ្តិតមេដៃធ្វើលិខិតផ្ទេរសិទ្ធិរួច ក៏បានយកទៅឲ្យចុះហត្ថលេខានៅភូមិ-ឃុំ តែពុះទាន់ចុះទេ ឯកសារនេះទុកនៅឈ្មោះ – – – ។ ក្រោយមកឈ្មោះ – – – – មិនបានយកឯកសារទៅឲ្យភាគីថៃទេ បែរជាលួចយកទៅធ្វើប្លង់រឹងនិងបានយកទៅដាក់បញ្ចាំឲ្យឈ្មោះ – – – – ភេទស្រី អាយុ៤៦ឆ្នាំ ជាប្រាក់ចំនួន ១៥,០០០,០០០(ដប់ប្រាំលាន)បាត។ បន្ទាប់មកភាគីថៃដឹងបានឲ្យឈ្មោះ– – – យកប្លង់ និង ផ្ទេរសិទ្ធិឲ្យឈ្មោះ– – – – – វិញប៉ុន្តែឈ្មោះ– – – ព្យាយាមគេចមិនដោះស្រាយ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ – – – – បានឆ្លើយថា: នៅឆ្នាំ២០១២ ឈ្មោះ – – – – – – – – និងឈ្មោះ – – – – – – – – បានទិញដីនៅម្តុំជប់គរគីខាងលិច ក្រោយមកនៅឆ្នាំ២០១៤ ឈ្មោះ– – – – – – – – បានឲ្យឈ្មោះ– – – – – និងឈ្មោះ – – – – – – – – – ផ្ទេរសិទ្ធិដីខាងលើឲ្យទៅឈ្មោះ– – – ជាអ្នកកាន់កាប់ជំនួសវិញ ហើយបានយកឯកសារទៅផ្ទះមេភូមិចុះហត្ថលេខា តែត្រូវផ្អាកសិនដោយសារថ្នាក់លើផ្អាកទិញលក់ដីតំបន់នោះ និងបានឲ្យឈ្មោះ– – – – យកឯកសារប្រគល់ជូនម្ចាស់ដើមវិញ តែគាត់មិនបានប្រគល់ជូននោះទេ ហើយបានទៅលួចធ្វើប្លង់រឹងបន្ថែមទៀតផង។ រហូតដល់ភាគីថៃមកលក់ដីខាងលើនេះទើបដឹងថា ឈ្មោះ– – – បានលួចធ្វើប្លង់ ហើយបានយកទៅបញ្ចាំឲ្យគេទៀត ប៉ុន្តែតាមអំណានចម្លើយរបស់ឈ្មោះ– – – បានបញ្ជាក់ថា៖ ខ្លួនពុំដែលស្គាល់ឈ្មោះ– – – – – – – – ទេ នៅឆ្នាំ២០១៤ ខ្លួនបានទិញដីពីឈ្មោះ– – – – ក្នុងតំលៃ ២៥០,០០០ដុល្លា ខ្លួនបានប្រគល់ប្រាក់ឲ្យទៅឈ្មោះ– – – – – នៅភូមិជប់គរគីខាងលិច ដោយមានលិខិតផ្ទេរសិទ្ធិហើយឈ្មោះ– – – – និងឈ្មោះ– – – – – – – – បានទៅផ្តិតមេដៃឲ្យខ្លួននៅផ្ទះមេភូមិដើម្បីផ្ទេរសិទ្ធិដីចំនួន៥ហិចតា ដោយមេភូមិប្រាប់ថាមិនអីទេមានតែស្នាមមេដៃប៉ុណ្ណឹងបានហើយ ចំណែកហត្ថលេខាចាំពេលក្រោយ រួចខ្លួនបានទុកឯកសារនោះ ក្រោយមកឈ្មោះ – – – បាន

ហៅខ្លួនទៅជួបនិង បានយកឯកសារនោះទុក ពេលដែលឈ្មោះ ---- បានប្តូរចេញពីខេត្តឧត្តរមានជ័យ ស្រាប់តែមានឈ្មោះ------ បានយកឯកសារមកឲ្យខ្លួន ពេលនោះខ្លួនបានរត់ការធ្វើប្លង់រឹងដោយខ្លួនឯង ខ្លួនបានយកឯកសារទៅឲ្យសុរិយោដី និងបានបង់ពន្ធដារទៀតផង ក្រោយមកបានយកប្លង់នោះទៅដាក់បញ្ចាំនឹងឈ្មោះ---- ប្តីឈ្មោះ----- ដើម្បីខ្ចីប្រាក់ចំនួន ៥០០,០០០ (ហាសិបម៉ឺន)ដុល្លា ។

-តាមចម្លើយរបស់សាក្សីឈ្មោះ---- បានបញ្ជាក់ថាៈ ខ្លួនពិតជាបានចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១១៨៣/២០១២ ចុះថ្ងៃទី០១-តុលា-២០១២ ដោយឈ្មោះ----- បានលក់ដីមានទំហំ៥ហិចតា ១០០ម៉ែត្រគុណនឹង ៥០០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិជប់គរគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ឲ្យទៅឈ្មោះ------ ប្រាកដមែន ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ដីដែលមានស្នាមមេដៃឈ្មោះ--- ឈ្មោះ-----, ឈ្មោះ--------, ឈ្មោះ--- និងឈ្មោះ--- គឺមិនបានធ្វើនៅចំពោះមុខខ្លួនទេ ហើយខ្លួនក៏ពុំបានចុះហត្ថលេខាដែរ ចម្លើយនេះមានភាពស៊ីសង្វាក់នឹងចម្លើយរបស់ឈ្មោះ--- បានបញ្ជាក់ថាៈ ខ្លួនពិតជាបានលក់ដីខាងលើឲ្យទៅឈ្មោះ----- ប្រាកដមែន ក្នុងតម្លៃ ២៥០,០០០(ម្ភៃប្រាំម៉ឺន)ដុល្លា និងបានធ្វើលិខិតផ្ទេរដី និងប្លង់បង្ហាញទីតាំងចុះថ្ងៃទី០១-តុលា-២០១២ រួចហើយទើបទៅទទួលប្រាក់ នៅធនាគារអេស៊ីលីដា ក្រុងប៉ោយប៉ែតទាំងអស់គ្នា ក្រោយមកឈ្មោះ----- បានផ្ទេរសិទ្ធិដីឲ្យទៅឈ្មោះ--- ដោយអ្នកទាំងពីរផ្តិមេដៃចំពោះមុខខ្លួន តែមេភូមិពុំទាន់បានចុះហត្ថលេខានោះទេ ព្រោះគាត់មិនទាន់បានសុំយោបល់ពីថ្នាក់លើ ខ្លួនអត់បានឃើញគេប្រគល់ប្រាក់ឲ្យគ្នាទេ តែខ្លួនធ្លាប់ឧស្សាហ៍ឃើញឈ្មោះ--- ទៅមើលថែដីនោះ តែធ្លាប់ឮគេថាឈ្មោះ--- ទៅមើលថែដីឲ្យក្រុមហ៊ុនថៃ ដែលមានឈ្មោះ---

ជាអ្នកតំណាងឲ្យក្រុមហ៊ុន ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ---- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ-----, សាក្សីឈ្មោះ---, ឈ្មោះ---- នឹងឯកសារជាភស្តុតាងនានាបានបញ្ជាក់ថាៈ នៅឆ្នាំ២០១៤ ឈ្មោះ------ និងឈ្មោះ --------- ពិតជាបានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីមួយកន្លែងទំហំ១០០ម៉ែត្រគុណនឹង៥០០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ឲ្យទៅឈ្មោះ---- ប្រាកដមែន ដោយពេលនោះអាជ្ញាធរមូលដ្ឋានពុំបានចុះហត្ថលេខានៅឡើយ ដោយហេតុថាពុំទាន់ទទួលបានការអនុញ្ញាតពីថ្នាក់លើ ។ ដូច្នេះសកម្មភាពនេះតុលាការយល់ឃើញថាឈ្មោះ----- និងឈ្មោះ--- មានឆន្ទៈបង្កើតកិច្ចសន្យាលក់ទិញស្របនឹងបញ្ញត្តិមាត្រា ៥១៥ មាត្រា ៥១៦ និងមាត្រា ៥២៨ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណី ពុំមែនអំពើរំលោភលើទំនុកចិត្តឡើយ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ ----- បានបញ្ជាក់ថាៈ វិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខៈ ២២០២០១១៤----- ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ គឺពិតជាចេញដោយមន្ទីររៀបចំដែនដី នគរូបនីកម្ម សំណង់ និង សុរិយោដី ខេត្តឧត្តរមានជ័យ ពិតប្រាកដមែន ចំពោះលិខិតនៃការចុះវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនោះ គឺការិយាល័យភូមិបាលជាអ្នកទទួលបន្ទុកធ្វើ ដោយមានលោកម៉ៅ មឿនជាប្រធានការិយាល័យភូមិបាល និងលោក---- ជាអ្នកវាស់វែង ហើយការិយាល័យភូមិបាលស្រុកបញ្ជូនមកខាងមន្ទីររៀបចំដែនដី នគរូបនីកម្ម សំណង់ និង សុរិយោដី ខេត្តឧត្តរមានជ័យ ឈ្មោះ

គាត់បានអះអាងថាបានទិញដីពីឈ្មោះ______ ហើយនៅពេលធ្វើកំណត់ហេតុលើទម្រង់បែបបទបំពេញទិន្នន័យនោះ គឺត្រូវមានវត្តមានអ្នកទិញដីទៅបង្ហាញទីតាំងព្រំផងដែរ ។

-យោងតាមសេចក្តីជូនដំណឹង លេខ: ២៥០/១៩ សបព ចុះថ្ងៃទី ១៣-មិថុនា-២០១៩ របស់អភិបាលស្រុកបន្ទាយអំពិល ស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ដែលមានខ្លឹមសារដូចតទៅ: សូមជូនដំណឹងដល់សាធារណៈជន ពិសេសអ្នកកាន់កាប់ដី ព្រមទាំងអ្នកតំណាងគ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គ្រឹះស្ថានហិរញ្ញវត្ថុដែលមានការពាក់ព័ន្ធនិងក្បាលដីចំនួន០១ ស្ថិតនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ឲ្យបានជ្រាបថា ការិយាល័យរៀបចំដែនដី នគរូបនីកម្ម សំណង់ និង ភូមិបាល និងធ្វើការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យរួមមានផែនទីក្បាលដី គំនូសបង្ហាញទីតាំងក្បាលដី និងបញ្ជីឈ្មោះម្ចាស់ដីដែលផ្ទុកនូវទិន្នន័យប្រមូលបានកន្លងមកនៅឃុំអំពិល ស្រុកបន្ទាយអំពិល អាស្រ័យហេតុនេះសូមសាធារណៈជន អ្នកកាន់កាប់ដីព្រមទាំងអ្នកតំណាងគ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គ្រឹះស្ថានហិរញ្ញវត្ថុដែលមានការពាក់ព័ន្ធនិងក្បាលដីខាងលើ អញ្ជើញពិនិត្យទិន្នន័យក្នុងឯកសារ ដែលបានបិទផ្សាយដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬខុសឆ្គង ដែលត្រូវកែតម្រូវ ឬជំទាស់តវ៉ា ក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទី១៧-មិថុនា-២០១៩ ដល់ថ្ងៃទី ១៦-កក្កដា-២០១៩ ជាកំហិត នៅការិយាល័យរៀបចំ ដែនដី នគរូបនីកម្ម សំណង់ និង ភូមិបាលស្រុកបន្ទាយអំពិល ផុតរយៈពេលកំណត់ខាងលើ បើគ្មានការជំទាស់តវ៉ា ឬសុំកែតម្រូវទេ នោះទិន្នន័យដែលបានបិទផ្សាយត្រូវបានសន្មតថាមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ និងមិនអាចជំទាស់តវ៉ា ឬសុំកែតម្រូវនៅពេលក្រោយទៀតបានឡើយ ហើយសមត្ថកិច្ចជំនាញនឹងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យជូនអភិបាលរាជធានី-ខេត្ត ពិនិត្យសម្រេចមុននឹងផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ/វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនម្ចាស់សំណើរតាមការស្នើសុំ ។

-យោងតាមសេចក្តីជូនដំណឹងខាងលើនេះ ឃើញថាឈ្មោះ______ ពុំបានចូលខ្លួនមកប្តឹងជំទាស់តវ៉ាឡើយ ដូច្នេះតុលាការយល់ឃើញថា ឈ្មោះ______ ពិតជាបានលក់ដីឲ្យទៅឈ្មោះ

ពិតប្រាកដមែន ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ____បានឆ្លើយថា: ក្រោយពីធ្វើប្លង់រួចខ្លួនពិតជាបានយកប្លង់ដីនេះ ពិតប្រាកដមែន ដោយខ្លួនបានយកលុយជាបណ្តើរៗ ក្រោយមកបានធ្វើកិច្ចសន្យាបញ្ចាំចុះថ្ងៃទី ២៦-សីហា-២០១៩ ខ្លួនខ្ចីដើម្បីទៅរកស៊ី ចម្លើយនេះមានភាពស៊ីសង្វាក់និងចម្លើយរបស់ឈ្មោះ____ បញ្ជាក់ថា: ឈ្មោះ___, ឈ្មោះ____ និង______បានមកជួបខ្លួននៅការិយាល័យភូមិបាលស្រុកបន្ទាយអំពិលដើម្បីឲ្យខ្លួនធ្វើសាក្សីដឹងឮថាឈ្មោះ___ បានយកប័ណ្ណលេខ 2202 0114-0003 មកបញ្ចាំឲ្យឈ្មោះ_____ និង______ នូវទឹកប្រាក់ចំនួន ៥០០,០០០ (ហាសិបម៉ឺន)ដុល្លា ដោយមានការអង្វរពីអ្នកទាំងបីខ្លួនក៏បានចុះហត្ថលេខាលើកិច្ចសន្យាបញ្ចាំនោះ ដូច្នេះការឲ្យខ្ចីប្រាក់របស់ឈ្មោះ____ មិនមែនជាការសមគំនិតក្នុងអំពើរលោភលើទំនុកចិត្តឡើយ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ នៅឆ្នាំ២០១៤ ឈ្មោះ_____ និងឈ្មោះ________ ពិតជាបានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីមួយកន្លែងទំហំ១០០ម៉ែត្រគុណនឹង៥០០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិជប់គរគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ឲ្យទៅឈ្មោះ___ ប្រាកដមែន ដោយពេលនោះអាជ្ញាធរមូលដ្ឋានពុំបានចុះហត្ថលេខានៅឡើយ ដោយ

ហេតុថាពុំទាន់ទទួលបានការអនុញ្ញាតពីថ្នាក់លើ ។ អ្នកទាំងពីរអះអាងថាការផ្តិតមេដៃលើលិខិតខាងលើនេះគឺធ្វើឡើងដើម្បីឲ្យឈ្មោះ--- ធ្វើជាតំណាងនិងមើលការខុសត្រូវដីនោះជំនួសនិងដើម្បីងាយស្រួលក្នុងការលក់ទិញប៉ុណ្ណោះ ពុំមែនជាការទិញលក់ទេ ប៉ុន្តែត្រូវបាន--- ឆ្លើយបដិសេធថា: ការផ្តិតមេដៃលើលិខិតខាងលើគឺជាការទិញលក់យ៉ាងពិតប្រាកដ ដូចមានបញ្ជាក់ខ្លឹមសារក្នុងលិខិតផ្ទេរសិទ្ធិនោះស្រាប់ ដែលចម្លើយនេះមានភាពស៊ីសង្វាក់និងចម្លើយរបស់ឈ្មោះ---- ដែលជាអភិបាលស្រុកបន្ទាយអំពិល និងដែលបានផ្តិតមេដៃធ្វើជាសាក្សីលើលិខិតផ្ទេរសិទ្ធិនេះដែរ។ នៅឆ្នាំ២០១៩ ឈ្មោះ--- ក៏បានទំនាក់ទំនងអាជ្ញាធរពាក់ព័ន្ធដើម្បីធ្វើប័ណ្ណកម្មសិទ្ធិលើដីនេះ រហូតនិតិវិធីនៃការចេញប័ណ្ណដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី បានចេញវិញ្ញាបនបត្រ័សម្គាល់ម្ចាស់អចលនវត្ថុលេខ: ២២០២០ ១១៤-000៣ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៩ ដែលមានឈ្មោះ--- ជាម្ចាស់កម្មសិទ្ធិ បន្ទាប់មក ឈ្មោះ បានយកប័ណ្ណនេះទៅដាក់បញ្ចាំនឹងឈ្មោះ---- ក្នុងទឹកប្រាក់៥០ម៉ឺនដុល្លាអាមេរិក ដោយបានធ្វើជាកិច្ចសន្យាបញ្ចាំ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៩ ប្រាកដមែន។ ឈ្មោះ----- និងឈ្មោះ---------- បានឆ្លើយថា: ឈ្មោះ--- បានលួចធ្វើប័ណ្ណកម្មសិទ្ធិដោយមិនឲ្យខ្លួនបានដឹងជាមុនទេ។ ចំពោះកិច្ចសន្យាចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ នោះគ្រាន់តែជារូបភាពបំភ័ន្តការពិតតែប៉ុណ្ណោះ ការអះអាងនេះក៏ត្រូវឈ្មោះ--- បដិសេធផងដែរ ដោយលើកឡើងថា: ការធ្វើប័ណ្ណកម្មសិទ្ធិនេះ គឺដោយសារឈ្មោះ----- និងឈ្មោះ-------- បានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិរួចហើយ ចំពោះការដាក់បញ្ចាំដីនោះ គឺជារឿងពិតប្រាកដ និងដោយសារខ្លួនជាម្ចាស់កម្មសិទ្ធិលើដីនោះ ។ តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ បានចោទប្រកាន់លើឈ្មោះ-----ពី បទ: **រំលោភលើទំនុកចិត្ត** តាមមាត្រា ៣៩១ និង៣៩២ និងប្តឹងចោទប្រកាន់លើឈ្មោះ-----ពីបទ: **សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត** តាមមាត្រា២៩, មាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែផ្អែកតាមចំណុចដូចបានលើកឡើងខាងលើ ឃើញថាបុគ្គលពាក់ព័ន្ធបានអះអាងអំពីអង្គហេតុ និងមានទឡ្ហីករណ៍បញ្ជាក់រៀងៗខ្លួន ដោយហេតុនេះ ស្នើសុំឱ្យលោកប្រធានពិនិត្យពិចារណា និង សម្រេចតាមនីតិវិធី ។

-លោក ចិត្ត សង្ហារ ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ---- បានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយកូនក្តីខ្លួន និងដើមបណ្តឹងរដ្ឋប្បវេណី គឺថាអ្នកទាំងពីរពុំដែលស្គាល់គ្នាឡើយ ដូច្នេះការដែលឈ្មោះ------------ អះអាងថាបានទិញដីទំហំ៥ហិចតា នៅភូមិជប់គរគីខាងលិច ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ហើយឲ្យកូនក្តីខ្លួនជាអ្នកឈរឈ្មោះជំនួសនោះ គឺមិនពិតនោះទេ ព្រោះអ្នកទាំងពីរពុំដែលស្គាល់គ្នា។ ដើមបណ្តឹងបានផ្តោតសំខាន់ទៅលើលិខិតពីរ ទី១-លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីមានផ្តិតមេដៃ តែពុំមានចុះហត្ថលេខាទទួលស្គាល់ដោយអាជ្ញាធរ ទី២-លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី មានផ្តិតមេដៃ ចុះថ្ងៃទី២-៧-២០១៤ មានចុះហត្ថលេខាទទួលស្គាល់ដោយអាជ្ញាធរ ថាជាធាតុផ្សំបទល្មើស ប៉ុន្តែខ្លឹមសារនៃលិខិតទាំងពីរនេះវិញឃើញថា ឈ្មោះ ------. និងឈ្មោះ --- បានព្រមព្រៀងគ្នាលក់ទិញដីទំហំ៥ហិចតា យ៉ាងពិតប្រាកដ ដែលសកម្មភាពនេះ ស្របនឹងបញ្ញត្តិមាត្រា ៣១១ មាត្រា ៣៣៦ កថាខណ្ឌទី១ មាត្រា ៥១៥ មាត្រា ៥១៦ និងមាត្រា ៥២៨ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណី គឺមិនអាចចាត់ថាជាធាតុផ្សំនៃបទល្មើសនោះទេ ។ ពាក់ព័ន្ធនិងការចុះហត្ថលេខាដោយអាជ្ញាធរភូមិឃុំ ឬមិនអនុញ្ញាត្តិចុះហត្ថលេខា លើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីនេះ វាគ្រាន់តែជាវិធានការណ៍មួយ ដែលស្ថិតក្នុងក្របខណ្ឌនិងសិទ្ធិអំណាចរបស់រដ្ឋបាលខេត្តប៉ុណ្ណោះ ធ្វើយ៉ាងណាឲ្យស្របគ្នានឹងគោលនយោបាយ

នីតិនគរូនីយកម្ម និងសំណង់។ ឯអង្គហេតុក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ ពុំមានចរិតជាបទល្មើស រំលោភលើសេចក្ដីទុកចិត្ត តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌនោះទេ វាជាករណីនៃការលក់ទិញដីធ្លីរវាងកូនក្ដីខ្លួនជាមួយឈ្មោះ______ ។ ជាក់ស្ដែងខ្លឹមសារលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ឈ្មោះ ______ ភាគីអ្នកលក់បានបញ្ជាក់យ៉ាងមុតមាំថា (យើងខ្ញុំជាភាគីអ្នលលក់ សូមធានាថាបើថ្ងៃក្រោយសមត្ថកិច្ចជំនាញរកឃើញថាដីខាងលើនេះមានប័ណ្ណអចលនវត្ថុរួចហើយ ឬមានជនណាមកអះអាងថា ដីចំការនេះថាជាដីរបស់ខ្លួននោះ យើងខ្ញុំសុខចិត្តទទួលខុសត្រូវចំពោះមុខច្បាប់)។ ការធានាដូចនេះ បាននាំឲ្យភាគីមានស្មារតីទទួលខុសត្រូវខ្ពស់នូវការអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាបន្តបន្ទាប់ រហូតឈានដល់មានការផ្ទេរប្រគល់ដី និងចុះបញ្ជីអចលនវត្ថុជាសិទ្ធិរបស់អ្នកទិញចប់សព្វគ្រប់ស្របតាមបញ្ញត្តិមាត្រា ៥២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នឹងមាត្រា ៦៤ មាត្រា ៦៥ ច្បាប់ភូមិបាលឆ្នាំ២០០១ ។ យោងតាមយុត្តិសាស្ត្រលេខ ០២កយសណន/០៥ ចុះថ្ងៃទី ៨-៨-២០០៥ របស់ក្រសួងយុត្តិធម៌ និងតុលាការកំពូល បានកំណត់លិខិត៦ប្រភេទរួមមាន៖ កិច្ចសន្យាជួល, កិច្ចសន្យាផ្ញើទុក, កិច្ចសន្យាបញ្ចាំ, កិច្ចសន្យាឲ្យខ្ចីប្រើ, កិច្ចសន្យាអាណត្តិ និងកិច្ចសន្យាការងារ ថា ជាធាតុសម្ភារៈនៃធាតុផ្សំបទល្មើសបទរំលោភលើទំនុកចិត្ត ប៉ុន្តែអង្គហេតុក្នុងរឿងក្ដីនេះពុំឃើញមានឯកសារ ឬភស្តុតាងណាមួយអាចបញ្ជាក់បានជាធាតុសម្ភារៈ ដែលនឹងក្លាយជាធាតុផ្សំនៃបទល្មើសឡើយ ពោលគឺមានតែកិច្ចសន្យាផ្ទេរសិទ្ធិកាន់កាប់ដី ដោយការលក់ទិញដីនិងជាលិខិតស្នាមដែលទាក់ទងនិងការចុះបញ្ជីដីរបស់រដ្ឋបាលសុរិយោដីប៉ុណ្ណោះ បានន័យថានៅក្នុងសំណុំរឿងនេះពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីដាក់បន្ទុក ឬចោទប្រកាន់លើកូនក្ដីខ្លួន ពីបទរំលោភលើទំនុកចិត្តឡើយ ។

-លោក សុខ អួង ជាមេធាវីការពារឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ខ្លួនទទួលស្គាល់កំណត់ហេតុបណ្ដឹងរបស់កូនក្ដីខ្លួន និងកិច្ចសន្យាចុះថ្ងៃទី០២-១១-២០១៩ រវាងឈ្មោះ__________ និងឈ្មោះ___ (ឯកសារសរសេរជាភាសាថៃ) ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។ នៅឆ្នាំ២០១២កូនក្ដីខ្លួនពិតជាបានទិញដីនៅម្ដុំជប់គរគីខាងលិច ហើយនៅឆ្នាំ២០១៤ កូនក្ដីខ្លួនបានផ្ទេរសិទ្ធិដីខាងលើឲ្យទៅឈ្មោះ___ ជាអ្នកកាន់កាប់ជំនួស មិនមែនផ្ទេរកម្មសិទ្ធិទេ តែឈ្មោះ____ បានយកឯកសារផ្ទេរសិទ្ធិនេះ ទៅលួចធ្វើប្លង់រឹង និងបានយកប្លង់ទៅបញ្ចាំឲ្យឈ្មោះ_____ ទៀតផង ដូច្នេះខ្លួនស្នើសុំឲ្យតុលាការផ្ដន្ទាទោសឈ្មោះ___, ឈ្មោះ_____ និងបុគ្គលដែលពាក់ព័ន្ធក្នុងរឿងនេះដាក់ពន្ធនាគារតាមច្បាប់, សុំឲ្យចេញដីកាចាប់ខ្លួនឈ្មោះ___ និងឈ្មោះ____ មកអនុវត្តទោសក្នុងពន្ធនាគារ និងបង្គាប់ឲ្យឈ្មោះ___ ផ្ដិតមេដៃប្រគល់ប្លង់ដីឲ្យមកកូនក្ដីខ្លួនវិញ ព្រមទាំងសំណងជម្ងឺចិត្តចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លា។

-ជនជាប់ចោទឈ្មោះ___ ភេទស្រី អាយុ៥៩ ឆ្នាំ និងឈ្មោះ___ ភេទស្រី អាយុ៤៦ ឆ្នាំ ជានីតិជនមានស្មារតីទទួលខុសត្រូវ នឹងនិតិសម្បទាបរិបូរណ៍អាចពិចារណា និងយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ។

-ក្រោយពីឆ្លងកាត់ការសួរដេញដោលនាពេលសវនាការ ការពិនិត្យឯកសារនានា សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ និងការសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ តុលាការយល់ឃើញថា ពុំមានភស្តុតាងជាក់ស្ដែងច្បាស់លាស់ ស៊ីសង្វាក់ ដែលបង្ហាញឲ្យឃើញថាពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ___ ភេទស្រី ពីបទៈ **រំលោភលើទំនុកចិត្ត** និងឈ្មោះ____ ពីបទៈ **សមគំនិតក្នុង អំពើរំលោភលើទំនុកចិត្ត** ប្រព្រឹត្តភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរ

មានជ័យ កាលពីឆ្នាំ២០១២ រហូត ដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៩, មាត្រា៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌឡើយ ដូច្នេះគប្បីតុលាការសម្រេចឲ្យជនសង្ស័យឈ្មោះ ---- និង ឈ្មោះ ---- រួចផុតពីបទចោទ ។

-តាមដីកាបង្គាប់ឲ្យចាប់ខ្លួន ឈ្មោះ ---- ភេទស្រី អាយុ៤៦ឆ្នាំ លេខ: ០០៥៣ស/ព្រទ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តឧត្តរមានជ័យ ឃើញថាចៅក្រមស៊ើបសួរបានបំពេញដោយគោរពតាមទ្រឹស្តីអំពីភាពគ្រប់គ្រាន់នៃកិច្ចស៊ើបសួរ ប៉ុន្តែការចេញដីកាចាប់ខ្លួនឈ្មោះ ---- ភេទស្រី ក្នុងសំណុំរឿងនេះ ពុំមែនជាវិធានការចាំបាច់ឡើយ ព្រោះថាឈ្មោះ ---- បានចូលមកឆ្លើយបំភ្លឺនៅចំពោះមុខចៅក្រមស៊ើបសួររួចហើយ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ដូច្នេះគប្បីតុលាការពិចារណា បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួន ឈ្មោះ ---- តាមអំណាចសាលក្រមនេះ។

-វត្ថុតាងដែលចាប់យករួមមាន: អត្តសញ្ញាណប័ណ្ណឈ្មោះ ---- និងឈ្មោះ ---- ចំនួន ០២សន្លឹក (មនុស្សតែមួយ), លិខិតឆ្លងដែនឈ្មោះ ---- ចំនួន ០១ ក្បាល, បណ្ណបើកបរមានឈ្មោះ ---- ចំនួន ០១ សន្លឹក និងទូរស័ព្ទដៃម៉ាក HAUWEI ពណ៌ប្រាក់ចំនួន០១គ្រឿង គប្បីតុលាការប្រគល់ឲ្យម្ចាស់ដើមវិញ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ---- និងឈ្មោះ ---- ដែលមានលោក សុខ អួង ជាមេធាវីការពារសិទ្ធិ បានទាមទារសំណងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក តុលាការមិនអាចសម្រេចជូនបានទេ ព្រោះថាឈ្មោះ ---- និងឈ្មោះ ---- មិនមានកំហុសដែលធ្វើឲ្យមានព្យសនកម្មកើតឡើងឡើយ ។

**<u>ហេតុដូច្នេះ សាលាដំបូងខេត្តឧត្តរមានជ័យ</u>**

**<u>សម្រេច</u>** ៖

១- **<u>ឲ្យរួចផុតពីបទចោទលើឈ្មោះ</u>** ៖

ក-ឈ្មោះ ---- ភេទស្រី អាយុ៥៩ឆ្នាំ ជាតិខ្មែរ( សាវតាជាតិដូចខាងលើ) **ពីបទ: រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

ខ-ឈ្មោះ ---- ភេទស្រី អាយុ៤៦ឆ្នាំ ជាតិ ខ្មែរ( សាវតាជាតិដូចខាងលើ) **ពីបទ: សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៩, មាត្រា៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២- <u>បញ្ឈប់</u>ដីកាបង្គាប់ឲ្យចាប់ខ្លួន លើឈ្មោះ ---- លេខ: ០០៥៣ស/ព្រទ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០២០ ចាប់ពីពេលនេះតទៅ ។

៣- **<u>វត្ថុតាងដែលចាប់យករួមមាន:</u>** អត្តសញ្ញាណប័ណ្ណឈ្មោះ ---- និងឈ្មោះ ---- ចំនួន ០២សន្លឹក(មនុស្សតែមួយ), លិខិតឆ្លងដែនឈ្មោះ ---- ចំនួន០១ក្បាល, បណ្ណបើកបរមានឈ្មោះ:

_ _ ... _ ចំនួន ០១ សន្លឹក និងទូរស័ព្ទដៃម៉ាក HAUWEI ព៌ណប្រាក់ចំនួន០១គ្រឿង ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤- <u>សាលក្រម</u>នេះជំនុំជម្រះ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ _ _ _ _ _ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ _ _ _ _ _ _ _ _ , ជនជាប់ចោទឈ្មោះ _ _ _ និងឈ្មោះ _ _ _ _ ទុកសិទ្ធិទាស់ និងប្តឹង ឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

**ហត្ថលេខា និងត្រា ឯក ថាវី**

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា ឃន សុភល**

---

បានឃើញ

ប្រធានសាលាដំបូង

**ឃន សុភល**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំជូត ឯកស័ក ពុធសករាជ ២៥៦២

ឧត្តរមានជ័យ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២០

ក្រឡាបញ្ជីសវនាការ

**ឯក_ថាវី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តឧត្តរមានជ័យ**
លេខ ..020....... ដប.ចខ

## ដីកាបញ្ជាឲ្យចូលខ្លួន[១]

យើង ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូង ខេត្តឧត្តរមានជ័យ។

បានឃើញមាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញរបាយការណ៍លេខ ០២៩/១៩ រ.ប.ក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ ផែនការងារនគរបាលព្រហ្មទណ្ឌ ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល។

**យល់ឃើញថា**

-ជនជាប់សង្ស័យឈ្មោះ ហៅ ភេទស្រី អាយុ៥៩ឆ្នាំ មុខរបរ លក់ដូរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិក្រសាំង ឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត ទីលំនៅបច្ចុប្បន្នភូមិក្រសាំង ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត ប្ដីឈ្មោះ រៀង មានកូន០៣នាក់ ឪពុកឈ្មោះ (......) ម្ដាយឈ្មោះ (.......)។

-បានប្រព្រឹត្តអំពើ រំលោភលើទំនុកចិត្ត និងកំហែងយក តាមមាត្រា៣៩១,មាត្រា៣៩២,មាត្រា៣៦៣ និងមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ នៅចំណុចខេត្តឧត្តរមានជ័យ នៅឆ្នាំ២០១៩ ។

**បញ្ជា**

១. ឲ្យចូលខ្លួនឈ្មោះ ហៅ ភេទស្រី អាយុ៥៩ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិក្រសាំង ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត[២] ចូលទៅបង្ហាញខ្លួននៅស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ ឲ្យបានមុនថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ដើម្បីសាកសួរពីរឿង រំលោភលើទំនុកចិត្ត និងកំហែងយក។

២. បង្គាប់មក លោកស្នងការនគរបាលខេត្តឧត្តរមានជ័យ ចាត់ចែងអនុវត្តដីកានេះឲ្យបានសម្រេច។

៣. ដីកានេះមានអានុភាពអនុវត្តរយៈពេល០១ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៨កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ឧត្តរមានជ័យ,ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩
**ព្រះរាជអាជ្ញា**

កុយ ភាន់យ៉ា

---

(១) អនុលោមតាមមាត្រា១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ជាឲ្យចូលខ្លួន អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលខ្លួន។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តឧត្តរមានជ័យ

សំណុំរឿងព្រហ្មទណ្ឌលេខៈ ២៧៨

ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៩

# កំណត់ហេតុសួរចម្លើយ

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែវិច្ឆិកា ថ្ងៃទីដប់ វេលាម៉ោងពីរ និងសាមសិបនាទីរសៀល ។

យើង _ _ _ _ _ _ _ _ _ _ ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តឧត្តរមានជ័យ មានលោក _ _ _ _ _ _ ជាក្រឡាបញ្ជីអមផង បានស្តាប់ចម្លើយឈ្មោះ _ _ _ ជា ជនសង្ស័យ ដោយមានលោកមេធាវី _ _ _ _ .ជាអ្នកការពារចូលរួមជាមួយ ។

**សួរ-ឆ្លើយៈ** នាងខ្ញុំឈ្មោះ _ _ _ _ ភេទស្រី អាយុ៦០ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតនៅភូមិក្រសាំង ឃុំសំលាញ់ ស្រុកអង្គរជ័យ ខេត្តកំពត សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិគិរីមង្គល សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ប្តីឈ្មោះ _ _ _ _ _ មានកូន៣នាក់ ឪពុកឈ្មោះ _ _ _ (ស) ម្តាយឈ្មោះ _ _ _ _ (ស) ទោសពីមុន គ្មាន កម្រិតវប្បធម៌ មិនចេះអក្សរ ។

**សួរ-ឆ្លើយៈ** សមត្ថកិច្ចបានឃាត់ខ្លួននាងខ្ញុំ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង១០ព្រឹក សមត្ថកិច្ចឃាត់ខ្លួននាងខ្ញុំ មិនបានប្រាប់មូលហេតុការឃាត់ខ្លួននោះឡើយ ។

**សួរ-ឆ្លើយៈ** ចំពោះចម្លើយដែលនាងខ្ញុំ បានឆ្លើយ នៅចំពោះមុខសមត្ថកិច្ចនាងខ្ញុំ សូមរក្សាទុកដដែលដោយមិនមានការកែប្រែនោះទេ ។ មុនដំបូងឡើយឈ្មោះ _ _ _ និងនាងខ្ញុំជាអ្នកស្គាល់រាប់អានគ្នា បានបបួលនាងខ្ញុំទិញដីនៅម្តុំភូមិជប់គគី ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ទំហំ៥ហិចតា ប៉ុន្តែគ្មានលទ្ធភាពនាងខ្ញុំក៏មិនបានទិញដីនោះឡើយ លុះក្រោយមករំលងបានបីទៅបួនខែ នៅឆ្នាំមិនចាំឈ្មោះ _ _ _ _ _ _ បានលក់ដីខាងលើនេះមកឱ្យនាងខ្ញុំវិញក្នុងតំលៃ២៥០ ០០០ដុល្លា ដោយមិនបានធ្វើការកក់ប្រាក់ ឫធ្វើកិច្ចសន្យាលក់ទិញដីជាមួយគ្នានោះទេ ដោយឈ្មោះ _ _ _ ឱ្យនាងខ្ញុំមកទិញដីទើបនាងខ្ញុំទិញដីនោះតែម្តងទៅ ។ ពេលដែលនាងខ្ញុំប្រគល់ប្រាក់ថ្លៃទិញដីនោះគឺប្រគល់នៅក្នុងឡាន ជាមួយនិងឈ្មោះ _ _ _ _ _ តែម្តងដោយគ្មានសាក្សីនោះទេ ។

**សួរ-ឆ្លើយៈ** ក្រោយពីពេលដែលឈ្មោះ _ _ _ _ _ _ បានលក់ដីឱ្យនាងខ្ញុំហើយបានធ្វើលិខិតផ្ទេរសិទ្ធកាន់កាប់ដីមកឱ្យនាងខ្ញុំ តែពេលនោះឱ្យអាជ្ញាធរភូមិ ឃុំ ស្រុក មិនបានចុះហត្ថលេខាលើដីដែលនាងខ្ញុំនិងឈ្មោះ _ _ _ _ _ លក់ទិញនោះទេ ព្រោះដោយគាត់បានអះអាងថា ដីនៅតំបន់នោះ គឺបានហាមឃាត់មិនឱ្យលក់ទិញរឺដោះដូរនោះទេ ។ បន្ទាប់នាងខ្ញុំបានយកឯកសារដែលផ្តិតមេដៃនោះ ប្រគល់ជូនឯកឧត្តម _ _ _ ដើម្បីរក្សាទុកលុះក្រោយមកពេលគាត់ផ្លាស់ចេញ លោក _ _ _ _ _ បានយកឯកសារនោះមកឱ្យនាងខ្ញុំ ហើយពេលនោះនាងខ្ញុំបានយកទៅធ្វើប្លង់រឹងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខៈ ២២០២០១១៤-០០០៣ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តឧត្តរមានជ័យ ។

សួរ-ឆ្លើយ: [illegible] ៧៨ ០០០ ០០០([illegible]
លាន)បាត នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង ដោយមានឈ្មោះ _ _ ភេទស្រី ប្រហែល៤០ឆ្នាំ រស់នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ ជាអ្នកជូនទៅបញ្ជាំ ហើយបានធានាបន្ថែមទៀត ។

សួរ-ឆ្លើយ: សំនូមពរសុំឲ្យលោកស្រីព្រះរាជអាជ្ញារង ជួយឱ្យនាងខ្ញុំបានត្រលប់ទៅផ្ទះវិញផង ។

បញ្ចប់កំណត់ហេតុនៅវេលាបី និងម្ភៃនាទីរសៀល នាថ្ងៃទីខែឆ្នាំដដែល បានអានឲ្យស្ដាប់សាម៉ីខ្លួនឆ្លើយថាត្រឹមត្រូវ ហើយបានសុខចិត្តចុះហត្ថលេខា ឬផ្ដិតមេដៃស្ដាំជាមួយយើង ។

**អ្នកឆ្លើយ** **មេធាវី** **ក្រឡាបញ្ជី** **ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអមសាលាដំបូង**

**ខេត្តឧត្តរមានជ័យ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ២៧៨

ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩

លេខ: ....១៨៥....ដសបស

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង _ _ _ _ _ _ _ _ _ _ តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ។

-បានឃើញពាក្យបណ្តឹងលេខ: ០៣១ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៩ របស់ស្នងការនគរបាលខេត្តឧត្តរមានជ័យ ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្មតបានថា៖

១-ឈ្មោះ _ _ _ ភេទស្រី អាយុ ៥៩ ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិក្រសាំង ឃុំសំលាញ់ ស្រុកអង្គជ័យ ខេត្តកំពត ទីលំនៅបច្ចុប្បន្នភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ មុខរបរ លក់ដូរ ប្តីឈ្មោះ _ _ _ _ _ _ មានកូន ០៣នាក់ ឪពុកឈ្មោះ _ _ _ _ "ស" ម្តាយឈ្មោះ _ _ _ _ "ស" ទោសពីមុនគ្មាន កំរិតវប្បធម៌ គ្មាន ទោសពីមុនគ្មាន។

បានប្រព្រឹត្តដូចតទៅ: កាលពីឆ្នាំ ២០១២ រហូតមកដល់ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៩ មានករណី រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ_ _ _ _ ភេទស្រី អាយុ ៥៩ ឆ្នាំ ។ ដោយដំបូងឡើងជនរងគ្រោះឈ្មោះ _ _ _ _ _ _ _ _ _ _ ជាជនជាតិថៃបានទិញដីនៅមួយកន្លែងនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលមានទទឹង ១០០ម៉ែត្រ និងបណ្តោយ ៥០០ម៉ែត្រ ។ ក្រោយមកភាគីថៃបានឲ្យឈ្មោះ _ _ _ _ ឈរឈ្មោះជំនួសវិញ ក្រោយពីផ្តិតមេដៃធ្វើលិខិតផ្ទេរសិទ្ធិរួច ក៏យកទៅចុះហត្ថលេខាភូមិឃុំ ហើយឯកសារទុកនៅឈ្មោះ _ _ _ _ ។ ក្រោយមកឈ្មោះ _ _ _ _មិនបានយកឯកសារទៅឲ្យខាងភាគីថៃទេ បែរជាលួចយកទៅធ្វើប្លង់រឹង និងបានយកទៅដាក់បញ្ចាំជាប្រាក់ចំនួន ១៥.០០០.០០០ បាត ។ បន្ទាប់មកខាងភាគីថៃដឹង និងបានឲ្យឈ្មោះ _ _ _ _ យកប្លង់និងផ្ទេរសិទ្ធិឲ្យឈ្មោះ _ _ _ _ _ វិញ ប៉ុន្តែឈ្មោះ _ _ _ ព្យាយាមគេចមិនដោះស្រាយ ។

អំពើខាងលើជាបទល្មើស: រំលោភលើទំនុកចិត្ត ប្រព្រឹត្តភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីឆ្នាំ ២០១១ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា <u>៣៩១.៣៩២</u> នៃក្រមព្រហ្មទណ្ឌ។

**សម្រេច ៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ៖

☑ ដាក់អោយស្ថិតនៅក្រោមការពិនិត្យលើ:

ឈ្មោះ _ _ _ ភេទស្រី អាយុ ៥៩ឆ្នាំ ។

ពីបទ: រំលោភលើទំនុកចិត្ត។

☐ដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ.................................

☑ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន:លើឈ្មោះខាងលើ

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំអោយកើតមានសារជាថ្មី។

-ដើម្បីរារាំងកុំអោយមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំអោយមានការត្រូវរូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិត។

-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារ:។

-ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

-ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណ:កុំអោយមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

ថ្ងៃអាទិត្យ ១៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ពស២៥៦៣

ធ្វើនៅឧត្តរមានជ័យ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៩

**តំណាងអយ្យការ**

[illegible]

[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូង ខេត្តឧត្ដរមានជ័យ

លេខ : ០១៧ ដសសា

# ដីកាសន្និដ្ឋានស្ថាពរ

យើង _ _ _ _ _ _ _ _ _ ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តឧត្តរមានជ័យ

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ២៧៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ១៨៥ អ.យ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ: ១៧៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-បានឃើញលិខិតជូនព័ត៌មានអំពីការបញ្ចប់ការស៊ើបសួរលេខ: ០២៨ តព្រ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តឧត្តរមានជ័យ ។

-បានឃើញដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យលេខ: ០១៥ ត.ព្រ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តឧត្តរមានជ័យ ។

## ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

**ឃើញថា:**

១. ឈ្មោះ _ _ _ _ ភេទស្រី អាយុ៥៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតនៅភូមិក្រសាំង ឃុំសំលាញ់ ស្រុកអង្គរជ័យ ខេត្តកំពត សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ប្ដីឈ្មោះ _ _ _ _ _ មានកូន៣នាក់ ឪពុកឈ្មោះ _ _ _ (ស) ម្ដាយឈ្មោះ _ _ _ _ _ (ស) ទោសពីមុន គ្មាន កម្រិតវប្បធម៌ មិនចេះអក្សរ ។

២. ឈ្មោះ _ _ _ _ _ ភេទស្រី អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតនៅភូមិច្បារអំពៅ សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ប្ដីឈ្មោះ _ _ _ _ _ មានកូន......នាក់ ឪពុកឈ្មោះ _ _ _ _ (រ) ម្ដាយឈ្មោះ _ _ _ _ (ស) ទោសពីមុន គ្មាន កម្រិតវប្បធម៌ ...... ។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: **រំលោភលើទំនុកចិត្ត** និងសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចភូមិជប់គគីខាងលិច ឃុំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា២៩ មាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

បានប្រព្រឹត្តដូចតទៅ៖ កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ មានករណីរំលោភលើទំនុកចិត្ត និងសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចភូមិដប់គតីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលបង្កឡើងជនសង្ស័យឈ្មោះ_____ ភេទប្រុស អាយុ៥៩ឆ្នាំ ដោយដំបូងឡើយជនរងគ្រោះឈ្មោះ _________ ជាជនជាតិថៃបានទិញដីមួយកន្លែងនៅភូមិដប់គតីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តបន្ទាយមានជ័យ មានទទឹង១០០ម៉ែត្រ និងបណ្តោយ៥០០ម៉ែត្រ ។ ក្រោយមកភាគីថៃបានឱ្យឈ្មោះ _____ ឈរឈ្មោះជំនួសវិញ ក្រោយពីផ្តិតមេដៃធ្វើលិខិតផ្ទេរសិទ្ធិរួច ក៏បានយកចុះហត្ថលេខាភូមិឃុំ ហើយឯកសារទុកនៅឈ្មោះ _____ ។ ក្រោយមកឈ្មោះ_____ មិនបានយកឯកសារទៅឱ្យភាគីថៃទេ បែរជាលួចយកទៅធ្វើប្លង់រឹង និងបានយកទៅដាក់បញ្ចាំឱ្យឈ្មោះ_____ ភេទស្រី អាយុ៤៦ឆ្នាំ ជាប្រាក់ចំនួន១៥ ០០០ ០០០(ដប់ប្រាំលាន)បាត ។ បន្ទាប់មកភាគីថៃដឹង បានឱ្យឈ្មោះ_____ យកប្លង់ និងផ្ទេរសិទ្ធិឱ្យឈ្មោះ_____ វិញ ប៉ុន្តែឈ្មោះ_____ ព្យាយាមគេចមិនដោះស្រាយ ។

## ឃ្លាំងឃើញប្រាយការណ៍ ឬ កំណត់ហេតុផ្សេងៗទៀត

១/ ដំណាក់កាលនគរបាលយុត្តិធម៌:

-កំណត់ហេតុបណ្តឹងរបស់ឈ្មោះ _____ ភេទប្រុស អាយុ៤៥ឆ្នាំ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-កំណត់ហេតុស្តាប់ការបំភ្លឺឈ្មោះ _____ ភេទប្រុស អាយុ៤៥ឆ្នាំ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ បានឆ្លើយថា: ឈ្មោះ _________ និងឈ្មោះ_________ នៅឆ្នាំ២០១២ បានទិញដីនៅម្តុំដប់គតីខាងលិច ចំនួន៥ហិចតា ក្រោយមកនៅឆ្នាំ២០១៤ ឈ្មោះ ________ បានឱ្យឈ្មោះ _____ និងឈ្មោះ _______ ផ្ទេរសិទ្ធិដីខាងលើឱ្យទៅឈ្មោះ _____ ជាអ្នកកាន់កាប់ជំនួសវិញ ក្រោយមកបានយកឯកសារទៅផ្ទះមេភូមិចុះហត្ថលេខា តែផ្អាកសិនដោយសារថ្នាក់លើផ្អាកទិញលក់ដីតំបន់នោះក្រោយ ហើយបានឱ្យឈ្មោះ_____ យកឯកសារប្រគល់ជូនម្ចាស់ដើមវិញ តែគាត់មិនបានប្រគល់ជូននោះទេ ហើយបានទៅលួចធ្វើប្លង់រឹងបន្ថែមទៀតផង។ រហូតដល់ភាគីថៃមកលក់ខាងលើនេះទើបដឹងថា ឈ្មោះ_____ បានលួចធ្វើប្លង់ដីហើយបានយកទៅបញ្ចាំឱ្យគេទៀត ។

-កំណត់ហេតុស្តាប់ចម្លើយឈ្មោះ _____ ភេទប្រុស អាយុ៤៤ឆ្នាំ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

-កំណត់ហេតុស្តាប់ចម្លើយឈ្មោះ _____ ភេទស្រី អាយុ៥៩ឆ្នាំ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ បានឆ្លើយថា: នៅឆ្នាំ២០១៤ មានឈ្មោះ_____ បានលក់ដីមកឱ្យខ្លួនក្នុងតំលៃ២៥០ ០០០ដុល្លា ដោយមានលិខិតផ្ទេរសិទ្ធិហើយឈ្មោះ_______ និងឈ្មោះ _________ បានទៅផ្តិតមេដៃផ្ទះមេភូមិផ្ទេរសិទ្ធិដីចំនួន៥ហិចតា ដោយមេភូមិប្រាប់ថាមិនអីទេមានតែស្នាមមេដៃប៉ុណ្ណឹងបានហើយ ចំណែកហត្ថលេខាចាំពេលក្រោយ រួចខ្លួនបានទុកឯកសារនោះ រួចក្រោយមកឈ្មោះ _____ បានហៅខ្លួនទៅជួបនិងបានយកឯកសារនោះទុក ពេលដែលឈ្មោះ ___ បានប្តូរចេញពីខេត្តឧត្តរមានជ័យ ស្រាប់តែមានឈ្មោះ:

[redacted] បានយកឯកសារមកឱ្យខ្លួនរត់ការធ្វើប្លង់ ក្រោយមកបានយកប្លង់នោះទៅបញ្ចាំឱ្យគេចំនួន ៥០០ ០០០ដុល្លារ ។

**២/ ដំណាក់កាលអយ្យការ:**

-កំណត់ហេតុសួរចម្លើយជនសង្ស័យឈ្មោះ [redacted] ភេទស្រី អាយុ៥៩ឆ្នាំ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០១៩ បានឆ្លើយថា: មានឈ្មោះ[redacted] បានបបួលខ្លួនទៅទិញដីនៅម្តុំជប់គគីចំនួន៥ហិចតា តែគ្មានលទ្ធភាពក៏មិនបានទិញនោះទេ ក្រោយមកមានឈ្មោះ [redacted] បានលក់ដីខាងលើនេះមកឱ្យនាងខ្ញុំ ហើយបានធ្វើលិខិតផ្ទេរសិទ្ធិ តែអាជ្ញាធរមិនបានចុះហត្ថលេខានោះទេ បន្ទាប់មកស្រាប់តែលោក [redacted] បានផ្លាស់ប្តូរចេញពីខេត្តឧត្តរមានជ័យ លោក [redacted] បានហៅខ្លួនទៅយកប្លង់រឹងលើដីខាងលើនេះ ។

-កំណត់ហេតុទទួលវត្ថុចាប់យកលេខ: ១០៤ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

**៣/ ដំណាក់កាលចៅក្រមស៊ើបសួរ**

-កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៤៥ឆ្នាំ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ បានឆ្លើយថា: ខ្លួនមិនបានផ្ទេរសិទ្ធិលើការកាន់កាប់ដីចំនួន៥ហិចតាឱ្យទៅឈ្មោះ [redacted] នោះទេ ដោយពេលនោះគ្រាន់តែផ្ទេរឱ្យគាត់តំណាងឱ្យតែប៉ុណ្ណោះ ដោយគ្មានអាជ្ញាធរចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិនោះខ្លួនបានឱ្យឈ្មោះ[redacted] យកឯកសារនោះទៅឱ្យឈ្មោះ[redacted]វិញ ។ ក្រោយមកមានឈ្មោះ [redacted] ចង់ទិញដីចំនួន៥ហិចតាខាងលើនេះ ខ្លួនក៏បានយកលិខិតផ្ទេរសិទ្ធិ(ប្លង់ទន់) ឱ្យទៅគេមើល ស្រាប់តែឈ្មោះ [redacted] ទៅឆែកប្លង់នៅសុរិយោដី ស្រាប់តែដីខាងលើនេះជាកម្មសិទ្ធិរបស់ឈ្មោះ[redacted] ទៅវិញ ។ ដីខាងលើនេះខ្លួនមិនបានលក់ឱ្យទៅឈ្មោះ [redacted] នោះទេ គ្រាន់តែឱ្យឈរឈ្មោះជាតំណាងតែប៉ុណ្ណោះ ។

-កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៥៦ឆ្នាំ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ភេទប្រុស អាយុ៥១ឆ្នាំ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ភេទប្រុស អាយុ៤៣ឆ្នាំ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ ។

-កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ភេទប្រុស អាយុ៥៤ឆ្នាំ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ។

-កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ បានឆ្លើយថា: ខ្លួនបានឃើញឈ្មោះ [redacted] ផ្តិតមេដៃផ្ទេរសិទ្ធិឱ្យទៅឈ្មោះ [redacted] តែមិនឃើញឈ្មោះ[redacted] ឱ្យប្រាក់ទៅឈ្មោះ [redacted] វិញនោះទេ ដោយឈ្មោះ [redacted] គ្រាន់តែឈរឈ្មោះ ឱ្យក្រុមហ៊ុនថៃតែប៉ុណ្ណោះ ។

-កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ភេទប្រុស អាយុ៥២ឆ្នាំ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ។

-កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សីឈ្មោះ ---- ភេទប្រុស អាយុ៥៤ឆ្នាំ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ។

-កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សីឈ្មោះ ---- ភេទប្រុស អាយុ៥២ឆ្នាំ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ។

-កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សីឈ្មោះ --- ភេទប្រុស អាយុ៦៣ឆ្នាំ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សីឈ្មោះ ---- ភេទស្រី អាយុ៤៦ឆ្នាំ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សីឈ្មោះ ---- ភេទប្រុស អាយុ៥៨ឆ្នាំ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទឈ្មោះ --- ភេទស្រី អាយុ៥៩ឆ្នាំ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ បានឆ្លើយថា: ខ្លួនបានយកឯកសារដែលគេផ្ទេរ ទៅធ្វើប្លង់ដីពិតប្រាកដមែន តាំងពីផ្ទេរសិទ្ធិហើយមកខ្លួនបានយកឯកសារទៅជួបលោក ---- ហើយគាត់ប្រាប់ថាធ្វើប្លង់មិនទាន់បាននោះទេ ក្រោយពេលលោក --- ត្រូវបានគេដកពីតំណែង ខ្លួនចាប់ផ្ដើមធ្វើប្លង់ដីថ្មីវិញ ពេលធ្វើប្លង់បានក៏យកទៅដាក់បញ្ចាំឱ្យគេសម្រាប់យកប្រាក់ ។

-កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទឈ្មោះ ---- ភេទស្រី អាយុ៥៩ឆ្នាំ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ បានឆ្លើយថា: ខ្លួនបានទិញដីពីឈ្មោះ ------ លើដីទំហំ៥ហិចតា ក្នុងតំលៃ២៥០ ០០០ដុល្លា ដោយបានប្រគល់ប្រាក់ឱ្យគាត់តែម្ដង ហើយពេលទិញនោះខ្លួនមិនបានដឹងថាមេភូមិ មេឃុំ ធ្វើកិច្ចសន្យាទិញលក់អីអត់នោះទេ ចំពោះឈ្មោះ ------ ថាខ្លួនបានប្រគល់ឯកសារឱ្យគាត់វិញនោះគឺមិនពិតនោះទេ ព្រោះខ្លួនមិនដែលបានប្រគល់ឯកសាអ្វីនោះទេ ។ ក្រោយមកនាងខ្ញុំបានទៅជួបលោក ដើម្បីពិនិត្យឯកសារសម្រាប់ធ្វើការផ្ទេរសិទ្ធិ ក្រោយមកគាត់ប្រាប់ថាអាចផ្ទេរសិទ្ធិជាជនជាតិខ្មែរ ។

-ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ: ១៤៣ ត.ព្រ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩។

-ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ: ១៤៤ ត.ព្រ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

-ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្នលេខ: ០០៤ ព្រ.ទ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០១៩ ។

-សាលដីកាព្រហ្មទណ្ឌលេខ: ០៥ "ក្រ.VII.ភ.ស" ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

-ឯកសារផ្សេងៗ ដែលមានក្នុងសំណុំរឿង ។

**<u>យល់ឃើញថា</u>**

-នៅឆ្នាំ២០១២ រហូតមកដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ពិតជាមានអំពើ រំលោភលើទំនុកចិត្ត និងសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិជប់គគីខាងលិច ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ពិតប្រាកដមែន ដែលប្រព្រឹត្តដោយជនត្រូវចោទឈ្មោះ ភេទស្រី អាយុ៥៩ឆ្នាំ បានធ្វើ

សកម្មភាពលួចទៅធ្វើប្លង់ដីទំហំ៥ហិចតា ដែលដីនេះគឺមានម្ចាស់កម្មសិទ្ធិឈ្មោះ ------ ហើយបានយកទៅដាក់បញ្ចាំឱ្យឈ្មោះ កែវ រិន ជា ភេទស្រី អាយុ៤៦ឆ្នាំ ដើម្បីយកប្រាក់ ។

-ឆ្លងតាមចម្លើយរបស់ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងឯកសារនានា មានភាពស៊ីសង្វាក់គ្នាដែលយើងអាចបញ្ជាក់បានថា ---- ដំបូងឡើយគ្រាន់តែជាអ្នកតំណាងឱ្យឈ្មោះ ----- ក្នុងការមើលថែរក្សាដីចំនួន៥ហិចតា ដោយអ្នកទាំងពីរមិនលក់ដូរនោះទេ ក្រោយពេលដែលមានលិខិតផ្ទេរសិទ្ធិហើយក៏មិនបានចុះហត្ថលេខាដោយអាជ្ញាធរនោះដែរ ដោយលិខិតផ្ទេរសិទ្ធិទាំងនោះឈ្មោះ ---- បានប្រគល់ជូនទៅម្ចាស់ដើមវិញទាំងអស់ លុះក្រោយមកស្រាប់តែឈ្មោះ ------ ត្រូវការលក់ដីហើយបានឱ្យគេទៅពិនិត្យមើលបញ្ជីឈ្មោះដីក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តឧត្តរមានជ័យ ស្រាប់តែដីចំនួន៥ហិចតាខាងលើនេះមានម្ចាស់កម្មសិទ្ធិឈ្មោះ ---- ដែលខ្លួនបានផ្ទេរឱ្យតំណាងមើលដីលើកមុនទៅវិញ ។ ទន្ទឹមនិងនេះផងដែរ បើយោងតាមចម្លើយរបស់ឈ្មោះ ---- បានឆ្លើយបដិសេធគ្រប់តំណាក់កាលនៃនីតិវិធីក៏មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ បើផ្អែកតាមចម្លើយរបស់សាក្សីបញ្ជាក់ឱ្យឃើញថាឈ្មោះ ----គ្រាន់តែតំណាងឱ្យឈ្មោះ ------ ក្នុងការមើលថែរក្សាដីតែប៉ុណ្ណោះ មិនមានសិទ្ធិលក់ រឺបញ្ចាំដីចំនួន៥ហិចតានោះទេ តែផ្ទុយទៅវិញឈ្មោះ --- បានយកលិខិតដែលអាជ្ញាធរមិនបានចុះហត្ថលេខាទៅលួចធ្វើប្លង់រឹងលើដីចំនួន៥ហិចតាខាងលើនេះ ទៅវិញហើយបានយកទៅដាក់បញ្ចាំឱ្យទៅឈ្មោះ ---- យកប្រាក់បន្ថែមទៀតផង ។ ចំនែកឈ្មោះ ----- តុលាការបានធ្វើការកោះហៅចូលតាមនីតិវិធីស្រាប់តែជននេះមិនចូលខ្លួនមកនោះទេ ដោយបានគេចវេសនូវទង្វើដែលខ្លួនបានប្រព្រឹត្តទៅវិញ ។

-អំពើរបស់ជនត្រូវចោទ បង្ហាញឲ្យឃើញពីចេតនាទុច្ចរិត ដោយបានដឹងថាអំពើរបស់ខ្លួនជាអំពើខុសច្បាប់ តែខ្លួននៅតែប្រព្រឹត្តដោយមានចេតនាបំពានលើច្បាប់ ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ បង្កឲ្យមានការប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ដែលច្បាប់បានហាមឃាត់ និងតម្រូវឲ្យផ្តន្ទាទោស ។

-មានភស្តុតាង និងធាតុផ្សំបទល្មើសគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ --- ភេទស្រី អាយុ៥៩ឆ្នាំ និងឈ្មោះ ---- ភេទស្រី អាយុ៤៦ឆ្នាំ ពីបទៈ **រំលោភលើទំនុកចិត្ត និងសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត** បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា<u>២៩</u> មាត្រា <u>៣៩១</u> និងមាត្រា<u>៣៩២</u> នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិជប់គគីខាងលិច ឃុំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ។

-ក្រោយពីការស៊ើបសួរត្រូវបានបញ្ចប់ ផ្អែកតាមសំអាងហេតុនិងយោងសំអាងច្បាប់ខាងលើ ឃើញថាអំពើរបស់ជនត្រូវចោទបំពេញលក្ខខណ្ឌនូវធាតុផ្សំ នៃបទល្មើសព្រហ្មទណ្ឌដែលតំណាងអយ្យការអាចធ្វើសច្ចធារណ៍លើការចោទប្រកាន់ពីបទចោទខាងលើ ។

<u>**ហេតុដូច្នេះសម្រេច**</u>

ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច៖

☑-បញ្ជូនជនត្រូវចោទលើ

១. ឈ្មោះ . _ _ ភេទស្រី អាយុ៥៩ឆ្នាំ

ពីបទ: **រំលោភលើទំនុកចិត្ត** តាមមាត្រា ៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិជប់គគីខាងលិច ឃុំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ **ទៅតុលាការជំនុំជម្រះ** ។

២.ឈ្មោះ _ _ _ ភេទស្រី អាយុ៤៦ឆ្នាំ

ពីបទ: **សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្ត** តាមមាត្រា<u>២៩</u> មាត្រា <u>៣៩១</u> និងមាត្រា<u>៣៩២</u> នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិជប់គគីខាងលិច ឃុំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ **ទៅតុលាការជំនុំជម្រះ** ។

☑-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ: ២៧៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ ទៅសាលាដំបូងខេត្តឧត្តរមានជ័យ **ដើម្បីចាត់ការតាមនីតិវិធីព្រហ្មទណ្ឌ** ។

ថ្ងៃ ពុធ ៤រោច ខែមាឃ ឆ្នាំ កុរ ឯកស័ក ព.ស២៥៦៣

ឧត្តរមានជ័យ, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០២០

**តំណាងអយ្យការ**

[illegible]